# ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០១៩

## អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បើកកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្តីពីវិភាគជំបូងលើការកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមប្រពន្ធអនឡាញ

http://www.freshnewsasia.com/ 2019-11-29

**(សៀមរាប)៖** អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) សហការជាមួយអង្គការ Terre des hommes Netherland រៀបចំកិច្ចប្រជុំ ក្រុមការងារបច្ចេកទេសអន្តរក្រសួង ស្តីពី វិភាគជំបូងលើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធ អនឡាញនៅកម្ពុជា (OCSE) ធ្វើឡើងនៅខេត្តសៀមរាប ចាប់ពីថ្ងៃ២៥ ដល់ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ដឹកនាំដោយលោកស្រី សម្បត្តិ សុគន្ធា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក.ជ.ក តំណាងលោកស្រី ញ៉េប សុភាព អគ្គលេខាធិការ។

កិច្ចប្រជុំនេះមានគោលបំណងដើម្បីពិនិត្យ និងផ្តល់យោបល់លើខ្លឹមសារវិភាគស្ថានភាពជំបូង ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា និងកែសម្រួលនៅអត្ថបទនេះ ឲ្យស្របនឹងបរិបទ និងស្ថានភាពបច្ចុប្បន្នរបស់កម្ពុជា ដែលជាសមាជិក Pathfinding ដែលកំពុងចូលរួមយ៉ាងសកម្ម ក្នុងការលុបបំបាត់ អំពើហិង្សាលើកុមារ។ កិច្ចប្រជុំមានការចូលរួមពីលោក លោកស្រី ដែលអញ្ជើញមកពី ក្រសួង ស្ថាប័ន ពាក់ព័ន្ធនានា ក្នុងនោះ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ (នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ, នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន, នាយកដ្ឋានប្រឆាំងបទល្មើសតាមបច្ចេកវិទ្យា) ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (និយ័តករទូរគមនាគមន៍កម្ពុជា, តំណាងការិយាធីតិកម្ម) ក្រសួងការពារជាតិ (កងរាជអាវុធហត្ថលើផ្ទៃប្រទេស) មន្ត្រី ក.ជ.ក និងអង្គការ Terre de homme Netherland៕

## ប្រតិភូក្រសួងសង្គមកិច្ច ធ្វើដំណើរទៅថៃ ពិភាក្សាលើការគ្រប់គ្រង និងសាងសង់មណ្ឌលសំចត ទី១ នៅក្រុងប៉ោយប៉ែត

http://www.freshnewsasia.com/ 2019-12-01

**(ភ្នំពេញ)៖** មន្ត្រីជាន់ខ្ពស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ត្រីជំនាញជាច្រើនរូបទៀត បានធ្វើដំណើរចាកចេញពីព្រលានយន្តហោះអន្តរជាតិភ្នំពេញ នាថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩ ធ្វើដំណើរទៅកាន់ប្រទេសថៃ រយៈពេល ៥ថ្ងៃ ដើម្បីពិភាក្សាជាមួយភាគីថៃ លើពីការគ្រប់គ្រង និងសាងសង់មណ្ឌលមជ្ឈមណ្ឌលសំចតទី១ នៅក្រុងប៉ោយប៉ែត។

គណៈប្រតិភូកម្ពុជាខាងលើដឹកនាំដោយ លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងលោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរួមដំណើពីលោក តូច ចាន់នី អគ្គនាយក នៃអគ្គនាយកបច្ចេកទេស លោក សៅ ឡែន អនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ និងលោក លោកស្រីប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងមានការអញ្ជើញចូលរួមពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធរួមមាន ក្រសួងការបរទេស ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច ក្រសួងការងារ គណៈកម្មការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអភិបាលខេត្តបន្ទាយមានជ័យផងដែរ។ **ថ្លែងប្រាប់អ្នកសារព័ត៌មាននៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ លោក ញឹក វណ្ណារ៉ា មានលើកឡើងថា ដំណើរទស្សនកិច្ចនាពេលនេះ គឺបានផ្តោតសំខាន់លើ៖**

*ទី១ ៖ ការផ្លាស់ប្តូរព័ត៌មានពីជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណងធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

*ទី២ ៖ ការសម្របសម្រួលក្នុងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

*ទី៣៖ ការសម្របសម្រួលក្នុងកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។

*ទី៤៖ ការតាមដានត្រួតពិនិត្យ និងការប៉ាន់ប្រមាណលទ្ធផល នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

លោក ញ៉ឹក វណ្ណារ៉ា បានបន្ថែមថា ការសម្រេចកសាងមជ្ឈមណ្ឌលសំចតទី១ និងដំបូងបង្អស់ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត នាពេលនេះ គឺបានបង្ហាញពីចំណុចចាប់ផ្តើមជាវិជ្ជមានរបស់កម្ពុជា-ថៃ លើការពង្រឹង និងគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និង សមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្នុងប្រទេសថៃ ដែលកម្ពុជា និងថៃបានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩។ លោកបន្តថា ការបង្កើតមជ្ឈមណ្ឌលសំចតជួយជនរងគ្រោះ នៅតាមព្រំដែនជាច្រើនកន្លែង នៅតាមច្រកព្រំដែន ពិតជាមានសារសំខាន់ណាស់ និងបានចូលរួម ចំណែក ការងារសង្គមកិច្ច ក្នុងការទទួលមើលខុសត្រូវលើជនងាយរងគ្រោះឲ្យកាន់តែប្រសើរ និងមានប្រសិទ្ធភាពជាងមុន ជាពិសេសជាការលើកមុខមាត់ រាជរដ្ឋាភិបាល និងប្រទេសកម្ពុជា។

បើតាមរបាយការណ៍ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ បានឲ្យដឹងថា គិតមកដល់ពេលនេះ នាយកដ្ឋានមួយនេះទទួលបាន ជនរងគ្រោះ ពីការធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានាសរុបចំនួន ១១៧នាក់ ក្នុងនោះស្ត្រី៥៧នាក់ ដែលជនរងគ្រោះទាំងនោះ មកពីប្រទេសម៉ាឡេស៊ីចំនួន ៤១នាក់ ឥណ្ឌូនេស៊ី ចំនួន២០នាក់ ប្រទេសថៃចំនួន ៤៥នាក់ ប្រទេសចិនចំនួន៤នាក់ ប្រទេសជប៉ុនចំនួន៦នាក់ និងប្រទេសសិង្ហបុរីចំនួនម្នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 01-12-2019

នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ១៤និង២០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់។ ចំពោះពលករខ្មែរឆ្លងដែនខុសច្បាប់នេះ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ បានទទួលពលរដ្ឋខ្មែរចំនួន ០៤នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial/ General Department of Immigration GDI November 28 2019

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ បានទទួលពលរដ្ឋខ្មែរចំនួន ០៤នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកតាថាវ ខេត្តព្រះវិហារ៕

## កិច្ចប្រជុំរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប !

https://www.facebook.com/deputygovernoryousophear/ November 29 at 7:38 PM

ខេត្តសៀមរាប៖ រសៀលថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប (គ.ខ.ប.ជ) បានបើកកិច្ចប្រជុំប្រចាំខែវិច្ឆិកា ឆ្នាំ២០១៩ ក្រោមអធិបតីភាពលោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងមានការអញ្ជើញចូលរួមពី ព្រះរាជអាជ្ញារង ស្នងការរងនគរបាលខេត្ត មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត តំណាងមន្ទីរពាក់ព័ន្ធជុំវិញខេត្ត គណៈអភិបាលក្រុង-

ស្រុក និងតំណាងអង្គការដៃគូជាតិ-អន្តរជាតិ សរុប៥២នាក់ ក្នុងនោះស្រី ៣២នាក់ នៅបន្ទប់ប្រជុំរដ្ឋបាលសាលាខេត្តសៀមរាប។ កិច្ចប្រជុំបានដំណើរការតាមរបៀបវារៈរួមមាន៖

-ពិភាក្សាបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការអនុវត្តសកម្មភាព ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងខេត្តរួមមាន ទី១. បញ្ហាការបង្ការទប់ស្កាត់ដោយជំរុញឲ្យមន្ទីរអប់រំយុវជន និងកីឡាខេត្ត បង្កើតក្រុមការងារយុវជនដើម្បីធ្វើយុទ្ធនាការប្រឆាំងអំពើជួញដូរមនុស្សនៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងចូលរួមផ្សព្វផ្សាយតាមគ្រប់រូបភាព។ ទី២ បញ្ហាអំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ និងអំពើរំលោភសេពសន្ថវៈ និងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ (ពិភាក្សាលើនីតិវិធីតាមច្បាប់ និងការរួមសហការពីគ្រប់អ្នកពាក់ព័ន្ធលើការផ្តល់ភស្តុតាងដល់តុលាការ ក្នុងដំណើរការសវនាការ) ។ទី៣ បញ្ហាការគ្រប់គ្រង ទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស និងជនអន្តោប្រវេសន៍តាមបណ្តាលក្រុង-ស្រុក។ ទី៤ បញ្ហាប្រជាពលរដ្ឋចំណាកស្រុកដោយបន្សល់ទុកកូនជាច្រើននាក់ជាមួយជីដូន (ហើយបាត់ដំណឹងរយៈពេលជាយូឆ្នាំ) ។ ទី៥ បញ្ហាការទាញយកពត៌មានចាស់ (ករណីបញ្ចប់នីតិវិធីច្បាប់) មកផ្សព្វផ្សាយសារជាថ្មី ដែលធ្វើឲ្យប៉ះពាល់ផ្លូវចិត្តរបស់ជនរងគ្រោះ។ ទី៦ បញ្ហាជនសង្ស័យ ឬជនល្មើសដែលមានជំងឺវិបល្លាសស្មារតីប្រព្រឹត្តបទល្មើស។

-ពិភាក្សាលើការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ សម្រាប់ឆ្នាំ២០១៩ ដែលគ្រោងរៀបចំឡើងនាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ដោយមានអ្នកចូលរួមចំនួន១០០០នាក់ នៅក្នុងខេត្តសៀមរាប នាពេលខាងមុខ។ ការរៀបចំទិវាជាតិដ៏មានសារៈសំខាន់នេះ ក៏មានការចូលរួមសហការរៀបចំ ពីរដ្ឋបាលសាលាខេត្ត បណ្តាមន្ទីរ-អង្គភាព និងអង្គការដៃគូជាតិ-អន្តរជាតិ មួយចំនួនផងដែរ ដែលបានបង្ហាញអំពីការយកចិត្តទុកដាក់ កិច្ចសហការ រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស។

មានប្រសាសន៍ក្នុងកិច្ចប្រជុំ លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋានបានថ្លែងអំណរគុណចំពោះក្រុមការងារបច្ចេកទេស ដែលបានរៀបចំចុះទៅបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមការងារនៅថ្នាក់ក្រុង-ស្រុកទាំង១២ និងការចូលរួមរបស់លោក លោកស្រី ជាសមាជិក និងអង្គការដៃគូទាំងអស់ ដែលតែងតែចូលរួមរាល់គ្រប់សកម្មភាពរបស់លេខាធិការដ្ឋាន ទាំងធនធាន និងបច្ចេកទេស។ លោកស្រី ក៏បានសូមឲ្យមានការបន្តចូលរួមសកម្មភាពបែបនេះជារៀងរហូត។

## ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៩

## រដ្ឋមន្ត្រី វេង សាខុន៖ រាជរដ្ឋាភិបាលចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសកម្មភាពអាទិភាពមួយ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់

http://www.freshnewsasia.com/ 03-12-2019

**(ភ្នំពេញ)៖** លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩នេះ បានអញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី «ការបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងវិស័យកសិកម្ម» ដែលរៀបចំធ្វើឡើងនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ ពិធីនេះ មានការអញ្ជើញចូលរួម ពីសំណាក់លោករដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ, លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មន្ត្រីរាជការ បុគ្គលិកព្រមទាំងក្មួយៗនិស្សិតចំនួន ៧៥០នាក់។

លោករដ្ឋមន្ត្រី វេង សាខុន បានវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់គ្រប់ភាគីពាក់ព័ន្ធ ដែលសហការរៀបចំសិក្ខាសាលានេះឡើង បានយ៉ាងល្អប្រសើរ និងជាពិសេសសមិទ្ធផល ដែលក្រុមការងារសម្រេចបាន ទាក់ទងការបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងវិស័យកសិកម្ម។ លោករដ្ឋមន្ត្រី វេង សាខុន បានបញ្ជាក់

ថា «**រាជរដ្ឋាភិបាលបានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសកម្មភាពអាទិភាពមួយ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ និងជំរុញសកម្មភាពអនុវត្ត តាមរយៈធនធានមនុស្ស ថវិកា និងសម្ភារបម្រើឲ្យការងារប្រតិបត្តិការ**»។ជាមួយគ្នានោះ រដ្ឋមន្ត្រីក្រសួងកសិកម្ម ក៏បានឲ្យដឹងផងដែរថា ក្រសួងបានសហការអនុវត្ត ផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ឆ្នាំ២០១៩-២០២៣ ដើម្បីរួមចំណែកលើកកម្ពស់ប្រសិទ្ធភាព នៃការអនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាល។

**លោករដ្ឋមន្ត្រី វេង សាខុន ក៏បានផ្ដល់ជូននូវអនុសាសន៍គន្លឹះ ចំនួន៥ចំណុចសំខាន់ៗ ជូនអ្នកពាក់ព័ន្ធធ្វើជាមូលដ្ឋានអនុវត្តដូចជា៖**

**ទី១៖** បង្កើនកិច្ចសហការ ជាមួយគណៈកម្មាធិការជាតិ ផ្សព្វផ្សាយច្បាប់ គោលនយោបាយជាតិ សំខាន់ៗ អនុសញ្ញាអន្តរជាតិ ផែនការសកម្មភាពជាតិ ផែនការនៃអនុសញ្ញាអាស៊ាន ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផែនការសកម្មភាព ដែលបានកំណត់ដោយទ្វេភាគី និងពហុភាគីក្នុងតំបន់ និងអន្តរជាតិ។

**ទី២៖** គ្រឹះស្ថានអប់រំកសិកម្មទាំងអស់ ត្រូវខិតខំរួមគ្នាធ្វើការអប់រំផ្សព្វផ្សាយដល់ស្រទាប់យុវជន និស្សិតឲ្យយល់ដឹងច្បាស់អំពីគោលការណ៍ច្បាប់ ប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។

**ទី៣៖** ត្រូវសហការជាមួយស្ថាប័នមានសមត្ថកិច្ច ក្នុងការរាយការណ៍អំពីបទល្មើសដែលកើតមានក្នុងស្រទាប់កសិករនៅមូលដ្ឋាន ពាក់ព័ន្ធនឹងការជួញដូរមនុស្ស ការកេងប្រវ័ញ្ចពលកម្ម ការជួញដូរផ្លូវភេទ ការជួញដូរគ្រឿងញៀន។

**ទី៤៖** ត្រូវបន្តខិតខំបង្កើតការងារទាំងបរិមាណ និងគុណភាព ជាពិសេសសម្រាប់យុវជន តាមរយៈការផ្តល់ជំនាញបច្ចេកទេស ផ្តល់សេវាកសិកម្មនៅមូលដ្ឋាន ឲ្យកាន់តែងាយស្រួលដល់កសិករ រួមទាំងភ្នាក់ងារផ្សព្វផ្សាយឃុំ ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុក ព្រមទាំងផ្តល់កិច្ចសហការយ៉ាងទូលំទូលាយ និងជំរុញឲ្យមានការចូលរួមគាំទ្រពីដៃគូពាក់ព័ន្ធទាំងអស់តាមអភិក្រម «រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍ និងសហគមន៍»។

**ទី៥៖** សុំស្នើគណៈកម្មាធិការជាតិ បន្តការសម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ក៏ដូច ជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីធ្វើការបង្ការ បង្ក្រាប ប្រយុទ្ធប្រឆាំងរាល់ការជួញដូរមនុស្ស៕

## កម្ពុជា ស្នើថៃ ជួយបណ្ដុះបណ្ដាលគ្រូបង្គោល និងមន្ត្រីជំនាញកម្ពុជា ពង្រឹងការគ្រប់គ្រងមជ្ឈមណ្ឌលសំចតទី១ប៉ោយប៉ែត

http://www.freshnewsasia.com/ 2019-12-02

**(បាងកក)៖** កម្ពុជា បានស្នើថៃ ជួយបណ្ដុះបណ្ដាលគ្រូបង្គោល និងមន្ត្រីជំនាញ ក្នុងការគ្រប់គ្រងមជ្ឈមណ្ឌលសំចតទី១ប៉ោយប៉ែត។ ការស្នើសុំរបស់កម្ពុជានាពេលនេះ បានធ្វើឡើងនៅថ្ងៃដំបូងនៃដំណើរទស្សនកិច្ចរបស់ប្រតិភូសង្គមកិច្ចកម្ពុជា ទៅកាន់មជ្ឈមណ្ឌលគ្រប់គ្រងសុវត្ថិភាពជនរងគ្រោះ និងងាយរងគ្រោះ គឺមជ្ឈមណ្ឌល «ក្មេងស្រីក្រេតត្រាក់កាន» នៅខេត្តចន្ទបុរី ប្រទេសថៃ នាថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩។

ដំណើរទស្សនកិច្ចនៅមជ្ឈមណ្ឌលនេះ ដឹកនាំដោយ លោក ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងមន្ត្រីជំនាញរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ជាច្រើនរូបទៀត។ ក្នុងដំណើរទស្សនកិច្ចនោះ ប្រតិភូសង្គមកិច្ចកម្ពុជា បានជួបពិភាក្សាជាមួយភាគីថៃ ជុំវិញគម្រោងសាងសង់មជ្ឈមណ្ឌលសំចតទី១ នៅក្រុងប៉ោយប៉ែត ដោយភាគីកម្ពុជា ស្នើសុំឱ្យភាគីថៃ ជួយបណ្ដុះបណ្ដាលគ្រូបង្គោល ហើយផ្តល់មន្ត្រីជំនាញ ដើម្បី ហ្វឹកហាត់ដល់មន្ត្រីកម្ពុជា ក្នុងការគ្រប់គ្រងមជ្ឈមណ្ឌលនោះ។ បន្ថែមពីលើនេះ ប្រតិភូសង្គមកិច្ចកម្ពុជាក៏បានអញ្ជើញទស្សនកិច្ច កន្លែងបណ្ដុះបណ្ដាលតាមជំនាញនៅក្នុងមជ្ឈមណ្ឌលក្មេងស្រីផងដែរ រួមមាន មានជំនាញកាត់ដេរ ជំនាញធ្វើនំ សិប្បកម្មដោយដៃ ម៉ាស្សា កែសម្ផស្ស និង ត្បាញ។

កម្ពុជា និង ថៃ បានព្រមព្រៀងគ្នាហើយថានៅដើមឆ្នាំ ២០២០ខាងមុខនេះ នឹងចាប់ផ្តើមសាងសង់មជ្ឈមណ្ឌលសំចតមួយនៅប៉ោយប៉ែត សម្រាប់សង្គ្រោះ និង ផ្តល់សេវាដល់ជនរងគ្រោះ និង ងាយរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដែលគ្រោងនឹងចំណាយថវិកាប្រមាណជា១លានដុល្លារអាមេរិក ដែលជា ជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលថៃ ដើម្បីជាចំណងដៃមិត្តភាពរវាងប្រទេសទាំងពីរកម្ពុជា-ថៃ។

គួរបញ្ជាក់ថា លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងមន្ត្រីជំនាញជាច្រើនរូបទៀត នាថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩ បានចាកចេញពីកម្ពុជា ដើម្បីបំពេញទស្សនកិច្ចរយៈពេល៥ថ្ងៃ នៅប្រទេសថៃ ដើម្បីពិភាក្សាជាមួយភាគីថៃ លើពីការគ្រប់គ្រង និងសាងសង់មណ្ឌលមជ្ឈមណ្ឌលសំចតទី១ នៅក្រុងប៉ោយប៉ែត។ ដំណើរទស្សនកិច្ចនេះ ក៏មានការអញ្ជើញចូលរួមពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធរួមមាន ក្រសួងការបរទេស ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច ក្រសួងការងារ គណៈកម្មការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអភិបាលរងខេត្តបន្ទាយមានជ័យផងដែរ។

**ថ្លែងប្រាប់អ្នកសារព័ត៌មាននៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ លោក ញឹក វណ្ណារ៉ា មានលើកឡើងថា ដំណើរទស្សនកិច្ចនាពេលនេះ គឺបានផ្តោតសំខាន់លើ៖**

ទី១៖ ការផ្លាស់ប្តូរព័ត៌មានពីជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណងធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

ទី២៖ ការសម្របសម្រួលក្នុងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

ទី៣៖ ការសម្របសម្រួលក្នុងកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។

ទី៤៖ ការតាមដានត្រួតពិនិត្យ និងការប៉ាន់ប្រមាណលទ្ធផល នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម៕

## គួរអោយអាណិតកូនខ្មែរយើងណាស់ គាត់ត្រូវមេខ្យល់បោកយកទៅលក់នៅជាប់ជាយដែនម៉ាឡេ រយៈពេលជាង១០ឆ្នាំហើយ

http://khosja.com/ December 3, 2019

ពិតជាអាណិត និងខ្លោចចិត្តជាទីបំផុត ដែលប្អូនប្រុសម្នាក់ មានឈ្មោះ (បុត្រ) ត្រូវបានមេខ្យល់ម្នាក់ បោកអោយទៅបម្រើការនៅទូកនេសាទប្រទេសម៉ាឡេស៊ីតាំងតែអាយុ១៥ឆ្នាំ រហូតមកដល់ពេលនេះ មានអាយុ២៤ឆ្នាំ ក្រោយមកក៏រត់គេចខ្លួនបានមកដល់ស្រុកខ្មែរហើយដើរអស់រយៈពេលជាង២ខែមកហើយ ដើម្បីស្វែងរកក្រុមគ្រួសារ។ ក្នុងវីដេអូ ដែលបង្ហោះឡើង កាលពីថ្ងៃអាទិត្យ ទី០១ ខែធ្នូ ឆ្នាំ២០១៩ ដោយម្ចាស់គណនី ហ្វេសប៊ុកនារីម្នាក់ឈ្មោះ Jirada Nomo បានជួបសំភាសន៏ប្អូនប្រុសរូបនេះ ទាំងអារម្មណ៍អាណិតអាសូរជាពន់ពេក សឹងតែរកពាក្យអ្វីមកថ្លែងមិនបាន ព្រោះតែស្តាប់ការរៀបរាប់របស់យុវជនរូបនេះ គឺរស់នៅស្រុកគេពិតជាវេទនាខ្លាំងណាស់ ដោយមិនដែលស្គាល់ដីគោកនោះឡើយ គឺនៅតែកណ្តាលសមុទ្រប៉ុណ្ណោះ។

យ៉ាងណាមិញ នារីខាងលើ ក៏បានសរសេរប្រាប់ឱ្យដឹងថា៖"ទី០១ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង៥ល្ងាច បងប្អូនជួយស៊ែរម្នាក់មួយផង គាត់ត្រូវមេខ្យល់បោកយកទៅលក់នៅជាប់ជាយដែនប្រទេសម៉ាឡេស៊ីតាំងពី២០០៧ ស្រុកកំណើតគាត់នៅខេត្តបន្ទាយមានជ័យ គាត់នៅភ្នំតូចភ្នំធំគាត់ចាំបានតែភូមិហើយនឹងខេត្ត សូមបងប្អូនជួយស៊ែរគាត់ម្នាក់មួយផង ដើម្បីអោយបងប្អូនគាត់បានឃើញ ខ្ញុំមានតែទឹកចិត្តបន្តិចបន្តួចជូនពរគាត់ឲ្យគាត់ធ្វើដំណើរត្រឡប់ទៅផ្ទះវិញ សុវត្ថិភាព តាមផ្លូវ"៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាព្រឹកថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ បានទទួលពលករខ្មែរចំនួន ០៦នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 03-12-2019

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាព្រឹកថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ បានទទួលពលករខ្មែរចំនួន ០៦នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងការស្នាក់នៅខុសច្បាប់។ នគរបាលអន្តោប្រវេសន្តបានឲ្យដឹងថា ពលករខ្មែរទាំង ០៦នាក់នេះ មកពីខេត្តបាត់ដំបង ០៤នាក់ ស្រី ០១នាក់ និងខេត្តត្បូងឃ្មុំ ០២នាក់ ស្រី ០១នាក់៕

# ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១៩

## វិស័យកសិកម្មបានធ្លាក់ចុះ ធ្វើឲ្យប្រជាកសិករមួយចំនួន បាននាំគ្នាធ្វើចំណាកស្រុក ប្រឈមនឹងអំពើជួញដូរមនុស្សក្នុងវិស័យកសិកម្ម

http://www.cen.com.kh/ December 4, 2019

ភ្នំពេញ៖ រដ្ឋមន្ត្រីក្រសួងកសិកម្ម បានលើកឡើងថា កម្លាំងពលកម្មក្នុងវិស័យកសិកម្មបានធ្លាក់ចុះ ដែលជាមូលហេតុធ្វើឲ្យប្រជាកសិករមួយចំនួន បាននាំគ្នាធ្វើចំណាកស្រុកមករស់នៅ និងស្វែងរកការងារនៅទីក្រុង ឬទៅធ្វើការនៅក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ដែលជាហេតុនាំឲ្យមានបញ្ហាប្រឈមមួយផ្នែក ពីការធ្វើចំណាកស្រុក និងការជួញដូរមនុស្ស ដែលរដ្ឋាភិបាល ពិសេសគណៈកម្មាធិការជាតិក្នុងការបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានយកចិត្តទុកដាក់អនុវត្តធ្វើយ៉ាងណាឲ្យទទួលបានជោគជ័យ។ លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ បានថ្លែងបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងវិស័យកសិកម្ម" នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម នាថ្ងៃអង្គារ ទី៣ ខែធ្នូ ឆ្នាំ ២០១៩ ។

ក្នុងឱកាសនេះផងដែរ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានធ្វើបទបង្ហាញអំពីស្ថានភាពទូទៅ នៃការជួញដូរមនុស្សផលប៉ះពាល់ដល់ដំណើរការនៃការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច វប្បធម៌ និងប្រពៃណីដ៏ផូរផង់របស់ខ្មែរយើងដោយសារអំពើជួញដូរមនុស្សក្នុងវិស័យកសិកម្ម និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងវិស័យនេះ។

លោករដ្ឋមន្ត្រី បានថ្លែងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់គ្រប់ភាគីពាក់ព័ន្ធដែលសហការរៀបចំសិក្ខាសាលានេះឡើងបានយ៉ាងល្អប្រសើរ និងជាពិសេសសមិទ្ធផលដែលក្រុមការងារសម្រេចបានទាក់ទងការបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងវិស័យកសិកម្ម"។ ឆ្លៀតយកឱកាសនេះ លោកថ្លែងថា ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាបាននិងកំពុងអភិវឌ្ឍផ្នែកសេដ្ឋកិច្ចតាមបែបឧស្សាហកម្ម កសិឧស្សាហកម្ម និងកសិធុរកិច្ចផ្សេងៗទៀត គឺមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ដែលជាហេតុធ្វើឲ្យមានតម្រូវការកម្លាំងពលកម្មយ៉ាងច្រើនជាមួយនឹងប្រាក់កម្រៃខ្ពស់ ហើយចាំបាច់កម្លាំងពលកម្មទាំង អស់នោះបានស្រូបទាញយកពីវិស័យកសិកម្មដែលធ្វើឲ្យកម្លាំងពលកម្មក្នុងវិស័យនេះបានធ្លាក់ ចុះ ទាំងនេះជាមូលហេតុធ្វើឲ្យប្រជាកសិករមួយចំនួនបាននាំគ្នាធ្វើចំណាកស្រុកមករស់នៅ និងស្វែងរកការងារនៅទីក្រុង ឬទៅធ្វើការនៅក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ដែលជា ហេតុនាំឲ្យមានបញ្ហាប្រឈមមួយផ្នែក ពីការធ្វើចំណាកស្រុក និងការជួញដូរមនុស្ស ដែលរដ្ឋា ភិបាល ពិសេសគណៈកម្មាធិការជាតិក្នុងការបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានយកចិត្តទុកដាក់អនុវត្តធ្វើយ៉ាងណាឲ្យទទួលបានជោគជ័យ។

លោករដ្ឋមន្ត្រីបានបញ្ជាក់បន្ថែមថា រាជរដ្ឋាភិបាលបានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសកម្មភាពអាទិភាពមួយ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ និងជំរុញសកម្មភាពអនុវត្ត តាមរយៈធនធានមនុស្ស ថវិកា និងសម្ភារបម្រើឱ្យការងារប្រតិបត្តិការ ។ ព្រមជាមួយគ្នា ក្រសួងបានសហការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៩ -២០២៣ ដើម្បីរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរបស់រាជរដ្ឋា ភិបាល។ ស្ថិតក្នុងបរិបទនៃសាកលភាវូបនីយកម្ម កំណើនសេដ្ឋកិច្ច កំណើនប្រជាជន ការប្រែ ប្រួលអាកាសធាតុ បរិយាប័ន ការរីកចម្រើនលើវិស័យបច្ចេកវិទ្យាកសិកម្ម និងនិន្នាការនៃការវិវឌ្ឍន៍សេដ្ឋកិច្ចសកល និងជាពិសេសដើម្បីចូលរួមអនុវត្តភារកិច្ចរបស់ក្រសួងឲ្យបានពេញលេញ ខ្ជាប់ ខ្ជួន ទាន់ពេល និងមានប្រសិទ្ធភាពពាក់ព័ន្ធប្រធានបទខាងលើនេះ។ លោករដ្ឋមន្ត្រីបានផ្តល់ជូននូវអនុសាសន៍គន្លឹះចំនួន ៥ចំណុចសំខាន់ៗ ជូនអ្នកពាក់ព័ន្ធធ្វើជាមូលដ្ឋានអនុវត្តដូចជាៈ

ទី១-បង្កើនកិច្ចសហការជាមួយគណៈកម្មាធិការជាតិ ផ្សព្វផ្សាយច្បាប់ គោលនយោបាយជាតិ សំខាន់ៗ អនុសញ្ញាអន្តរជាតិ ផែនការសកម្មភាពជាតិ ផែនការនៃអនុសញ្ញាអាស៊ានស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផែនការសកម្មភាពដែលបានកំណត់ដោយទ្វេភាគី និងពហុភាគីក្នុងតំបន់ និងអន្តរជាតិ។

ទី២-គ្រឹះស្ថានអប់រំកសិកម្មទាំងអស់ត្រូវខិតខំរួមគ្នាធ្វើការអប់រំផ្សព្វផ្សាយដល់ស្រទាប់យុវជន និស្សិតឲ្យយល់ដឹងច្បាស់អំពីគោលការណ៍ច្បាប់ ប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។

ទី៣-ត្រូវសហការជាមួយស្ថាប័នមានសមត្ថកិច្ច ក្នុងការរាយការណ៍អំពីបទល្មើសដែលកើតមានក្នុងស្រទាប់កសិករនៅមូលដ្ឋានពាក់ព័ន្ធនឹងការជួញដូរមនុស្សការកេងប្រវ័ញ្ចពលកម្ម ការជួញដូរផ្លូវភេទ ការជួញដូរគ្រឿងញៀន។

ទី៤-ត្រូវបន្តខិតខំបង្កើតការងារទាំងបរិមាណ និងគុណភាព ជាពិសេសសម្រាប់យុវជនតាមរយៈការផ្តល់ជំនាញបច្ចេកទេស ផ្តល់សេវាកសិកម្មនៅមូលដ្ឋានឱ្យកាន់តែងាយស្រួលដល់កសិកររួមទាំងភ្នាក់ងារផ្សព្វផ្សាយឃុំ ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុក ព្រមទាំងផ្តល់កិច្ចសហការយ៉ាងទូលំទូលាយ និងជំរុញឱ្យមានការចូលរួមគាំទ្រពីដៃគូពាក់ព័ន្ធទាំងអស់តាមអភិក្រម "រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍ និងសហគមន៍"។

ទី៥- សុំស្នើគណៈកម្មាធិការជាតិ បន្តការសម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ក៏ដូច ជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីធ្វើការបង្ការ បង្ក្រាប ប្រយុទ្ធប្រឆាំងរាល់ការជួញដូរមនុស្ស៕ ដោយ ៖ បញ្ញាស័ក្តិ

## សមត្ថកិច្ចថៃ បានបញ្ជូនពលរដ្ឋខ្មែរចំនួន ០១នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 03-12-2019

នៅរសៀលថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ សមត្ថកិច្ចថៃ បានបញ្ជូនពលរដ្ឋខ្មែរចំនួន ០១នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនទៅធ្វើការខុសច្បាប់ នៅប្រទេសថៃ ដែលចេញតាមច្រកជាំ ខេត្តឧត្តរមានជ័យ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាព្រឹកថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ បានទទួលពលករខ្មែរចំនួន ០៦នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 04-12-2019

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាព្រឹកថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ បានទទួលពលករខ្មែរចំនួន ០៦នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងការស្នាក់នៅខុសច្បាប់។ នគរបាលអន្តោប្រវេសន្តបានឲ្យដឹងថា ពលករខ្មែរទាំង ០៦នាក់នេះ មកពីខេត្តបាត់ដំបង ០៤នាក់ ស្រី ០១នាក់ និងខេត្តត្បូងឃ្មុំ ០២នាក់ ស្រី ០១នាក់៕

## កម្ពុជា-ថៃ បើកកិច្ចប្រជុំពិភាក្សា ដើម្បីរឹតចំណងសាមគ្គីភាព និងសហប្រតិបត្តិការនៅតាមខ្សែបន្ទាត់ព្រំដែនរវាងខេត្តកោះកុង និងខេត្តត្រាត

http://www.freshnewsasia.com/ 2019-12-03

**(ត្រាត-ថៃ)៖** លោកស្រី មិថុនា ភូថង អភិបាលខេត្តកោះកុង ប្រទេសកម្ពុជា និងបានលោក ភិឈាន លឹមវាំងយូ ជាអភិបាលខេត្តត្រាត ប្រទេសថៃ បានដឹកនាំគណៈប្រតិភូបើកកិច្ចប្រជុំពិភាក្សា និងដើម្បីរឹតចំណងសាមគ្គីភាព និងសហប្រតិបត្តិការព្រំដែនសន្តិភាព នៃខេត្តកោះកុង និងខេត្តត្រាត។ កិច្ចប្រជុំពិភាក្សានេះ បានធ្វើឡើងនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៩ នៅរដ្ឋបាលសាលាខេត្តត្រាត នៅសាលប្រជុំសាលាខេត្តត្រាត ប្រទេសថៃ។

ក្នុងឱកាសនោះដែរ លោក ភិឈាន លឹមវងយូ បានថ្លែងថា ដើម្បីរឹតចំណងមិត្តភាពរវាងខេត្តកោះកុង និងខេត្តត្រាត ឃើញថា មានលក្ខណៈល្អប្រសើរ និងដោះស្រាយរាល់បញ្ហាអ្វីផ្សេងៗ ឱ្យមានភាពកាន់តែលឿននឹងសហប្រតិបត្តិការ ជាមួយគ្នាបានយ៉ាងល្អ ជាពិសេសអាជ្ញាធរ ខេត្តត្រាត និងអាជ្ញាធរខេត្តកោះកុង បានសហការគ្នា និងរៀនបទពិសោធន៍ពីគ្នាទៅវិញទៅមក ដើម្បីធ្វើការអភិវឌ្ឍខេត្ត ឱ្យមានសោភណ្ឌភាពលើវិស័យទេសចរណ៍ និងវិស័យសេដ្ឋកិច្ចជាពិសេសប្រជាពលរដ្ឋ និងប្រជាពលរដ្ឋឱ្យមានភាពសាមគ្គីគ្នា របៀបប្រជាពលរដ្ឋទាំងទ្វេភាគីហ្នឹង ដើម្បីសុវត្ថិភាព នៅតាមខ្សែបន្ទាត់ព្រំដែន។ លោកបានបញ្ជាក់ថា បើខេត្តកោះកុង ខ្វះអ្វីដែលត្រូវឱ្យអាជ្ញាធរខេត្តត្រាត ជួយអាជ្ញាធរខេត្តត្រាត នៅជួយដោះស្រាយ។ លោកបានបញ្ជាក់ថា នៅក្នុងប្រទេសថៃពលករ ធ្វើការងារ ដូច្នេះហើយបើអាជ្ញាធរខេត្តកោះកុង សម្រួលដើម្បីឱ្យពលករខ្មែរចូលមករកការងារធ្វើនៅខេត្តត្រានេះ លោកនឹងទទួលដោយស្របច្បាប់មិនថាស្រីប្រុសឡើយ។

លោកស្រី មិថុនា ភូថង បានថ្លែងថាខេត្តកោះកុង ជាមួយនឹងការហាត់ប្រាណ គឺជាខេត្តបងប្អូនដែលមានព្រំដែនជាប់គ្នា និងមានកិច្ចសហប្រតិបត្តិការជាមួយគ្នាលើគ្រប់វិស័យបានយ៉ាងល្អប្រសើរគួរជាទីមោទនៈ និងកិច្ចសហការផ្លាស់ប្តូរបទពិសោធន៍ និងរឹតចំណងមិត្តភាព តាមរយៈកិច្ចប្រជុំសិក្ខាសាលាកម្មសិក្សាការជួបសំដែងការគួរសម និងតាមរយៈកីឡាជាលក្ខណៈមិត្តភាពជាដើម។ លោកស្រីបានថ្លែងបន្តថានាពេលថ្មីៗនេះ ខេត្តត្រាត បានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការជួយឧបត្ថម្ភដល់ខេត្តកោះកុង នៅការសាងសង់មន្ទីរពេទ្យ មណ្ឌលសុខភាព អគារមជ្ឈមណ្ឌលសិក្សាសហគមន៍ទំនប់ការពារទឹកប្រៃ រថយន្តសង្គ្រោះបន្ទាន់អគារសង្គ្រោះបន្ទាន់ និងផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ដល់សហគមន៍មូលដ្ឋាន ក្នុងខេត្តកោះកុង ដែលជាទឹកចិត្តថ្លៃថ្លាបំផុត។

ការទំនាក់ទំនង និងកិច្ចសហការល្អៗ រវាងខេត្តយើងទាំង២ និងនៅតែបន្តនូវចំណងមិត្តភាព ជាមួយគ្នាកាន់តែប្រសើរឡើងថែមទៀត លើគ្រប់វិស័យ កិច្ចសហការដ៏ល្អកន្លងនេះ ឃើញថាខេត្តត្រាត និងខេត្តកោះកុង មានមិត្តភាពល្អរវាងមន្ត្រីរាជការ និងមន្ត្រីរាជការប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ហើយនៅតាមខ្សែបន្ទាត់ព្រំដែនឃើញថាមានសុវត្ថិភាពល្អ មានសន្តិភាពព្រំដែន គ្មានការប្រមូលផ្តុំបក្សពួក របស់ជនក្បត់ជាតិទណ្ឌិត សមរង្ស៊ី ដែលមានគម្រោងធ្វើដំណើរឆ្លងដែនប្រទេសថៃ ចូលមកប្រទេសកម្ពុជា ដើម្បីប្រមូលម្ញុំតវ៉ាប្រឆាំងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ដែលកើតចេញពីការបោះឆ្នោតនោះឡើយ។ លោកស្រីក៏សូមថ្លែងអំណរគុណដល់អាជ្ញាធរខេត្តត្រាត បានចូលថែរក្សាសន្តិភាពព្រំដែនល្អ៕

## សេចក្តីជូនដំណឹងស្តីពីពលករទំនាក់ទំនងមិនបាន

https://www.facebook.com/mtosbcambodia/ MTOSB Cambodia 04-12-2019

គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស សូមជូនដំណឹងដល់ពលករ ដែលមានឈ្មោះ ឈិត ម៉ាលៃ (CHHIT MALAI) ភេទ ប្រុស អាសយដ្ឋាន ភូមិត្រងិល ឃុំត្រងិល ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ សូមរួសរាន់ទំនាក់ទំនងមកគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ឱ្យបានមុនថ្ងៃសុក្រ ទី០៦

ខែធ្នូ ឆ្នាំ២០១៩ ម៉ោង០៣:០០នាទីល្ងាច ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣ ៦៥២៥ ៧៧៧, ០៨៨ ៣៥៩៨ ៨៨៨ និង ០១២ ៤៦៦ ២២២ នៅរៀងរាល់ម៉ោងធ្វើការ។

*បញ្ជាក់៖ គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស មិនអាចទំនាក់ទំនង តាមរយៈលេខទូរស័ព្ទរបស់គាត់ និងគ្រួសាររបស់គាត់បានឡើយ។ អាស្រ័យហេតុនេះ សូមបងប្អូន និងសាធារណជនមេត្តាជួយផ្សព្វផ្សាយបន្ត។ សូមអរគុណ!

## សេចក្តីជូនដំណឹងស្តីពីពលករទំនាក់ទំនងមិនបាន

https://www.facebook.com/mtosbcambodia/ MTOSB Cambodia 04-12-2019

គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស សូមជូនដំណឹងដល់ពលករ ដែលមានឈ្មោះ ណា ឡាវី (NA LAVY) ភេទ ប្រុស អាសយដ្ឋាន ភូមិ៣ ឃុំត្រពាំងច្រេស ស្រុកកូនមុំ ខេត្តរតនគិរី។ សូមរួសរាន់ទំនាក់ទំនងមកគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ឱ្យបានមុនថ្ងៃសុក្រ ទី០៦ ខែធ្នូ ឆ្នាំ២០១៩ ម៉ោង០៣:០០នាទីល្ងាច ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣ ៦៥២៥ ៧៧៧, ០៨៨ ៣៥៩៨ ៨៨៨ និង ០១២ ៤៦៦ ២២២ នៅរៀងរាល់ម៉ោងធ្វើការ។

*បញ្ជាក់៖ គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស មិនអាចទំនាក់ទំនង តាមរយៈលេខទូរស័ព្ទរបស់គាត់ និងគ្រួសាររបស់គាត់បានឡើយ។ អាស្រ័យហេតុនេះ សូមបងប្អូន និងសាធារណជនមេត្តាជួយផ្សព្វផ្សាយបន្ត។ សូមអរគុណ!

# ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៩

## វគ្គបណ្តុះបណ្តាលដល់ ក្រុមការងារថ្នាក់ស្រុក ស្តីពីការពង្រឹងប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://gdlf-kh.com// Prime vannak ខេត្តស្វាយរៀង 2019/12/05

ខេត្តស្វាយរៀង ៖ នៅថ្ងៃពុធ ៨កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ ២០១៩ លោកជំទាវ ឯក សុវណ្ណភារៈ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តស្វាយរៀង តំណាងឯកឧត្តម ម៉ែន វិបុល អភិបាលខេត្ត បានអញ្ជើញជាអធិបតីក្នុងវគ្គបណ្តុះបណ្តាលដល់ ក្រុមការងារថ្នាក់ស្រុក ស្តីពីការពង្រឹងប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលាស្រុកចន្ទ្រា ។

អញ្ជើញចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះដែលរួមមាន៖ លោក ថន ថាវុទ្ធា អភិបាលនៃគណៈអភិបាលស្រុកចន្ទ្រា លោក ប៉ែន សុវណ្ណនី អនុប្រធានមន្ទីរសង្គមកិច្ចខេត្ត លោកវរសេនីយ៍ឯក នេត សារឿន នាយការិយាល័យប្រឆាំងការជួញដូរ និងការពារអនីតិជនខេត្តស្វាយរៀង លោកស្រី សំ ថាវី អភិបាលរងស្រុកទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក លោកអធិការនគរបាលស្រុក មន្ត្រីការិយាល័យអប់រំយុវជននិងកីឡាស្រុក ការិយាល័យកិច្ចការនារីស្រុក ការិយាល័យសង្គមកិច្ចស្រុក លោកមេឃុំ ជំទប់ទី ជនបង្គោលឃុំ កម្លាំងប៉ុស្តិ៍រដ្ឋបាលរដ្ឋបាលឃុំ សរុបវគ្គមានចូលរួមចំនួន ៣៥នាក់ ស្រី១២នាក់ ៕

# ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ប្រជុំផ្សព្វផ្សាយលទ្ធផលបណ្តោះអាសន្ន នៃការវិភាគស្ថានភាពការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ

http://www.freshnewsasia.com/ 2019-12-05

**(បាត់ដំបង)៖** អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ (ក.ជ.ក) សហការជាមួយ អង្គការ Terre des hommes Netherland និងអង្គការ Save the Children តាមរយៈអង្គការសកម្មភាពដើម្បីកុមារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលបណ្តោះអាសន្ន នៃការវិភាគស្ថានភាពដំបូង លើការកេងប្រវ័ញ្ចផ្លូវភេទ លើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា (OCSE) និង ពិនិត្យលើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីប្រព័ន្ធការពារកុមារឆ្នាំ២០១៩-២០២៨។

កិច្ចប្រជុំនៅព្រឹកថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩នេះ បានរៀបចំធ្វើឡើងនៅសណ្ឋាគារប្រេស៊ីដង់ ខេត្តបាត់ដំបង ក្រោមអធិបតីភាព លោកស្រី ញ៉េប សុភាព អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក.ជ.ក និងមានការអញ្ជើញចូលរួមពីលោក លោកស្រី មកពីក្រសួង ស្ថាប័ន ដែលជាសមាជិក គណៈកម្មការការពារកុមារថ្នាក់ជាតិ មន្ត្រី ក.ជ.ក អង្គការសកម្មភាពដើម្បីកុមារ (APLE) និងអង្គការ Terre de homme Netherland។

គួរជម្រាបថា ការកេងប្រវ័ញ្ចរំលោភបំពានផ្លូវភេទ លើកុមារតាមប្រព័ន្ធអ៊ីនធឺណេត ដូចជា ជនខិលខូចល្បួងលួងលោម បោកបញ្ឆោតកុមារឲ្យបង្ហោះរូបភាព អាសអាភាសជាដើម រួចហើយពួកគេយករូបភាពទាំងនោះ ទៅគំរាមកុមារ ឬគ្រួសារកុមារឲ្យប្រគល់ផលប្រយោជន៍ម្យ៉ាងដល់ពួកគេ ឬបង្ហោះរូបភាពទាំងនោះ ដើម្បីរកផលប្រយោជន៍ ខណៈជនខ្លះល្បួងកុមារទៅរំលោភសេពសន្ថវៈជាដើម៕

# កម្ពុជានិងអូស្ត្រាលី មានកិច្ចសហប្រតិបត្តិការល្អ ក្នុងការប្រយុទ្ធប្រឆាំង អំពើភេរវកម្ម ការជួញដូរមនុស្ស និងគ្រឿងញៀន

http://www.cen.com.kh/archives/ December 5, 2019

ភ្នំពេញ៖ ចាប់ពីឆ្នាំ១៩៩៤មក មាននិស្សិតកម្ពុជាបានទៅសិក្សានៅប្រទេសអូស្ត្រាលី ចំនួន២៩០០ កន្លែង។ ក្នុងនោះនិស្សិតកម្ពុជាចំនួន ៨៥០នាក់ ទទួលបានអាហារូបករណ៍ពីរដ្ឋាភិបាលអូស្ត្រាលី ចំណែកទំហំពាណិជ្ជកម្មប្រទេស ទាំងពីរវិញ បានកើនដល់ ១,៣ពាន់លានដុល្លារ ហើយក្នុងនោះ កម្ពុជានិងអូស្ត្រាលី មានកិច្ចសហប្រតិបត្តិការល្អក្នុងការប្រយុទ្ធប្រឆាំង អំពើភេរវកម្មនានា ដូចជាការជួញដូរ មនុស្ស និងគ្រឿងញៀន។

ក្នុងឱកាសចូលជួបសម្តែងការគួរសម និងជម្រាបលា សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា លោកស្រី អានជីឡា ខូក្វ៉ាន់ (H.E.Mrs. Angela Corcoran) ឯកអគ្គរដ្ឋទូត នៃប្រទេសអូស្ត្រាលីប្រចាំនៅកម្ពុជា ដែលត្រូវចប់អាណត្តិ បានសម្តែងក្តីរីករាយ ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសកម្ពុជា និងអូស្ត្រាលី ទាំងខាងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ហើយប្រទេសអូស្ត្រាលី នៅតែបន្តគាំទ្រដល់ការអភិវឌ្ឍរបស់កម្ពុជាទៅមុខទៀត។

នៅក្នុងជំនួបនៅវិមានរដ្ឋសភា នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៥ ខែធ្នូ ឆ្នាំ២០១៩នេះ លោកស្រី អានជីឡា ខូក្វ៉ាន់ បានជម្រាបសម្តេចប្រធាន រដ្ឋសភាថា ចាប់តាំងពីឆ្នាំ១៩៩៣មក អូស្ត្រាលីបានចូលរួមចំណែកអភិវឌ្ឍន៍នៅកម្ពុជាជាច្រើនវិស័យ ដូចជា វិស័យអប់រំ កសិកម្ម ការបោសសម្អាតមីនជាដើម។ កម្ពុជានិងអូស្ត្រាលី មានកិច្ចសហប្រតិបត្តិការល្អក្នុងការប្រយុទ្ធប្រឆាំងអំពើភេរវកម្មនានា ដូចជាការជួញដូរមនុស្ស និងគ្រឿងញៀនជាដើម។ លោកស្រីឯកអគ្គរដ្ឋទូត បានគូសបញ្ជាក់ថា ចាប់ពីឆ្នាំ១៩៩៤មក មាននិស្សិតកម្ពុជាបានទៅសិក្សានៅប្រទេសអូស្ត្រាលី ចំនួន២៩០០ កន្លែង។ ក្នុងនោះនិស្សិតកម្ពុជាចំនួន ៨៥០នាក់ ទទួលបានអាហារូបករណ៍ពីរដ្ឋាភិបាលអូស្ត្រាលី។ ចំណែកទំហំពាណិជ្ជកម្មប្រទេស ទាំងពីរវិញ បានកើនដល់ ១,៣ពាន់លានដុល្លារ។ លោកស្រី អានជីឡា ខូក្វ៉ាន់ បានជម្រាបសម្តេចប្រធានរដ្ឋសភាថា ប្រទេសអូស្ត្រាលី បន្តគាំទ្រ និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយ កម្ពុជានៅលើគ្រប់វិស័យ។

ដោយឡែកនៅក្នុងឆ្នាំ២០២០នេះ អូស្ត្រាលីនឹងខិតខំជំរុញឲ្យមានដំណើរទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ របស់តំណាងរាស្ត្រវ័យក្មេងកម្ពុជា ទៅកាន់ប្រទេសអូស្ត្រាលី។ ប្រទេសអូស្ត្រាលីក៏បានត្រៀមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមាន នៃការអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ លើកទី២៨ នៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក (APPF) ដែលសម្តេចប្រធានរដ្ឋសភា និងគណៈប្រតិភូ សភាកម្ពុជា នឹងចូលរួមនៅប្រទេសអូស្ត្រាលី នាដើមខែមករា ឆ្នាំ២០២០ខាងមុខនេះផងដែរ។

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងអាណត្តិការទូតរបស់លោកស្រី អានជីឡា ខូក្វ៉ាន់ ដែលបានរួមចំណែកដល់ការបន្តថែរក្សាទំនាក់ទំនង មិត្តភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-អូស្ត្រាលី ឲ្យមាន ការរីកចម្រើនថែមមួយកម្រិតទៀត។ សម្តេចជឿជាក់ថា ក្នុងរយៈពេល៣ឆ្នាំដែលលោកស្រី ស្នាក់នៅកម្ពុជា លោកស្រីពិតជាបាន ឃើញជាក់ស្តែង នូវការអភិវឌ្ឍរីកចម្រើនជាបន្តបន្ទាប់របស់កម្ពុជា រួមទាំងសភាពការណ៍ពិតនៅកម្ពុជា ដែលផ្ទុយពីការបំពងសំឡេងពី ខាងក្រៅ ដើម្បីកេងចំណេញប្រយោជន៍នយោបាយបុគ្គលមួយចំនួនតូច។ សម្តេចប្រធានរដ្ឋសភា មានក្តីសង្ឃឹមថា ទោះបី លោកស្រី អានជីឡា ខូក្វ៉ាន់ បានចប់បេសកកម្មនៅកម្ពុជា តែលោកស្រីនៅតែមាន មនោសញ្ចេតនា និងទំនាក់ទំនងល្អជាមួយប្រជាជាតិកម្ពុជាជានិច្ច៕
ដោយៈកូឡាប

## ករណីបោកប្រាស់រឿងប្រាក់ឈ្នួលមួយបានកើតឡើងចំពោះពលករខ្មែរប្រមាណជាង ៣០នាក់ ដែលទៅធ្វើការនៅក្នុងប្រទេសថៃ

https://www.facebook.com/LabourOfficial/ **ពលករ** 04/12/19

រឿងនេះខ្ញុំសូមចែករំលែកជូនបងប្អូនពលករខ្មែរដែលធ្វើការរស់នៅក្នុងប្រទេសថៃទុកជាបទពិសោធន៍ មានករណីបោកប្រាស់រឿងប្រាក់ឈ្នួលមួយបានកើតឡើងចំពោះពលករខ្មែរប្រមាណជាង ៣០នាក់ ដែលទៅធ្វើការនៅក្នុងប្រទេសថៃ ករណីកើតឡើងបន្ទាប់ពីមានពលករខ្មែរ មួយក្រុមបាន ទៅជួលជនជាតិថៃធ្វើជាថៅកែ ដើម្បីយកឯសារធ្វើការទៅប្រកបរបរកស៊ីផ្ទាល់ខ្លួន។ ប៉ុន្តែអកុសលគាត់ត្រូវជនជាតិថៃបោកប្រាស់មិនអោយប្រាក់ឈ្នួលដែលគាត់ម៉ៅការពីក្រុមហ៊ុនប្រមាណជាង ១សែនបាត ហើយរត់គេចបាត់ទាក់ទងមិន ។ អ្វីដែរគួរឲ្យឈឺចាប់នោះគឺគាត់មិនស្គាល់អត្តសញ្ញាណច្បាស់លាស់របស់ជាតិថៃម្នាក់នោះឡើយ ទោះបីជាចង់ទៅប្តឹងក៏មិនកើត ព្រោះមិនស្គាល់ប្រវត្តិរូបជនបង្កណាមួយខ្លួនឯងក៏ធ្វើការខុសលក្ខខ័ណ្ឌច្បាប់ស្រុកគេទៀត ។ គាត់បានត្រឹមតែហួសចិត្តចំពោះរឿងដែលកើតឡើងចំពោះគាត់មិនអាចមានអ្វីដោះស្រាយបាន ប៉ុន្តែមនុស្សដែលលំបាកជាងគេក្នុងរឿងនេះគឺកម្មករដែលមកផ្សងព្រេងជាគាត់ ត្រូវជំពាក់ថ្លៃចាយវាយដូចជាថ្លៃម្ហូបអាហារហូបចុកដែលជឿពីតូមលក់នៅក្បែរកន្លែងធ្វើការនោះ។

រឿងនេះខ្ញុំលើកយកមកសរសេរប្រាប់បងប្អូនអោយបានដឹងពីព្រោះចង់ពន្យល់ថា ការធ្វើការមកផ្សងព្រេងបែបនេះគឺងាយនឹងរងគ្រោះបំផុតទាំងផ្លូវច្បាប់មិនអាចជួយបានហើយ អាចត្រូវទទួលទោសថែមទៀត។ ក្នុងច្បាប់ការងារថៃបានចែងថាពលករបរទេសមានសិទ្ធិធ្វើការងារតែបួនប្រភេទប៉ុណ្ណោះ៖
1.កម្មករ 2.អ្នកបំរើនៅតាមផ្ទះ 3.ជាងជួសជុលគ្រឿងយន្តនៅលើទូកនេសាទ 4.អ្នកបកប្រែភាសាខ្មែរ.ឡាវ.ភូមា
ចំពោះពលករចូលមកធ្វើការតាមរយៈប្រព័ន្ធ MOU អាចធ្វើការងារបានពីរប្រភេទ៖ 1.កម្មករ 2.អ្នកបំរើនៅតាមផ្ទះ

ដូច្នេះក្រៅពីការងារដែលបង្ហាញនៅខាងលើនេះគឺខុសច្បាប់ទាំងអស់ ប្រសិនបងប្អូនបំពានទៅធ្វើការងារក្រៅពីនេះ បងប្អូននិងត្រូវជនស្វែងរកផលប្រយោជន៍បោកប្រាស់កម្លាំងពលកម្ម ឬត្រូវរងការកេងប្រវ័ញ្ចប្រាក់ឈ្នួល ហើយអាចមានទោសតាមផ្លូវច្បាប់របស់ប្រទេសថៃថែម ។

## ពលករខ្មែរធ្វើការនៅកូរ៉េម្នាក់ បានដេកស្លាប់ក្នុងបន្ទប់ដោយសារគាំងបេះដូង គ្មានសូម្បីតែឪពុកម្ដាយព្រោះស្លាប់ចោលអស់

https://khmerpress.news/ cily sokDecember 5, 2019 at 2:48 am

ថ្មីៗនេះមានការចែករំលែកនៅលើបណ្ដាញសង្គមបង្ហាញនូវករណីគួរឲ្យសោកសង្រេង ដោយបុរសម្នាក់ជាពលករខ្មែរធ្វើការនៅប្រទេសកូរ៉េ បានគាំងបេះដូងស្លាប់យ៉ាងអាណោចអាធ័មនៅក្នុងបន្ទប់គេង។ ជនរងគ្រោះមានឈ្មោះ Kim Eng មានស្រុកកំណើតមកពីខេត្តពោធិ៍សាត់ ចំពោះព័ត៌មានលម្អិតនៃការស្លាប់របស់ជនរងគ្រោះពុំបានបញ្ជាក់នៅឡើយ ដោយមានការសង្ស័យថា អាចមកពីអាកាសធាតុនៅប្រទេសកូរ៉េត្រជាក់ពេកទើបធ្វើឲ្យជនរងគ្រោះគាំងបេះដូង។

នេះបើយោងតាមការបង្ហោះរបស់ប្រភពពីគណនីហ្វេសប៊ុកឈ្មោះ លី មន្នី ដាណេ បានឲ្យដឹងថា ៖ "ទៀតហើយពលករខ្មែរម្នាក់បានដេកស្លាប់ក្នុងបន្ទប់ដោយសារគាំងបេះដូង Kim Eng ឪពុកម្ដាយក៏ស្លាប់ចោលអស់ទៀតពិតជាអាសូរមែន។ ជីវិតពលករគឺបែបហ្នឹង ឈឺ ខំ លំបាកដើម្បីគ្រួសារនិងអនាគត សូមបងប្អូនពលករទាំងអស់ថែរក្សាសុខភាពទាំងអស់គ្នាផង សូមអោយបងបងទៅកាន់សុគតិភព"៕ ប្រភព៖

## ស្ត្រីជាម្ដាយម្នាក់ត្រូវចាប់ខ្លួននៅអាមេរិច ដោយសារលក់កូនតម្លៃ ២ពាន់ដុល្លារ

http://www.cen.com.kh/ December 4, 2019

ស្ត្រីជាម្ដាយម្នាក់នៅក្នុងរដ្ឋ Kentuckey សហរដ្ឋអាមេរិច បានរងការចោទប្រកាន់ពីបទលក់កូនក្នុងតម្លៃ ២.០០០ដុល្លារ។ នេះបើតាមការបញ្ជាក់របស់ប៉ូលីស។ ប៉ូលីសបានទាក់ទងស្ត្រីឈ្មោះ Maria Domingo-Perez អាយុ ៣១ឆ្នាំ ក្រោយពេលមន្ត្រីនៅសាលាបឋមសិក្សា ក្នុងទីក្រុង Bowling Green នៃរដ្ឋ Kentucky បានធ្វើការរាយការណ៍ថា ស្ត្រីរូបនោះបានឲ្យកូនទៅគេ។ ដំបូងឡើយស្ត្រីរូបនោះបានបដិសេធ ប៉ុន្តែក្រោយមកនាងបានទទួលស្គាល់ថា នាងបានឲ្យកូនទៅប្ដីប្រពន្ធមួយគូ។ នេះបើតាមការបញ្ជាក់របស់ប៉ូលីស។

ប្ដីប្រពន្ធមួយគូនោះបានប្រាប់អ្នកស៊ើបអង្កេតថា ពួកគេបានផ្ដល់ប្រាក់ចំនួន២.០០០ដុល្លារ សម្រាប់យកកូននោះ។ ពួកគេទាំងពីរនាក់ឈ្មោះ Catarina Jose Felipe វ័យ ៣៧ឆ្នាំ និងប្ដីឈ្មោះ Jose Manuel Pascual វ័យ ៤៥ឆ្នាំ។ អាជ្ញាធរមិនបានបញ្ជាក់ពីភេទ ឬអាយុរបស់កុមារដែលត្រូវគេលក់នោះទេ។ ស្ត្រីជាម្ដាយដែលលក់កូន ព្រមទាំងប្ដីប្រពន្ធនោះ ត្រូវបានចាប់ខ្លួន និងរងការចោទប្រកាន់ពីបទលក់ និងទិញកូន កាលពីថ្ងៃអង្គារ។ ប៉ូលីសបញ្ជាក់ថា កុមារដែលត្រូវស្ត្រីនោះយកលក់ ព្រមទាំងកូន ៤នាក់ទៀតរបស់នាង កំពុងស្ថិតនៅកន្លែងការពាររបស់ប៉ូលីស៕ អត្ថបទប្រែសម្រួលដោយ៖ សុភ័ក្រ ប្រភព៖ CNN

## ការស៊ើបអង្កេតរកឃើញក្មេងស្រីប៉ាគីស្ថានជាង ៦០០ នាក់ ត្រូវបានលក់ឲ្យរៀបការនឹងបុរសជនជាតិចិន

---

http://kampucheathmey.com/ 5/12/2019 9:40 AmKPT Plus,

ក្រុមអ្នកស៊ើបអង្កេតនៅក្នុងប្រទេសប៉ាគីស្ថានបានរកឃើញភ័ស្តុតាងបង្ហាញថា ក្មេងស្រីនិងស្ត្រីប៉ាគីស្ថានជាង ៦០០ នាក់ត្រូវបានគេលក់ជាកូនក្រមុំទៅឱ្យបុរសជនជាតិចិន និងត្រូវបាននាំទៅប្រទេសចិន។ សារព័ត៌មាន Associated Press ទទួលបានបញ្ជីឈ្មោះនារីវ័យក្មេងចំនួន ៦២៩ នាក់ដែលត្រូវបានគេយកធ្វើជាកូនក្រមុំទៅប្រទេសចិន ដែលចំនួនភាគច្រើនគឺនៅចន្លោះឆ្នាំ ២០១៨ និងខែមេសាឆ្នាំ ២០១៩ ។ បញ្ជីនេះគឺជាផ្នែកមួយនៃការ

ស៊ើបអង្កេតរបស់ប៉ូលីសប៉ាគីស្ថានដែលត្រូវបានគេរាយការណ៍ថា វាមានភាពយឺតយ៉ាវដោយសារមានសម្ពាធពីមន្ត្រីរដ្ឋាភិបាល ដោយព្រោះអាជ្ញាធរមានការព្រួយបារម្ភចំពោះទំនាក់ទំនងជាមួយប្រទេសចិន។

កាលពីខែតុលានេះ តុលាការនៅទីក្រុង Faisalabad បានដោះលែងជនជាតិចិនចំនួន ៣១ នាក់ដែលត្រូវបានចោទប្រកាន់ពីបទជួញដូរមនុស្ស បន្ទាប់ពីសាក្សីជាច្រើនមិនបានបង្ហាញខ្លួនសម្រាប់ការជំនុំជម្រះ។ ប៉ូលីសជឿជាក់ថាពួកគេត្រូវបានគេគំរាមកំហែងឬទទួលសំណូកដោយស្ងាត់ស្ងៀម។ ប្រទេសចិនត្រូវបានគេដឹងថាថាមានបុរសជាង ៣០ លាននាក់ច្រើនជាងស្ត្រី ដែលជាមូលហេតុធ្វើឱ្យការជួញដូរកូនក្រមុំពីប្រទេសជិតខាងជាទំនិញក្ដៅនៅក្នុងតំបន់ជនបទនៃប្រទេសនេះ។ ស្ត្រីទាំងនោះច្រើនតែត្រូវបានចាប់រំលោភ និងហាមមិនឱ្យទាក់ទងគ្រួសាររបស់ពួកគេនៅឯផ្ទះឡើយ ខណៈពួកគេនៅក្នុងប្រទេសចិន ។

ក្រុមគ្រួសារក្រីក្រនៃជនជាតិភាគតិចគ្រីស្ទានក្នុងប្រទេសប៉ាគីស្ថាន គឺជាគោលដៅជាពិសេសនៃជំនួញនេះ។ មន្ត្រីម្នាក់បានប្រាប់ទីភ្នាក់ងារព័ត៌មាន AP ថាឈ្មួញកណ្ដាលចិននិងប៉ាគីស្ថានអាចរកប្រាក់បានចន្លោះពី ៤ លានទៅ ១០ លានរូពី (២៥០០០ ដុល្លារទៅ ៦៥០០០ ដុល្លារ) ពីកូនកម្លោះជនជាតិចិន ចំណែកគ្រួសារកូនក្រមុំទទួលបានប្រាក់ ២លាន រូពី (១៥០០ ដុល្លារ) នៃប្រាក់នោះ។

## ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០១៩

## កិច្ចប្រជុំពិគ្រោះយោបល់ ស្ដីពី "សេចក្ដីព្រាងគោលការណ៍សម្រាប់កិច្ចការពារសិទ្ធិកុមារក្នុងបរិបទនៃការពពោះជំនួស

https://www.facebook.com/mojcambodia/ ក្រសួងយុត្តិធម៌ Ministry of Justice 05-12-2019

នាព្រឹកថ្ងៃព្រហស្បតិ៍ ៩កើត ខែមិគសិរ ឆ្នាំ កុរ ព.ស .២៥៦៣ ត្រូវនឹងថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០១៩ ឯកឧត្តម អង្គ វង្ស វឌ្ឍានា រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ បានអញ្ជើញបើកកិច្ចប្រជុំពិគ្រោះយោបល់ ស្ដីពី " សេចក្ដីព្រាងគោលការណ៍សម្រាប់កិច្ចការពារសិទ្ធិកុមារក្នុងបរិបទនៃការពពោះជំនួស "កិច្ចប្រជុំនេះ មានការចូលរួមពីអ្នកជំនាញនៃប្រទេសនានា រួមទាំងប្រទេសក្នុងតំបន់អាស៊ាន ព្រមទាំងស្ថាប័នជាតិពាក់ព័ន្ធមួយចំនួន ដែលធ្វើការពាក់ព័ន្ធនឹងការពពោះជំនួសក្នុងព្រះរាជាណាចក្រកម្ពុជា ។

កិច្ចប្រជុំនេះប្រព្រឹត្តទៅរយៈពេល ០២ថ្ងៃ គឺថ្ងៃទី៥-៦ ខែធ្នូ ឆ្នាំ២០១៩ ក្រោមកិច្ចសហការរវាងក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គមកិច្ច និងសន្តិសុខសង្គម នៃព្រះរាជាណាចក្រថៃ និងអង្គការ International Social Service (ISS) ដើម្បីពិគ្រោះយោបល់ទៅលើ បរិបទនៃការពពោះជំនួស ក្នុងថ្នាក់តំបន់ និង ថ្នាក់អន្តរជាតិ ក្នុងគោលបំណង រួមគ្នាការពារសិទ្ធិមនុស្ស សិទ្ធិស្ត្រី និង សិទ្ធិកុមារ ។

## ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បន្តបើកកិច្ចប្រជុំពិនិត្យ និងផ្ដល់ឯកសារលើសេចក្ដីព្រាងគោលនយោបាយជាតិស្ដីពី ប្រព័ន្ធកិច្ចការពារកុមារ

http://www.freshnewsasia.com/ 2019-12-06

**(បាត់ដំបង)៖** អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ នេះ បានបន្តកិច្ចប្រជុំគណៈកម្មការការពារកុមារថ្នាក់ជាតិ ដើម្បីពិនិត្យ និងផ្ដល់ការឯកភាពលើសេចក្ដីព្រាងគោលនយោបាយជាតិ ស្ដីពីប្រព័ន្ធកិច្ចការពារកុមារ នៅសណ្ឋាគារប្រេស៊ីដង់ ខេត្តបាត់ដំបង។

កិច្ចប្រជុំនេះ ត្រូវបានធ្វើឡើងក្រោមអធិបតីភាព លោកស្រី ញ៉េប សុភាព អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក.ជ.ក និងមានការអញ្ជើញចូលរួមពីលោក លោកស្រី មកពីក្រសួង ស្ថាប័ន ដែលជាសមាជិកគណៈកម្មការការពារកុមារថ្នាក់ជាតិ និងមន្ត្រី ក.ជ.ក ដោយមានការឧបត្ថម្ភពីអង្គការ PLAN។

គួរជម្រាបថា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ធ្លាប់បានកំណត់យុទ្ធសាស្ត្រសំខាន់ចំនួន ៥ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ២០១៩ -២០២៣ ក្នុងគោលដៅសំខាន់ធ្វើយ៉ាងណា ឲ្យកុមារកម្ពុជាទទួលបានសិទ្ធិមូលដ្ឋានពេញលេញ។ យុទ្ធសាស្ត្រសំខាន់ទាំង៥នោះ រួមមាន៖ ការពង្រឹងកិច្ចការពារ និងពិនិត្យតាមដានការលើកកម្ពស់សិទ្ធកុមារ ការបង្កើនការអប់រំផ្សព្វផ្សាយ និងអភិវឌ្ឍន៍ធនធានមនុស្ស ពង្រឹងពង្រីកក្រុមការងារ ដើម្បីកុមារក្រសួងស្ថាប័ន ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍន៍ភាពជាដៃគូ និងបង្កើនការអប់រំផ្សព្វផ្សាយពង្រឹងកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមាររាជធានី-ខេត្ត៕

## មន្ត្រីជាន់ខ្ពស់ក្រសួងសង្គមកិច្ច៖ ដំណើរទស្សនកិច្ចនៅថៃ ផ្តោតលើការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទទួលបានជោគជ័យ

http://www.freshnewsasia.com/ 2019-12-07

**(ភ្នំពេញ)៖** ដំណើរទស្សនកិច្ច នៅប្រទេសថៃ ផ្តោតលើការជួយជនរងគ្រោះ ដោយអំពើជួញដូរមនុស្សបានបញ្ចប់ ដោយភាពជោគជ័យ យ៉ាងត្រចះត្រចង់។ ជោគជ័យយ៉ាងត្រចះត្រចង់ដោយសារភាគីថៃ បានយល់ព្រមតាមសំណើរបស់កម្ពុជា គឺភាគីថៃនឹងបំពាក់បរិក្ខារទាំងអស់ នៅក្នុងមជ្ឈមណ្ឌលរួមទាំង ផ្តល់ការបណ្តុះបណ្តាល ដល់បុគ្គលិកជំនាញក៏ដូចជា បុគ្គលិកបម្រើការងារ នៅក្នុងមជ្ឈមណ្ឌល ហើយភាគីថៃ ក៏នឹងបន្ថែមអ្នកជំនាញរបស់ខ្លួនមកអមក្នុងការគ្រប់គ្រងមជ្ឈមណ្ឌល ដើម្បីឱ្យមជ្ឈមណ្ឌលនោះ ដំណើរការប្រកបដោយនិរន្តរភាព។

នេះជាការលើកឡើងរបស់ លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងឲ្យលោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ថ្លែងប្រាប់អ្នកសារព័ត៌មាននៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ នាយប់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៩ អំពីលទ្ធផលនៃទស្សនកិច្ច របស់គណប្រតិភូអន្តរក្រសួង នៅលើទឹកដីថៃ ពីថ្ងៃទី០២ ដល់ថ្ងៃទី០៦ ខែធ្នូ។

**លោក ញឹក វណ្ណារ៉ា មានលើកឡើងថា ដូចការគ្រោងទុកដំណើរទស្សនកិច្ចនេះ បានពិភាក្សាគ្នាលើចំណុច មួយចំនួនរួមមាន៖**

*ទី១ ៖ ការផ្លាស់ប្តូរព័ត៌មានពីជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណងធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

*ទី២ ៖ ការសម្របសម្រួលក្នុងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

*ទី៣ ៖ ការសម្របសម្រួលក្នុងកិច្ចខិតខំប្រឹងប្រែង ផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។

*ទី៤៖ ការតាមដានត្រួតពិនិត្យ និងការប៉ាន់ប្រមាណលទ្ធផល នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។ គួរបញ្ជាក់ថា កម្ពុជា និង ថៃ បានព្រមព្រៀងគ្នា ហើយថានឹង សាងសង់មជ្ឈមណ្ឌលសំចតមួយនៅប៉ោយប៉ែត ដែលនឹងចាប់ផ្តើមសាងសង់ នៅដើមឆ្នាំ២០២០នេះ សម្រាប់សង្គ្រោះ និងផ្តល់សេវាដល់ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលចំណាយថវិកា ប្រមាណជា១លានដុល្លារអាមេរិក ដែលជាជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលថៃ ដើម្បីជាចំណងដៃមិត្តភាព រវាងប្រទេសទាំងពីរ ។

លោក ញឹក វណ្ណារ៉ា បានបន្ថែមថា ការសម្រេចកសាងមជ្ឈមណ្ឌលសំចតទី១ និងជំបូងបង្អស់ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត នាពេលនេះ គឺបានបង្ហាញពីចំណុចចាប់ផ្តើមជាវិជ្ជមានរបស់កម្ពុជា-ថៃ លើការពង្រឹង និងគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និង សមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្នុងប្រទេសថៃ ដែលកម្ពុជា និងថៃបានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩។ លោកបន្តថា ការបង្កើតមជ្ឈមណ្ឌលសំចតជួយជនរងគ្រោះ នៅតាមព្រំដែនជាច្រើនកន្លែង នៅតាមច្រកព្រំដែន ពិតជាមាន

សារសំខាន់ណាស់ និងបានចូលរួម ចំណែក ការងារសង្គមកិច្ច ក្នុងការទទួលមើលខុសត្រូវលើជនងាយរងគ្រោះឲ្យកាន់តែប្រសើរ និងមានប្រសិទ្ធភាពជាងមុន ជាពិសេសជាការលើកមុខមាត់ រាជរដ្ឋាភិបាល និងប្រទេសកម្ពុជា។

បើតាមរបាយការណ៍ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ បានឲ្យដឹងថា គិតមកដល់ពេលនេះ នាយកដ្ឋានមួយនេះទទួលបានជនរងគ្រោះ ពីការធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានាសរុបចំនួន ១១៧នាក់ ក្នុងនោះស្ត្រី៥៧នាក់ ដែលជនរងគ្រោះទាំងនោះ មកពីប្រទេសម៉ាឡេស៊ីចំនួន ៤១នាក់ ឥណ្ឌូនេស៊ី ចំនួន ២០នាក់ ប្រទេសថៃចំនួន ៤៥នាក់ ប្រទេសចិនចំនួន ៤នាក់ ប្រទេសជប៉ុនចំនួន ៦នាក់ និងប្រទេសសិង្ហបុរីចំនួនម្នាក់៕

## ថៃបញ្ជូនពលរដ្ឋខ្មែរ២នាក់មកស្រុកកំណើតវិញបន្ទាប់ពីដោះលែងពីពន្ធនាគារ

http://www.rasmeinews.com/ December 8, 2019, 12:54 PM

ដោយបាយ័ន/ឧត្តរមានជ័យ:អាជ្ញាធរថៃបានបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន២នាក់ មកស្រុកកំណើតវិញបន្ទាប់ពីដោះលែងពីពន្ធនាគារពីបទឆ្លងដែនដោយខុសច្បាប់ចូលកាប់ឈើគ្រញូងក្នុងទឹកដីថៃ។ ករណីបញ្ជូនប្រជាពលរដ្ឋខ្មែរមកស្រុកកំណើតវិញនេះបានធ្វើឡើងកាលពីវេលាម៉ោង១៦និង៣០នាទី ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៩នេះ ស្ថិតនៅច្រកអន្តរជាតិជាំស្រងាំ ក្នុងទឹកដីស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ។

សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំស្រងាំ បាននិយាយថាប្រជាពលរដ្ឋខ្មែរចំនួន២នាក់ដែលត្រូវបានអាជ្ញាធរថៃបានបញ្ជូនមកស្រុកកំណើតវិញ គឺមានឈ្មោះ ហ៊ន ចាន់វិចិត្រភេទប្រុសអាយុ ៣០ ឆ្នាំរស់នៅភូមិត្រយ៉ង់ឃុំត្រយ៉ង់ស្រុកគូលែនខេត្តព្រះវិហារ។ម្នាក់ទៀតឈ្មោះយឹមសុខណៃភេទប្រុស អាយុ ២៨ ឆ្នាំរស់នៅភូមិចំការចេក ឃុំស្លែងស្ពាន ស្រុកស្រីស្នំ ខេត្តសៀមរាប។ សមត្ថកិច្ចបានបន្តថាអ្នកទាំងពីរចាប់ខ្លួនថ្ងៃទី១៨ខែកញ្ញាឆ្នាំ២០១៨កន្លងមកនេះពីបទឆ្លងដែនកាប់ឈើក្រញូង ដោយចូលតាមច្រកទឹកជប់ហើយត្រូវបានបញ្ជូនខ្លួនយកទៅដាក់ពន្ធនាគារនៅស្រុកខាន់តាឡាក់ ខេត្តស៊ីសាកេតប្រទេសថៃ ចាប់តាំងពីថ្ងៃនោះរហូតដល់ថ្ងៃទី០៧ ខែធ្នូនេះ ទើបដោះលែងហើយបញ្ជូនមកស្រុកកំណើតវិញ៕S/

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ពីភាគីថៃចំនួន ០៣នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration -GDI **December 6 - 2019**

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៥និង៤០នាទី ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០៣នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ផ្ទាំង ស៊ីម៉ង់ រលំសង្កត់ ពលករខ្មែរ ស្លាប់ ០១នាក់ និង របួស ធ្ងន់ ០១នាក់

https://www.facebook.com/LabourOfficial/ ពលករ 06-12-2019

06/12/19 ផ្ទាំងស៊ីម៉ង់រលំសង្កត់ពលករខ្មែរស្លាប់០១នាក់ និងរបួសធ្ងន់០១នាក់ ហេតុការណ៍គ្រោះថ្នាក់នេះកើតឡើងកាលពីវេលាម៉ោង០៩ព្រឹក ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ នៅក្នុងការដ្ឋានសាងសង់ផ្ទះមួយកន្លែងនៅម្តុំខាងក្រោយសណាមដែងស្ថិតក្នុងភូមិ៥ សង្កាត់បាងកែវ ស្រុកបាងភ្លី ខេត្តសាប្រាកាន ប្រទេសថៃ ។ ជនរងគ្រោះ ឈ្មោះ SITH MAO អាយុ ៣៦ឆ្នាំ ស្លាប់បាត់បង់ជីវិត នៅកន្លែងកើតហេតុ។ ជនរងគ្រោះ ឈ្មោះ HOEVRNG VUTH អាយុ ៣០ឆ្នាំ របួសត្រូវផ្ទាំងស៊ីម៉ង់សង្កត់ជើងទាំងសងខាង។ ក្រោយពេលកើតហេតុ ជនរងគ្រោះត្រូវបានសមត្ថកិច្ចបញ្ជូនយកទៅព្យាបាលនៅមន្ទីរពេទ្យខេត្តសាមុតប្រាកាន ចំណែកឯហេតុធ្វើឲ្យកើតគ្រោះថ្នាក់លើកនេះ សមត្ថកិច្ចថៃកំពុងធ្វើការស្រាវជ្រាវ ។

## ពលករខ្មែរ០៥នាក់ ធ្វើការនៅលើទូក នេសាទត្រី បានរួចផុតពីគ្រោះថ្នាក់ បន្ទាប់ពីលិចទូក នេសាទ

https://www.facebook.com/LabourOfficial/ 06-12-2019

ពលករខ្មែរ០៥នាក់ ធ្វើការនៅលើទូកនេសាទត្រី បានរួចផុតពីគ្រោះថ្នាក់បន្ទាប់ពីលិចទូកនេសាទត្រីដែលគាត់ធ្វើការនៅលើនោះបានលិចក្នុងនៅកណ្តាលសមុទ្រជាប់ព្រំប្រទល់ និងខេត្តឈុនបុរី ប្រទេសថៃ។ ហេតុការណ៍នេះបានកើតឡើងកាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ កន្លងទៅទូកនេសាទដែលរងគ្រោះនោះមានឈ្មោះទូកធូកថាក់ឡេថៃ 32 មានមនុស្សធ្វើការនៅលើទូកចំនួន០៦ នាក់ ក្នុងនោះមានពលករខ្មែរចំនួន០៥នាក់ និងជនជាតិថៃ០១នាក់៖

ឈ្មោះ ជន រងគ្រោះ

១.ឈ្មោះ Pondy,

២.ឈ្មោះ Yead Leab,

៣.ឈ្មោះ Rit Heng,

៤.ឈ្មោះ Ry Mit,

៥.ឈ្មោះ Ra Rann

ក្រោយពេលកើតហេតុ ជនរងគ្រោះត្រូវបានទូកនេសាទផ្សេងទៀត និងកម្លាំងអាជ្ញាធរនាវាជើងទឹក ប្រចាំស្រុកស៊ាប់តាហ៊ុប ខេត្តឈុនបុរី ធ្វើដំណើរទៅអន្តរាគមន៍ភ្លាមៗ នៅកន្លែងកើតប៉ុន្តែអ្នកបើកបរទូកនេសាទខាងលើ ជាជនជាតិថៃត្រូវបាត់ខ្លួននៅមិនទាន់រកឃើញនៅឡើយ ។ បច្ចុប្បន្នជនរងគ្រោះទាំងអស់ត្រូវនិយោជកមកទទួលយកទៅកន្លែងស្នាក់វិញ រួចរាល់អស់ហើយ ។

## ពលករខ្មែរ នៅប្រទេសថៃគ្រោះថ្នាក់បាត់បងជីវិតហើយមិនដឹងថាសាច់ញាតិគាត់នៅទីណា

https://www.facebook.com/LabourOfficial/ ពលករ 08-12-2019 រតនា ហ៊ន

សូមបងប្អូនក្នុងសង្គម Facabok មេត្តាជួយស៊ែររកសាច់ញាតរបស់គាត់ផងគាត់បានទៅធ្វើការចុះទូកនៅប្រទេសថៃអីឡូវបានគ្រោះថ្នាក់បាត់បងជីវិត ហើយមិនដឹងថាសាច់ញាតិគាត់នៅទីណាពិតប្រាកត់ទេតែតាមលីសម្តីគាត់កាលនៅរស់ថាគាត់រស់នៅខាង អាងកំពីងពួយ ភ្នំសំពៅ បាត់ដំបង ខាងថៅកែនៅថៃនឹងជួយលុយ១០ម៉ឺនបាតទៅដល់ឪពុកម្តាយរបស់គាត់ សូមបងប្អូនជួយស៊ែរយកតែបុណ្យផងចុះដើម្បីអោយឪពុកម្តាយគាត់បានដឹងផង បើបងប្អូនណាបានស្គាល់សាច់ញាតិគាត់ សូមខលមកលេខ 0979929525 សូមអរគុណបងប្អូនទុកជាមុនផង។

# ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៩

## គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តប៉ៃលិន ប្រជុំពិនិត្យ ពិភាក្សារបាយការណ៍ប្រចាំខែវិច្ឆិកា និងលើកទិសដៅការងារសម្រាប់ខែធ្នូ ឆ្នាំ២០១៩

https://www.information.gov.kh/ December 9, 2019 Hout CHEM អត្ថបទ លោក មួន ចរិយា

ប៉ៃលិន៖ព្រឹកថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តបានបើកកិច្ចប្រជុំពិនិត្យ ពិភាក្សារបាយការណ៍ប្រចាំខែវិច្ឆិកា និងលើកទិសដៅការងារបន្តសម្រាប់ខែធ្នូ ឆ្នាំ២០១៩ ដែលកិច្ចប្រជុំនេះស្ថិតក្រោមអធិបតីភាពលោកជំទាវ ជា លាភ អភិបាលរងខេត្តនិងមាន ការអញ្ជើញពីសមាជិកសមាជិកាគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តប៉ៃលិនផងដែរ។

បន្ទាប់ពីលោកស្រី គុំ ចាន់ធារី នាយករងរដ្ឋបាលខេត្តបានអានរបាការណ៍ប្រចាំខែវិច្ឆិការបស់គណកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តរួចមក លោកជំទាវ ជា លាភ អភិបាលរងខេត្តបានមានប្រសាសន៏ថា ក្នុងរយះពេល១ខែ គិតពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ គណៈកម្មាធិកា គ.ខ.ប.ជ បានអនុវត្តតាមផែនការដូច ដែលបានកំណត់ក្នុងការពង្រឹងនិរន្តរភាពការងារ សំដៅកាត់បន្ថយជាអប្បបរិមា នៃអត្រាគ្រោះថ្នាក់ដោយសារអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកចេញទៅក្រៅប្រទេសរបស់ប្រជាពលរដ្ឋខ្មែរដើម្បីស្វែងរកការងារធ្វើប្រថុយប្រថាន។ លោកជំទាវបានបន្តទៀតថា ទន្ទឹមនិងនេះ គ.ខ.ប.ជ បានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលដៃគូរ អភិវឌ្ឍន៏នានា ដែលបានមកបំពេញបេសកម្មនៅក្នុងដែនសមត្ថកិច្ចខេត្ត និងសហការជាប្រចាំជាមួយអាជ្ញាធរខេត្តចាន់បូរី ប្រទេសថៃបានល្អប្រសើរ បានទប់ស្កាត់នូវអំពើជួញដូមនុស្សទទួលបានជោគជ័យ។

លោកជំទាវបានផ្តាំផ្ញើរដល់ក្រុមការងារគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ត្រូវបន្តលើកកម្ពស់ការងារផ្សព្វផ្សាយច្បាប់ គោលនយោបាយ និងពង្រឹងការអប់រំតាមគ្រប់រូបភាព និងការប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកលអំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច កម្លាំងពលកម្ម ទំនាក់ទំនងរវាង ទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត។-ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករ ទៅធ្វើការនៅក្រៅ ប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់ រាជរដ្ឋាភិបាលឲ្យបានត្រឹម ត្រូវដើម្បីការពារសុវត្ថិភាព។- បន្តរៀបចំវិធានការគ្រប់គ្រងលំហូរពលករទេសន្តប្រវេសន៍ ការងារឆ្លង ដែនមិនប្រក្រតី។- ពង្រឹងប្រព័ន្ធយុត្តិ ធម៌ព្រហ្មទណ្ឌជាពិសេស ការពង្រឹងកិច្ចសហការ ក្នុងការជួយគ្នាទៅវិញទៅមកក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌជាមួយប្រទេសពាក់ព័ន្ធ។- បន្តអនុវត្ត និងចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល និង ការចុះតាមដានអនុវត្តគោល នយោបាយនៅថ្នាក់ក្រោមជាតិ។-ពង្រឹងសកម្មភាពទទួលពលករ ការស្រាវជ្រាវទិន្នន័យ និងផ្តល់សេវាជូនពលករដែលត្រូវបានបញ្ជូនត្រឡប់ពីអាជ្ញាធរបរទេស និងពលករវិលត្រឡប់វិញនៅតាមច្រកព្រំដែនសំខាន់ៗ៕

## លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយអង្គការដែនដីមនុស្សហូរដ៏ប្រចាំកម្ពុជា

https://www.facebook.com/deputygovernoryousophear/ លេខាធិការដ្ឋាន គខបជសៀមរាប 09-12-2019

នៅរសៀលថ្ងៃទីចន្ទ ទី០៩ ខែធ្នូ ឆ្នាំ២០១៩ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប ដឹកនាំដោយ លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយអង្គការដែនដីមនុស្សហូរដ៏ប្រចាំកម្ពុជាស្តីពីកិច្ចសហការរវាងអង្គការដែនដីមនុស្សហូរឡង់ដ៏ប្រចាំកម្ពុជា និងអង្គការដៃគូពាក់ព័ន្ធ ដែលបានសហការជាមួយអាជ្ញាធរខេត្តសៀមរាប ពិសេសកិច្ចសហការជាមួយគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ កិច្ចជំនួបនេះ ក៏មានការអញ្ជើញចូលរួមពីក្រុមការងារបច្ចេកទេស ដែលអញ្ជើញពីស្នងការនគរបាលខេត្ត មន្ទីរកិច្ចការនារីខេត្ត មន្ទីរសង្គមកិច្ចនិងអតីតយុទ្ធជននិងយុវនីតិសម្បទាខេត្ត មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។

នៅក្នុងជំនួបនេះ លោកស្រីប្រធានលេខាធិការដ្ឋានបាន ជម្រាបជូនអំពីដំណើរការរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងកិច្ចសហការជាមួយបណ្តាមន្ទីរ អង្គភាព និងគ្រប់អ្នកពាក់ព័ន្ធពិសេសជាមួយអង្គការដៃគូដែលទទួលបានថវិកាពីអង្គការដែនដីមនុស្សហូឡង់ដ៏ ដូចជាគម្រោង WHACH CAMBODIA អង្គការ សកម្មភាពដើម្បីកុមារ (APLE) និងអង្គការដៃគូជាច្រើនទៀត ដែលបានផ្តល់សេវាជួយជនរងគ្រោះទាំងផ្នែកច្បាប់ ផ្នែកសង្គមកិច្ច និងការអន្តរាគមន៍លើករណី ដូចជាករណីរំលោភបំពានទៅលើកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ឬ អំពើជួញដូរមនុស្ស ឬ អំពើហិង្សាទាក់ទងនឹងយេនឌ័រ។

បន្ថែមពីនេះ លោកស្រីប្រធានបានថ្លែងអំណរគុណចំពោះអង្គការដែនដីមនុស្សហូរឡង់ដ៏ដែលបានចុះកិច្ចព្រមព្រៀងជាមួយគណៈកម្មាធិការជាតិប្រយុទ្ធអំពើជួញដូរមនុស្ស និងតែងតែបានសហការជាមួយលេខាធិការដ្ឋាន គ.ឧ.ប.ជ ខេត្តសៀមរាប និងសូមឲ្យកិច្ចសហការនេះ នៅតែបន្តយ៉ាងស្អិតរមួតបន្ថែមទៀតជាមួយលេខាធិការដ្ឋាន ឬក្រុមការងារបច្ចេកទេសរបស់លេខាធិការដ្ឋាន និងមន្ទីរអង្គភាពជំនាញនានាក្នុងខេត្ត ដើម្បីពង្រឹងលើកិច្ចសហការ ក្នុងបង្ការ ការពារ សង្គ្រោះ បង្ក្រាប និងផ្តន្ទាទោស។ មួយវិញទៀត លោកស្រីប្រធាន បានស្នើឲ្យអង្គការពិនិត្យ និងពង្រីកគោលដៅបន្ថែមទៀតឲ្យបានច្រើន នៅក្នុងខេត្តសៀមរាបផងដែរ។

## ឧទ្ធរណ៍ជម្រះក្តីលើសំណុំរឿង នាំស្ត្រីខ្មែរទៅរៀបការប្តីចិននៅចិន

https://www.postkhmer.com/ គឹម សារុំ | Publication date 10 December 2019 | 09:36 ICT

**ភ្នំពេញ៖** នៅពេលដែលសាលាឧទ្ធរណ៍កំពុងបើកសវនាការនៅក្នុងបន្ទប់ជំនុំជម្រះកាលពីម្សិលមិញលើសំណុំរឿងនាំស្ត្រីខ្មែរទៅការប្តីនៅចិននៅក្នុងអំឡុងឆ្នាំ ២០១៦ នោះ ស្ត្រីដែលជាជនជាប់ចោទ ២ នាក់បានសុំអង្វរដល់ចៅក្រមឲ្យបន្ថយទោសដល់ពួកគេ។ ជនជាប់ចោទទាំង ២ នាក់ ឈ្មោះ សាន ខា អាយុ ៥៣ ឆ្នាំ និង ស្រ៊ន ស៊ីនឿន អាយុ ៥៣ ឆ្នាំ។

ស្ត្រីជាប់ចោទទាំង ២ នាក់ បានថ្លែងទៅកាន់ចៅក្រមក្នុងពេលជំនុំជម្រះថា៖ «ពួកខ្ញុំគ្រាន់តែនាំស្ត្រីរងគ្រោះឲ្យជួបគេនៅភ្នំពេញទេ ប៉ុន្តែខ្ញុំសុំទទួលខុស ហើយសូមតុលាការបន្ថយទោសដល់ពួកខ្ញុំផង»។ ស្ត្រីជាប់ចោទទាំង ២ នាក់ថា សំណុំរឿងនេះត្រូវសាលាដំបូងខេត្តក្រចេះ ប្រកាសសាលក្រមនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៨ ផ្តន្ទាទោសពួកគេម្នាក់ៗឲ្យជាប់ពន្ធនាគារ ៨ ឆ្នាំចោទពីបទលក់ដូរមនុស្សសម្រាប់ឆ្លងដែនតាមមាត្រា ២០ និងមាត្រា ១៩ ច្បាប់ជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងរួមគ្នាសងទៅស្ត្រីរងគ្រោះម្នាក់ៗ ៤ លានរៀល។

លោក ប៉ែត សារ៉ាត តំណាងមហាអយ្យការសន្និដ្ឋានថា តាមអង្គហេតុ និង ចម្លើយសារភាពរបស់ស្ត្រីជាប់ចោទទាំង ២ នាក់ និងចម្លើយរបស់ស្ត្រីរងគ្រោះទាំង ២ នាក់បង្ហាញថា ជនជាប់ចោទពិតជាប្រព្រឹត្តបទល្មើសមែន។ លោកថ្លែងថា៖ «សុំឲ្យក្រុមប្រឹក្សាពិចារណាតាមច្បាប់»។

លោកមេធាវីការពារសិទ្ធិជនជាប់ចោទទាំង ២ បានសន្និដ្ឋានថា ជនជាប់ចោទដែលជាកូនក្តីរបស់លោកក៏ជាជនរងគ្រោះដែរព្រោះគាត់គ្រាន់តែនាំស្ត្រីរងគ្រោះទៅឲ្យមនុស្សម្នាក់ទៀត ដូច្នេះគាត់មិនពាក់ព័ន្ធនឹងការនាំស្ត្រីរងគ្រោះទៅប្រទេសចិនទេ។ លោកមេធាវី ទាំង ២ នាក់ បានថ្លែងទៅកាន់អង្គជំនុំជម្រះដោយសូមឲ្យតុលាការបន្ថយទោសដល់កូនក្តីរបស់លោកទាំង ២ នាក់ផងដែរ។ លោក ចៅក្រម សេង ស៊ីវត្ថា ប្រធានក្រុមប្រឹក្សាជំនុំជម្រះថ្លែងថា សាលដីកានេះប្រកាសនៅថ្ងៃទី ១៩ ខែធ្នូ៕

## បើកយុទ្ធនាការ ១៦ថ្ងៃ បំពាក់បូពណ៌ស៖ រួមគិត រួមធ្វើ រួមដោះស្រាយ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី

http://www.rasmeinews.com/ December 10, 2019, 5:57 PM **ដោយ៖ ទេព មង្គល-គន្ធា**

**ភ្នំពេញ៖** លោកស្រី ហ៊ូ សាមិត្ត រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី បានចូលរួមបើកយុទ្ធនាការ ១៦ ថ្ងៃបំពាក់បូពណ៌ស ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និង ក្មេងស្រី កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩ កន្លងទៅថ្មីៗនេះ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលព្រឹត្តិការណ៍មួយនេះ ប្រព្រឹត្តទៅ ក្រោមប្រធានបទ ″ រួមគិត រួមធ្វើ រួមដោះស្រាយ ដើម្បីបញ្ឈប់អំពើហិង្សា លើស្ត្រី និងក្មេងស្រី ″ ។

បន្ទាប់ពីអរគុណចំពោះ ក្រុមការងារទប់ស្កាត់អំពើហិង្សា ទាក់ទងនឹងយេនឌ័ររបស់ ក្រសួងកិច្ចការនារី និងអង្គការដៃគូ របស់ក្រសួងកិច្ចការនារី រួមមាន អង្គការ UNFPAUN Women និងកម្មវិធី ACCESS ដែលបានជួយគាំទ្រកម្ម

វិធីនេះ លោកស្រី ហ៊ូ សាមិត្ត បានឱ្យដឹងថា ការរៀបចំកម្មវិធីយុទ្ធនាការ ១៦ ថ្ងៃ បំពាក់បូពណ៌ស ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី សម្រាប់ឆ្នាំ២០១៩ នាពេលនេះ ក្នុងគោលបំណងបង្កើនការ យល់ដឹងរបស់មន្ត្រី នៃក្រសួងកិច្ចការនារីទាំងអស់ អំពីអត្ថន័យ និងខ្លឹមសារ នៃយុទ្ធនាការ ១៦ ថ្ងៃ បំពាក់បូពណ៌ស ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ដូចនេះយើងទាំងអស់គ្នា ត្រូវតែ រួមគិតរួមធ្វើ រួមដោះស្រាយ ដើម្បីបញ្ឈប់អំពើហិង្សា លើស្ត្រី និងក្មេងស្រី ដោយយកអស់កម្លាំងកាយចិត្ត រួមទាំងឆន្ទៈមោះមុត ធ្វើយ៉ាងណាឱ្យស្ត្រី និងក្មេងស្រី រួចផុតពីអំពើហិង្សា ហើយមានឱកាសចូលរួម ក្នុងគ្រប់សកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជាតិ ដូចបុរស និងក្មេងប្រុសដែរ។

លោកស្រី បានបន្តថា ជារៀងរាល់ឆ្នាំ ក្រសួងកិច្ចការនារី តែងតែសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការដៃគូជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីប្រារព្ធពិធីនេះឡើង ក្នុងគោលបំណងរំលឹកឡើងវិញ ពីវីរភាពរបស់ក្រុមបុរសជនជាតិកាណាដាមួយក្រុម ដែលបានចាប់ផ្តើមឡើង តាំងពីឆ្នាំ ១៩៩១ រហូតដល់ទិវានេះ បានត្រូវបានអង្គការសហប្រជាជាតិ ទទួលស្គាល់ និងបានចាត់ទុក ជាទិវាអន្តរជាតិ ក្នុងការធ្វើយុទ្ធនាការ លុបបំបាត់រាល់ទម្រង់ នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ជារៀងរាល់ឆ្នាំ ចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ដល់ថ្ងៃទី១០ ខែធ្នូ នៅទូទាំងពិភពលោក តែងតែរៀបចំ យុទ្ធនាការនេះ ហើយគេបានចាត់ទុកថា អំឡុងពេលនេះ គឺជាទិវានៃស្មារតីសាមគ្គីភាព របស់បុរសប្រឆាំងនឹងអំពើហិង្សា របស់បុរស ទៅលើស្ត្រី ហើយបានកំណត់ ការបំពាក់បូពណ៌ស ដែលជាសញ្ញា នៃការសន្យារបស់ពួកគេ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។

លោកស្រី បានបន្តទៀតថា យើងទាំងអស់គ្នា ពិតជាបានដឹងហើយថា អំពើហិង្សា នៅក្នុងគ្រួសារ និងការរំលោភបំពានផ្លូវភេទ លើស្ត្រី និងក្មេងស្រី នៅតែបន្តកើតមានលើស្ត្រី និងក្មេងស្រី ក្នុងប្រទេសកម្ពុជា និងនៅលើពិភពលោកទាំងមូល ហើយអំពើហិង្សាទាំងនេះ កើតមានឡើងគ្រប់រូបភាព ដែលស្ត្រី និងក្មេងស្រី នៅតែបន្តជាកម្មវត្ថុ នៃអំពើហិង្សាលើរូបរាងកាយ ផ្លូវចិត្ត ផ្លូវភេទ និងនៅក្នុងជីវភាពរស់នៅ ប្រចាំថ្ងៃ។ ស្ត្រីប្រឈមមុខនឹងឧបសគ្គជាច្រើន ក្នុងការទទួលបាននូវ សិទ្ធិមនុស្ស កិច្ចការពារ និងយុត្តិធម៌ ហើយស្ត្រីក៏តែងតែទទួលរង នូវហានិភ័យ នៃអំពើហិង្សាថែមទៀតដែរ។ បញ្ហានេះ រួមបញ្ចូលទាំងស្ត្រីពិការ ស្ត្រីចាស់ជរា ស្ត្រីស្រឡាញ់ ភេទដូចគ្នា ស្ត្រីជនជាតិដើមភាគតិច ស្ត្រីបម្រើសេវាផ្លូវភេទ ស្ត្រីបម្រើការងារ នៅកន្លែងកំសាន្ត កម្មការិនីរោងចក្រ និងនិយោជិត ជាស្ត្រីផ្សេងៗទៀត។ រាល់ទម្រង់ទាំងឡាយ នៃអំពើហិង្សាលើស្ត្រី កើតឡើងដោយកត្តាគួបផ្សំផ្សេងៗ ទាក់ទងនឹងកម្រិតបុគ្គល សម្ព័ន្ធភាពសហគមន៍ និងឋានៈក្នុងសង្គម ហើយមិនអាចក្រសួង ស្ថាប័នណាមួយ ទទួលបន្ទុកដោះស្រាយ តែឯងបានឡើយ គឺទាមទារឱ្យមានការចូលរួម ពីគ្រប់អ្នកពាក់ព័ន្ធ ទាំងក្រសួង ស្ថាប័នរដ្ឋ អង្គការដៃគូជាតិ អន្តរជាតិ និងផ្នែកឯកជន ព្រមទាំងសហគមន៍ ក្រុមគ្រួសារ និងជនរងគ្រោះខ្លួនឯងផងដែរ ហេតុ ដូច្នេះ ទើបឆ្នាំនេះក្រសួងកិច្ចការនារី សម្រេចជ្រើសរើសយកប្រធានបទ " រួមគិត រួមធ្វើ រួមដោះស្រាយ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី" សម្រាប់យុទ្ធនាការ ១៦ថ្ងៃ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី " នៅឆ្នាំ២០១៩ នេះ ក្នុងគោលបំណងគៀរគរយើងទាំងអស់គ្នាចូលរួមរិះរកយុទ្ធសាស្ត្រ ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។

លោកស្រី បានបញ្ជាក់ថា ការចូលរួមធ្វើ គឺសំដៅការចូលរួមអប់រំផ្សព្វផ្សាយ ឱ្យបានទូលំទូលាយ ដល់ប្រជាពលរដ្ឋ មិនត្រូវប្រព្រឹត្តអំពើហិង្សា លើនរណាម្នាក់ឡើយ ទោះបីអ្នកនោះជាបងប្អូន កូនចៅ ប្រពន្ធប្តី ជាសាច់ញាតិ ឬអ្នកដទៃក៏ដោយ ពីព្រោះការប្រព្រឹត្តអំពើហិង្សា គឺជាអំពើខុសច្បាប់ ហើយរំលោភបំពាន សិទ្ធិមនុស្ស ដែលមានផលប៉ះពាល់ លើជីវិតរបស់ជនរងគ្រោះ។ យើងទាំងអស់គ្នា ត្រូវចូលរួមអនុវត្តសកម្មភាព ឬកិច្ចអន្តរាគមន៍ ក្នុងការផ្តល់សេវាជូន ជនរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការសម្របសម្រួលបញ្ជូនជនរងគ្រោះ ទៅសេវាពាក់ព័ន្ធឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ។ លោកស្រី បានមានជឿជាក់ថា សមិទ្ធផលដែលសម្រេចបាន បន្ទាប់ពីសកម្មភាពយុទ្ធនាការបូពណ៌ស ១៦ថ្ងៃ នាពេលនេះ នឹងជាវិភាគទានមួយ ដ៏មានតម្លៃ ប្រកបដោយវិសាលភាព ក្នុងការចូលរួមកាត់បន្ថយ អំពើហិង្សា ទាក់ទងនឹងយេនឌ័រ ដែលជាការឆ្លើយតប ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

របស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការយុទ្ធសាស្ត្រនារីរតនៈ របស់ក្រសួងកិច្ចការនារី ដែលជំរុញឱ្យមានសមភាព និងសមធម៌យេនឌ័រ នៅក្នុងសង្គម ប្រកបដោយបរិយាបន្ន ព្រមទាំងធ្វើឱ្យប្រសើរឡើង នូវទំនាក់ទំនងយេនឌ័រ ដើម្បីកាត់បន្ថយរាល់ទម្រង់ អំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ជាពិសេស សមិទ្ធផលនេះ រាជរដ្ឋាភិបាលកម្ពុជា ពិតជាបានរួមចំណែកអនុវត្តការប្តេជ្ញាចិត្ត នាពេលថ្មីៗនេះ នៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា ជាមួយតំណាងប្រទេស ចំនួន១៧០ ក្នុងការសម្រេចឱ្យបានដល់ចំណុចសូន្យ នៃការបញ្ឈប់អំពើហិង្សា លើស្ត្រី នៅឆ្នាំ២០៣០៕v

## អាមេរិក នាំគ្នាផ្អើល ដោយសារបណ្តាញសង្គមថា មានករណីចាប់ស្រី ទៅរំលោភ និងវះយកអាន្ត ភាយលក់

https://www.dap-news.com/ ByPH104 Posted on December 9, 2019

បរទេស: CNNចេញផ្សាយកាល ពីសប្តាហ៍មុននេះ បានចុះផ្សាយដ៏ គួរឲ្យចាប់អារម្មណ៍មួយថា បច្ចុប្បន្នកំពុងមានពាក្យចចាមអារាមដ៏ គួរឱ្យភ័យខ្លាចមួយ ដែលដំបូងឡើង ត្រូវបានបង្កើតឡើង នៅលើបណ្តាញ សង្គមយក្សហ្វេសប៊ុក ដែលវាកំពុងបានធ្វើឱ្យមាន ការភ័យខ្លាចកាន់តែខ្លាំងឡើងថា មានករណីបុរសបើកបររថយន្ត ដឹកទំនិញពណ៌ស កំពុងចាប់ជំរិតស្ត្រី នៅទូទាំងប្រទេស អាមេរិក ទៅរំលោភផ្លូវភេទ និងកាត់យកផ្នែកខ្លះ នៃរាង្គកាយរបស់ពួកគេទៅលក់ទៀតផង។

ទោះបី ជាយ៉ាងណាក្តី ខណៈ ដែលមិនមានភស្តុតាង ដើម្បីបង្ហាញថា រឿងនេះថាជារឿងពិតមែននោះ និងមិនទាន់មានសកម្មភាព សម្របសម្រួលថ្នាក់ជាតិណាមួយ ដើម្បីធ្វើការបញ្ជាក់នោះ ប៉ុន្តែនៅលើបណ្តាញសង្គមហ្វេសប៊ុកវិញមានគណនេយ្យមួយចំនួន បានបង្កើតព័ត៌មានបន្ថែម ហើយវាបានបណ្តាល ឱ្យអភិបាលក្រុងធំមួយ របស់អាមេរិកចេញការព្រមាន ដោយផ្អែកទៅលើការអះអាង ទាំងនោះទៅវិញ។

គួរឲ្យកត់ សំគាល់នោះ គឺការភ័យស្លន់ស្លោ ដែលបានបង្កើត ដោយប្រព័ន្ធអ៊ីនធ័រណេត ចុងក្រោយនេះគឺ បានបង្ហាញគ្រប់គ្នា បានមើលឃើញពីរបៀប ដែលការបង្ហោះតាមហ្វេសប៊ុក អាចក្លាយទៅជាមេរោគ និងអាចបង្កភាពវង្វេងស្មារតី និងធ្វើឱ្យមនុស្សជឿ តាមរយៈតែការក្រឡេកមើលអ្វីមួយ ដូចជាករណីរថយន្តដឹកទំនិញពណ៌ស នេះជាដើមតែវាបានក្លាយទៅជាការសង្ស័យ និងព្រួយបារម្ភព្រមទាំងបានផ្សារភ្ជាប់ ទៅនឹងឡានដឹកទំនិញពណ៌ស នៅទូទាំងប្រទេសទៅវិញ៕ ប្រែសម្រួលៈស៊ុនលី

## ពលរដ្ឋវៀតណាម ច្រើនជាង ១៣២.000នាក់ ទៅធ្វើពលករ ក្រៅប្រទេស នៅឆ្នាំ២០១៩

https://www.dap-news.com/ ByTR110 Posted on December 10, 2019

**ហាណូយ៖** ប្រជាជនវៀតណាម ច្រើនជាង ១៣២.៨០០នាក់ បានទៅធ្វើការ នៅក្រៅប្រទេស ក្នុងកំឡុងរយៈពេល ១១ខែ ឆ្នាំ២០១៩ នេះ លើសពីគោលដៅ ដែលបានគ្រោងទុក ក្នុងឆ្នាំនេះចំនួន ១២០.០០០ នាក់។ នេះបើយោងតាម តួលេខពីសមាគម ផ្គត់ផ្គង់កម្លាំង ពលកម្មវៀតណាម (VAMAS)។

យោងតាមសារព័ត៌មាន Vietnam News ចេញផ្សាយនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ បានឱ្យដឹងថា គ្រាន់តែក្នុងខែវិច្ឆិកាតែមួយ ជនជាតិវៀតណាម ជិត ១៤.៨០០ នាក់បានទៅធ្វើការ នៅក្រៅប្រទេស គឺកើនឡើងជិត ២,៦ ភាគរយ បើប្រៀបធៀបនឹង រយៈពេលដូចគ្នា កាលពីឆ្នាំមុន។

ប្រទេសជប៉ុន កូរ៉េខាងត្បូង និងកោះតៃវ៉ាន់ មានចំនួន ៩៦,៩ ភាគរយ នៃទីផ្សារនាំចេញកម្លាំងពលកម្ម របស់ប្រទេសវៀតណាម ដែលមានកម្មករចំនួន ១២៨.៦៨៥ នាក់។ ចំនួនពលករទៅជប៉ុន បានកើនឡើង ១៦,៦៤ ភាគរយ បើប្រៀបធៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំមុន។ ចាប់តាំងពីដើមឆ្នាំមក កូរ៉េខាងត្បូង បានទទួលពលករ វៀត

ណាមចំនួន ៦៣២នាក់ ជារៀងរាល់ខែ។ ទន្ទឹមនឹងនេះដែរ ចំនួនពលករទៅប្រទេស អាស៊ីអាគ្នេយ៍ ដូចជាម៉ាឡេស៊ី សិង្ហបុរី ហ្វីលីពីន ថៃនិងកម្ពុជា មានចំនួនត្រឹមតែ ៥៨៤នាក់ប៉ុណ្ណោះ គឺបានធ្លាក់ចុះ ៤៦,៧២ ភាគរយ។ ពលករធ្វើការនៅមជ្ឈឹមបូព៌ា មានចំនួនតែ ១ ភាគរយនៃចំនួនសរុប៕ ប្រែសម្រួលៈ ណៃ តុលា

## ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០១៩

## សម្តេច ស ខេង៖ បច្ចុប្បន្នប្រព័ន្ធ អនឡាញ បង្កើតបញ្ហាថ្មីៗ នាំឲ្យទៅរកការ ជួញដូរមនុស្ស និង រំលោភបំពានផ្លូវភេទ

https://www.dap-news.com/ ByPH104 Posted on December 12, 2019

ភ្នំពេញ ៖ ការប្រើប្រាស់ប្រព័ន្ធអនឡាញ ដែលកំពុងពេញនិយម នាពេលបច្ចុប្បន្ន បានធ្វើឲ្យឧក្រិដ្ឋជន ឆ្លៀតឱកាស ប្រើប្រាស់ទាក់ទាញ ជនរងគ្រោះ ឲ្យចូលក្នុងអន្ទាក់របស់ខ្លួន និងគេចវេសពីសមត្ថកិច្ច ហើយឈានទៅបង្កើតជាបញ្ហាថ្មីៗ ដូចជាការជួញដូរមនុស្ស និងការរំលោភបំពាន ផ្លូវភេទជាដើម ។ នេះបើតាមប្រសាសន៍ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងទិវាជាតិប្រឆាំងការ ជួញដូរមនុស្ស១២ធ្នូ នារសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩ សម្តេច ស ខេង បានឲ្យដឹងថា អំពើជួញដូរមនុស្ស ជាប្រភេទឧក្រិដ្ឋកម្មឆ្លងដែន ប្រកបដោយគ្រោះថ្នាក់ចំពោះមនុស្ស ជាពិសេសគ្រោះថ្នាក់ជាញឹកញាប់ត្រូវបានរកឃើញ ក្នុងចំណោមអ្នកធ្វើចំណាកស្រុក ឬទេសន្តរប្រវេសន៍។ សម្តេចថា រៀងរាល់ឆ្នាំមនុស្សរាប់លាននាក់ ត្រូវបានបំផ្លាញដោយឧក្រិដ្ឋជន ពីការជួញដូរមនុស្ស នៅគ្រប់ទីកន្លែងក្នុងពិភពលោក ។ សម្តេចរៀបរាប់ថា ជនល្មើសបានរកគ្រប់ល្បិចកលដ៏ស្មោគគ្រោក ពង្រាយបណ្តាញធ្វើសកម្មភាពកេងប្រវ័ញ្ចជនរងគ្រោះ នៅគ្រប់ដំណាក់កាល ទាំងដោយផ្ទាល់ និងប្រយោល តាមរយៈបណ្តាញទំនាក់ទំនងអនឡាញ (Online) ឬតាមបច្ចេកវិទ្យាទំនើប ដែលប្រជាពលរដ្ឋ ជាពិសេស យុវវ័យ កុមារ និងមនុស្សពេញវ័យនិយមប្រើប្រាស់ គឺទូរស័ព្ទដៃ និងប្រព័ន្ធអ៊ិនធឺណេត។ សម្តេចមានប្រសាសន៍ថា "ទំនោរនៃការប្រើប្រាស់ ប្រព័ន្ធបច្ចេកវិទ្យាទំនើបនេះ បានធ្វើឲ្យឧក្រិដ្ឋជនបានឆ្លៀត ឱកាសប្រើប្រាស់បច្ចេកវិទ្យា ទំនើបនេះ ដើម្បីទាក់ទាញជនរងគ្រោះឲ្យចូលក្នុងអន្ទាក់របស់ខ្លួន និងគេចវេសពីសមត្ថកិច្ច ដែលបច្ចុប្បន្ននេះ ប្រព័ន្ធអនឡាញ និងបណ្តាញផ្សព្វផ្សាយ សង្គមក៏បានបង្កើតជាបញ្ហាថ្មី គឺការជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ ជាពិសេស លើអនីតិជនតាមប្រព័ន្ធអនឡាញ" ។

បន្ថែមពីនេះ រដ្ឋមន្ត្រីមហាផ្ទៃ លើកឡើងថា ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាល នាពេលកន្លងមក ក៏នៅមានសេសសល់បញ្ហាមួយចំនួន ដូចជា ៖ ភាពប្រឈមក្នុងការដោះស្រាយ ភាពរងគ្រោះរបស់ពលករមួយចំនួន ដែលនៅតែមិនទាន់មានឯកសារច្បាប់ត្រឹមត្រូវ ។ កុមារដែលបានកើត និងរស់នៅក្នុងប្រទេសគោលដៅ មិនទាន់មានឯកសារបញ្ជាក់អត្តសញ្ញាណ សញ្ជាតិកំណើតរបស់ទារក នៅតែមានការនាំមនុស្សឆ្លងដែនដោយប្រើវិធីផ្សេងៗបន្លំភ្នែកសមត្ថកិច្ច ។ ទន្ទឹមនឹងនេះដែរ រដ្ឋមន្ត្រីមហាផ្ទៃ ក៏បានអំពាវនាវ ភាគីប្រទេសគោលដៅ ពាក់ព័ន្ធចូលរួមពង្រឹងកិច្ចសហការ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្ទៀងផ្ទាត់ និងផ្តល់ឯកសារត្រឹមត្រូវឲ្យពលករកម្ពុជា ដែលមានឯកសារផុតសុពលភាព ជៀសវាងការប្រើប្រាស់ឯកសារ អ្នកដទៃ ដែលខុសអត្តសញ្ញាណ និងការចេញឯកសារជា ឯកតោភាគីដោយខ្វះព័ត៌មាន អំពីអត្តសញ្ញាណពិត និងខ្វះការត្រួតពិនិត្យពី សមត្ថកិច្ចប្រទេសដើម ។ ដោយ ៖ អេង ប៊ូឆេង

# អំពើជួញដូរមនុស្ស ជាបទល្មើសឧក្រិដ្ឋកម្មឆ្លងដែន, កម្ពុជាប្តេជ្ញាបន្តប្រយុទ្ធប្រឆាំងការពារ និងលើកកម្ពស់សុវត្ថិភាពមនុស្ស

http://www.cen.com.kh/archives/ December 13, 2019

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានមានប្រសាសន៍ថា អំពើជួញដូរមនុស្ស ជាប្រភេទឧក្រិដ្ឋកម្មឆ្លងដែន ដែលមានគ្រោះថ្នាក់ចំពោះមនុស្សគ្រប់វ័យ-ភេទក្នុងសង្គម ហើយគ្រោះថ្នាក់ជាញឹកញាប់ ត្រូវបានរកឃើញក្នុងចំណោមអ្នកធ្វើចំណាកស្រុក ឬទេសន្តរប្រវេសន៍ ដែលស្វែងរកការងារ និងប្រាក់ចំណូល នៅទីឆ្ងាយដែលខ្លួនរស់នៅ ។ ក្នុងឱកាសអញ្ជើញជាអធិបតីប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី១៣ នៅរសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩នេះ សម្តេចក្រឡាហោម ស ខេង មានប្រសាសន៍ថា ជារៀងរាល់ឆ្នាំមនុស្សរាប់សែន រាប់លាននាក់ ត្រូវបានបំផ្លាញដោយឧក្រិដ្ឋជនជួញដូរមនុស្ស នៅគ្រប់ទីកន្លែងក្នុងពិភពលោក ។

សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី បានអះអាងទៀតថា នៅពេលនេះជនល្មើសបានរកគ្រប់ល្បិចកលដ៏ស្មោគគ្រោក ពង្រាយបណ្តាញធ្វើសកម្មភាពកេងប្រវ័ញ្ចជនរងគ្រោះនៅគ្រប់ដំណាក់កាល ទាំងដោយផ្ទាល់ និងប្រយោលតាមរយៈបណ្តាញទំនាក់ទំនងអនឡាញ ឬតាមបច្ចេកវិទ្យាទំនើបដែលប្រជាពលរដ្ឋ ជាពិសេសយុវវ័យ កុមារ និងមនុស្សពេញវ័យនិយមប្រើប្រាស់ គឺទូរស័ព្ទដៃ និងប្រព័ន្ធអ៊ិនធើណេត។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា សម្តេចក្រឡាហោម ស ខេង បានគូសបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តបន្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងគោលដៅការពារ និងលើកកម្ពស់សុវត្ថិភាពរបស់មនុស្សគ្រប់រូប និងសន្តិសុខសង្គម ក៏ដូចជាលើកកម្ពស់ការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ និងផលប្រយោជន៍របស់មនុស្សគ្រប់រូប ដែលត្រូវបានបំផ្លាញដោយជនល្មើសនៃអំពើជួញដូរមនុស្ស។ សម្តេចក្រឡាហោម ស ខេង បានសង្កត់ធ្ងន់ថា បេសកកម្មរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺត្រូវតែបន្តធ្វើឲ្យកាន់តែសកម្ម អនុវត្តនូវវិធានការច្បាប់ឲ្យកាន់តែងម៉ឺងម៉ាត់ និងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់ឆ្នាំ២០១៩-២០២៣ ឲ្យបានសម្រេចតាមគោលដៅគ្រោងទុក ។ រាជរដ្ឋាភិបាលត្រូវការការចូលរួមពីក្រសួង ស្ថាប័នជាសមាជិក ក៏ដូចជាដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងកិច្ចសហការល្អជាមួយប្រទេសពាក់ព័ន្ធ នៅក្នុងតំបន់ និងក្នុងពិភពលោក ។

សម្តេចក្រឡាហោម ស ខេង បានថ្លែងថា កម្ពុជាបាននិងកំពុងខិតខំជំរុញ អនុវត្តគោលការណ៍ទាំងឡាយដែលមានចែងក្នុងកតិកាសញ្ញាពិភពលោក «ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់» ដែលហៅកាត់ថា GCM និងជំរុញបន្ថែមទៀតនូវការអនុវត្តអនុសញ្ញាអន្តរជាតិ «ស្តីពីការប្រឆាំង ឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង» និងពិធីសារបន្ថែម «ស្តីពីការដាក់ទោសទណ្ឌអំពើជួញដូរមនុស្ស» អនុញ្ញាអាស៊ាន និងផែនការសកម្មភាពស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស-អនុស្សរណៈ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ដែលកម្ពុជាជាហត្ថលេខី និងច្បាប់ជាតិ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឲ្យម៉ឺងម៉ាត់ ៕ បញ្ញាស័ក្តិ

# រាជរដ្ឋាភិបាលប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ឲ្យបានលទ្ធផលជាអតិបរមា

http://bayontv.com.kh/ 12/12/2019

ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គជបជ) បានថ្លែងថា រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការបន្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងគោលដៅការ ពារ និងលើកកម្ពស់សុវត្ថិភាពមនុស្សឲ្យបានល្អប្រសើរជាអតិបរមា ខណៈការជួញដូរមនុស្ស នេះនៅតែជាបញ្ហាក្តៅគគុករបស់រាជរដ្ឋាភិបាល ក៏ដូចជាបណ្តាប្រទេស

នៅលើពិភពលោកនោះ។ ថ្លែងនៅក្នុងឱកាសអញ្ជើញជាអធិបតីក្នុងទិវាជាតិប្រឆាំងការជួញដូរមនុស្ស១២ធ្នូ លើកទី១៣ ឆ្នាំ២០១៩ ក្រោមប្រធានបទ «រួមសហការគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស » ដោយមានការចូលរួមពីថ្នាក់ដឹកនាំគ្រប់ស្ថាប័នព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល តំណាងអង្គទូត ស្ថានតំណាងនានាដែលមាននិវេសនដ្ឋាននៅកម្ពុជាភ្ញៀវជាតិ អន្តរជាតិ មន្ត្រីរាជការ កងកម្លាំង ប្រដាប់អាវុធ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស សហភាពសហព័ន្ធយុវជនកម្ពុជា ក្រុមយុវជន កាយរឹទ្ធិ និងយុវជនកាកបាទក្រហមកម្ពុជា និយោជក កម្មករ កម្មការិនី និងប្រជាពលរដ្ឋសរុបប្រមាណ៣,៥៥០នាក់នារសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩នេះនៅសាលមហោស្រពកោះពេជ្យ សម្តេចក្រឡាហោម ស ខេង បានលើកឡើងថា បញ្ហាការជួញដូរមនុស្សនេះនៅតែជាបញ្ហា ស្មុគស្មាញដែលត្រូវរួមគ្នាបង្ការនិងដោះស្រាយ។

សម្តេច បានបន្តថា «រាជរដ្ឋាភិបាលបញ្ជាក់សារជាថ្មី នូវការប្តេជ្ញាចិត្តបន្តប្រយុទ្ធប្រឆាំងអំ ពើជួញដូរមនុស្សក្នុងគោលដៅការពារ និងលើកកម្ពស់ សុវត្ថិភាពរបស់មនុស្សគ្រប់រូប និង សន្តិសុខសង្គម ក៏ដូចជាលើកកម្ពស់ការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរនិងផលប្រយោជន៍របស់មនុស្សគ្រប់ភេទគ្រប់វ័យ ដែលត្រូវបានបំផ្លាញដោយជនល្មើសនៃអំពើជួញដូរមនុស្សដោយការកេងប្រវ័ញ្ច និងការរំលោភបំពានគ្រប់រូបភាពឲ្យលទ្ធផលល្អប្រសើរជាអតិបរមា»។ សម្តេចក្រឡាហោម បានបន្តទៀតបេសកកម្មរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង ការជួញដូរមនុស្សគឺត្រូវតែបន្តធ្វើឲ្យកាន់តែសកម្ម អនុវត្តនូវវិធានការច្បាប់ឲ្យកាន់តែម៉ឺងម៉ាត់ និងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ប្រឆាំងអំពើជួញដូរមនុស្សសម្រាប់ឆ្នាំ២០១៩–២០២៣ ឲ្យសម្រេចបានទៅតាមគោលដៅដែលគ្រោងទុក។ យ៉ាងណាក៏ដោយសម្តេចក្រឡាហោមក៏បានអំពាវនាវឲ្យមានការចូលរួមពីសំណាក់ ក្រសួង ស្ថាប័នជាសមាជិក ក៏ដូចជាដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជនទាំងនៅថ្នាក់ ជាតិនិងថ្នាក់ក្រោមជាតិព្រមទាំងកិច្ចសហការល្អជាមួយប្រទេសពាក់ព័ន្ធនៅក្នុងតំបន់ក៏ដូចជា ពិភពផងដែរ។

ជាមួយគ្នានោះសម្តេចក្រឡាហោម ស ខេង ក៏បានបញ្ជាក់បន្ថែមទៀតផងដែរថា កម្ពុជា បាននឹងកំពុងខិតខំជម្រុញអនុវត្តគោលការណ៍ទាំងឡាយ ដែលមានចែងក្នុងកតិកាសញ្ញាពិភពលោក«ស្តីពីទេសន្តប្រវេសន៍ដោយសុវត្ថិភាពរៀបរយនិងស្របច្បាប់» ដែលហៅកាត់ថា GCM និងជំរុញបន្ថែមទៀតនូវការអនុវត្តអនុសញ្ញាអន្តរជាតិ «ស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង»និងកិច្ចព្រមព្រៀងទាំងទ្វេភាគីពហុភាគីឲ្យបានម៉ឺងម៉ាត់ផងដែរ។ ខណៈនោះដែរ សម្តេចក៏បានអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ត្រូវមានការប្រុងប្រយ័ត្នខ្ពស់បន្ថែមទៀតចំពោះជនខិលខូចដែលមានចេតនាបោកប្រាស់ តាមរូបភាពផ្សេងៗដូច ជាតាមប្រព័ន្ធបច្ចេកវិទ្យាទំនើបផងដែរ ខណៈបច្ចុប្បន្ននេះ ការបោកប្រាស់នូវតាមប្រព័ន្ធអន ឡាញនេះបានកើតឡើងជាបន្តបន្ទាប់នោះ៕

## លោក ស ខេង អំពាវនាវឲ្យប្រទេសជាមិត្ត ពង្រឹងកិច្ចសហការប្រឆាំងការជួញដូរមនុស្ស

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 13 December 2019 | 11:06 ICT

**ភ្នំពេញៈ** លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានថ្លែងនៅពេលធ្វើជាអធិបតីក្នុងទិវាជាតិប្រឆាំងការជួញដូរមនុស្សដោយបានអំពាវនាវដល់ប្រទេសជាមិត្តទាំងអស់ឲ្យពង្រឹងកិច្ចសហការ ជ្រោមជ្រែងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែខ្លាំងក្លា ខណៈអំពើជួញដូរមនុស្សនៅតែកើតឡើងតាមរូបភាពផ្សេងៗគ្នា។ ក្នុងពិធីពីម្សិលមិញនេះលោក ស ខេង បានកត់សម្គាល់ឃើញថា អំពើជួញដូរមនុស្សនៅតែមានការកើតឡើងតាមរយៈការនាំមនុស្សឆ្លងដែនដោយជនល្មើសបានប្រើវិធីផ្សេងៗ បន្លំក្នែកសមត្ថកិច្ចក្នុងគោលដៅធ្វើអាជីវកម្មតាមរូបភាពដូចជាអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ ការជួញដូរទារក ការស្វែងរកការងារ ដោយគេចវេះពីគោលការណ៍ច្បាប់ជាដើម។ លោកថ្លែងថា៖ «ខ្ញុំក៏សូមអំពាវនាវដល់ភាគីប្រទេសគោលដៅពាក់ព័ន្ធ សូមចូលរួមពង្រឹងកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើការផ្ទៀងផ្ទាត់ និងផ្តល់ឯកសារត្រឹមត្រូវ ជូនពលករកម្ពុជាដែលមានឯកសារផុតសុពលភាព»។

លោក ស ខេង ក៏អំពាវនាវដល់វិស័យឯកជនដែលមានកម្មករ ឬពលករបម្រើការងារក្នុងរោងចក្រ សហគ្រាស និងសេវាកម្មរបស់ខ្លួន ត្រូវពង្រឹងការតាមដានគ្រប់គ្រង និងសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធដើម្បីមានវិធានការបង្ក្រាប និងផ្តន្ទាទោសឲ្យបានទាន់ពេលវេលា លើជនខិលខូចដែលបង្កការលំបាក និងការកេងប្រវ័ញ្ចដោយធ្វើអាជីវកម្មលើកម្មករ និងពលករនៅក្រៅប្រទេសយ៉ាងអមនុស្សធម៌។

ក្នុងគោលដៅប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលោក ស ខេង បញ្ជាក់ថា រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងអប់រំផ្សព្វផ្សាយជូនសិស្ស-និស្សិត ប្រជាពលរដ្ឋឲ្យបានយល់ដឹងអំពីកលល្បិចរបស់ជនល្មើស និងផលប៉ះពាល់នៃការធ្វើទេសន្តរប្រវេសន៍ ដោយប្រថុយប្រថានដែលអាចកើតមានគ្រោះថ្នាក់ជាយថាហេតុក្នុងនោះក្រសួងពាក់ព័ន្ធរួមជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងប្រព័ន្ធផ្សព្វផ្សាយបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការផ្សព្វផ្សាយលើបញ្ហានេះ។ លោកបញ្ជាក់ថា ជនរងគ្រោះនៃអំពើជួញដូរមនុស្សភាគច្រើន គឺជាពលករទេសន្តរប្រវេសន៍ដែលរៀងរាល់ឆ្នាំមានជនរងគ្រោះរាប់សែនលាននាក់ត្រូវបានបំផ្លាញដោយក្រុមឧក្រិដ្ឋជននៃអំពើជួញដូរមនុស្សដោយជនល្មើសបានរកគ្រប់ល្បិចស្មោកគ្រោក បង្កើតបណ្តាញធ្វើសកម្មភាពកេងប្រវ័ញ្ចជនរងគ្រោះគ្រប់ដំណាក់កាលទាំងដោយផ្ទាល់ និងដោយប្រយោលតាមរយៈបណ្តាញទំនាក់ទំនងអនឡាញ ឬតាមបច្ចេកវិទ្យាទំនើបដែលកំពុងប្រើប្រាស់ពេញនិយមទាំងនៅទីក្រុងនិងជនបទ។ លោកថា៖ «ក្នុងនាមរដ្ឋាភិបាលខ្ញុំសូមគូសបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តបន្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងគោលដៅការពារ និងលើកកម្ពស់សុវត្ថិភាពរបស់មនុស្សគ្រប់រូប និងសន្តិសុខសង្គមក៏ដូចជាលើកកម្ពស់ ការគោរពសិទ្ធិសេចក្តីថ្លៃថ្នូរ និងផលប្រយោជន៍របស់មនុស្សគ្រប់ប្រភេទ គ្រប់វ័យ ដែលត្រូវបានបំផ្លាញដោយជនល្មើសនៃអំពើជួញដូរមនុស្សដោយការកេងប្រវ័ញ្ច និងការរំលោភបំពានគ្រប់រូបភាព...»។

លោកស្រី អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារីក៏បានថ្លែងក្នុងទិវានេះដែរថា អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទជាបញ្ហាប្រឈមសកលដែលនៅតែបន្តកើតមានអាស្រ័យដោយកត្តាសំខាន់ចំនួន ៣ គឺបណ្តាលមកពីការអប់រំសង្គមការអនុវត្តច្បាប់ និងការឆក់ឱកាសពីជនល្មើស។ លោកស្រីថ្លែងថា៖ «រូបភាពនៃការជួញដូរមនុស្សមិនត្រឹមតែជាការជួញដូរ ឬកេងប្រវ័ញ្ច កម្លាំងពលកម្ម និងផ្លូវភេទប៉ុណ្ណោះទេ តែក៏មានបាតុភាពមួយចំនួនទៀតដែលមានទំនោរទៅរកអំពើជួញដូរសេរីរាង្គ និងបទល្មើសជួញដូរទារកឆ្លងដែនក្រោមរូបភាពអំពើជួលពពោះជំនួស»។ លោកស្រីបន្ថែមថា នេះជាកង្វល់ថ្មីទៀតដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបាននិងកំពុងដាក់វិធានការស៊ើបអង្កេតស្រាវជ្រាវ និងបង្ក្រាបជាបណ្តើរៗឲ្យបានទាន់ពេល និងសិក្សាអំពីបរិបទច្បាប់ បទដ្ឋានគតិយុត្ត ពាក់ព័ន្ធបន្ថែមទៀតដើម្បីចៀសវាងការរីកដុះដាលនៃបទល្មើសដែលបង្កគ្រោះថ្នាក់កាន់តែច្រើនឡើងដល់សង្គម និងមនុស្សគ្រប់វ័យ។

ក្នុងពិធីនៅកោះពេជ្រនេះលោក ស ខេង ជំរុញឲ្យគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សត្រូវតែបន្តធ្វើឲ្យកាន់តែសកម្មអនុវត្តនូវវិធានការច្បាប់ឲ្យបានកាន់តែម៉ឺងម៉ាត់ និងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើជួញដូរមនុស្សសម្រាប់ ឆ្នាំ ២០១៩-២០២៣ ឲ្យបានសម្រេចតាមគោលដៅដែលគ្រោងទុក៕

## សម្តេច ស ខេង៖ ជនល្មើសប្រើអនឡាញទាក់ទាញជនរងគ្រោះឱ្យចូលអន្ទាក់

http://kleykley.sabay.com.kh/ 13-12-2019

សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ ‍ បានលើកឡើងថា ជនល្មើស បានរកគ្រប់ល្បិចកលដ៏ស្មោកគ្រោក ពង្រាយបណ្តាញធ្វើសកម្មភាពកេងប្រវ័ញ្ចជនរងគ្រោះនៅគ្រប់ដំណាក់កាល ទាំងដោយផ្ទាល់ និងប្រយោលតាមរយៈបណ្តាញទំនាក់ទំនង អនឡាញ (Online) ឬតាមបច្ចេកវិទ្យាទំនើបដែលប្រជាពលរដ្ឋ ជាពិសេសយុវវ័យ កុមារ និងមនុស្សពេញវ័យនិយមប្រើប្រាស់ គឺ

ទូរសព្ទដៃ និងប្រព័ន្ធអិនធើណេត។ ការថ្លែងនេះ ធ្វើឡើងនៅក្នុងទិវាជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស កាលពីរសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩ នៅសាលមហាស្រពកោះពេជ្រ។

សម្តេចក្រឡាហោមបញ្ជាក់ថា ទំនោរនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបនេះ បានធ្វើឲ្យឧក្រិដ្ឋជន បានឆ្លៀតឱកាសប្រើប្រាស់បច្ចេកវិទ្យាទំនើបនេះ ដើម្បីទាក់ទាញជនរងគ្រោះឲ្យចូលក្នុងអន្ទាក់របស់ខ្លួន និងគេចវេសពីសមត្ថកិច្ច ដែលបច្ចុប្បន្ននេះ ប្រព័ន្ធអនឡាញនិងបណ្តាញផ្សព្វផ្សាយសង្គម ក៏បានបង្កើតជាបញ្ហាថ្មី គឺ «ការជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ ជាពិសេស លើអនីតិជនតាមប្រព័ន្ធអនឡាញ»។ សម្តេចក្រឡាហោម ស ខេង បានមានប្រសាសន៍ថា អំពើជួញដូរមនុស្ស ជាប្រភេទឧក្រិដ្ឋកម្មឆ្លងដែន ដែលប្រកបដោយគ្រោះថ្នាក់ចំពោះមនុស្សគ្រប់វ័យ គ្រប់ភេទ ក្នុងសង្គម គ្រោះថ្នាក់ជាញឹកញាប់ត្រូវបានរកឃើញក្នុងចំណោមអ្នកធ្វើចំណាកស្រុក ឬទេសន្តរប្រវេសន៍ ដែលស្វែងរកការងារនិងប្រាក់ចំណូល ដែលនៅឆ្ងាយពីទីកន្លែងដែលខ្លួនរស់នៅ ។ រៀងរាល់ឆ្នាំមនុស្សរាប់សែន រាប់លាននាក់ ត្រូវបានបំផ្លាញដោយឧក្រិដ្ឋជនជួញដូរមនុស្ស នៅគ្រប់ទីកន្លែង ក្នុងពិភពលោក។

ជាមួយគ្នានេះ សម្តេចបានអំពាវនាវដល់ភាគីប្រទេសជាមិត្តទាំងអស់ ចូលរួមសហការ ជួយជ្រោមជ្រែងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែខ្លាំងក្លាថែមទៀត និងសូមអំពាវនាវភាគីប្រទេសគោលដៅពាក់ព័ន្ធចូលរួមពង្រឹងកិច្ចសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើការផ្ទៀងផ្ទាត់ និង ផ្តល់ឯកសារត្រឹមត្រូវជូនពលករកម្ពុជា ដែលមានឯកសារផុតសុពលភាព ជៀសវាងការប្រើប្រាស់ឯកសារអ្នកដទៃ ដែលខុសអត្តសញ្ញាណ និងការចេញឯកសារ ជាឯកត្តោភាគី ដោយខ្វះព័ត៌មានអំពីអត្តសញ្ញាណពិត និងខ្វះការត្រួតពិនិត្យ ពីសមត្ថកិច្ចប្រទេសដើម៕

អត្ថបទ៖ សោភា

## វគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី ជំនាញសម្រាប់ផ្តល់សេវាប្រកបដោយគុណភាព ដល់អ្នកផ្តល់សេវាជួរមុខ

https://www.facebook.com/deputygovernoryousophear/ December 11 at 3:31 PM •

ព្រឹកថ្ងៃពុធ ទី១១ ខែធ្នូ ឆ្នាំ២០១៩ លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត (គ.ខ.ប.ជ) បានអញ្ជើញចូលរួមក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពីជំនាញសម្រាប់ផ្តល់សេវាប្រកបដោយគុណភាពដល់អ្នកផ្តល់សេវាជួរមុខ ដល់ជនរងគ្រោះនិងជនងាយរងគ្រោះជាស្ត្រីដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ វគ្គបណ្តុះបណ្តាលនេះ រៀបចំដោយអង្គការ UN WOMEN ក្រោមគម្រោងស្តីពី កម្មវិធីសុវត្ថិភាព និងយុត្តិធម៌ (Safe and Fair) និងធ្វើការបណ្តុះបណ្តាលដល់មន្ត្រីក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងខេត្តចំនួន០៥ រួមមានខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ និងខេត្តកំពង់ចាម ដែលមានមន្ត្រីមកពីរដ្ឋបាលសាលាខេត្ត មន្ទីរពាក់ព័ន្ធ និងអង្គការដៃគូពាក់ព័ន្ធមួយចំនួនផងដែរ។

វគ្គបណ្តុះបណ្តាលនេះ រៀបចំឡើងក្នុងរយៈពេល០៣ថ្ងៃ (១១-១៣ ខែធ្នូ ឆ្នាំ២០១៩) នៅសណ្ឋាគារអង្គរសេនជូរី ខេត្តសៀមរាប ក្នុងគោលបំណង ដើម្បីស្វែងយល់ពីបទពិសោធន៍នៃការរងគ្រោះដោយអំពើហិង្សា ការលើកកម្ពស់ជំនាញប្រាស្រ័យទាក់ទងរបស់អ្នកផ្តល់សេវាជួរមុខ ក្នុងការគាំទ្រចិត្តសង្គមដល់ពលករ ទេសន្តរប្រវេសន៍ជាស្ត្រី និងការបង្កើនសមត្ថភាពរបស់អ្នកផ្តល់សេវាជួរមុខក្នុងការគ្រប់គ្រងករណី ការសម្របសម្រួល បញ្ជូន ប្រមូលទិន្នន័យ និងការរាយការណ៍។ វគ្គបណ្តុះបណ្តាលនេះ ជាគុណប្រយោជន៍ និងជាឱកាសក្នុងការចូលរួមពិភាក្សាជាក្រុម ពិភាក្សាលើករណីសិក្សាជាច្រើន ក្នុងការផ្លាស់ប្តូរ ការចែករំលែកបទពិសោធន៍ ដែលអាចធ្វើការឆ្លុះបញ្ចាំងលើសមត្ថភាព ដែលបានប្រើប្រាស់នាពេលកន្លងមក ហើយអាចធ្វើការកែលម្អបន្ថែមទៀត លើចំណុចខ្វះខាតក្នុងការផ្តល់សេវាជួយជនរង

គ្រោះឲ្យបានសមស្រប និងមានប្រសិទ្ធភាពខ្ពស់។ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រីគឺអាចធ្វើទៅបានតាមរយៈការឆ្លើយតប ជាពហុវិស័យទាមទារ ឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ពន្ធ័ រួមទាំងស្ត្រីខ្លួនឯងផងដែរ។

## កម្ពុជា-អារ៉ាប់រួម នឹងចុះអនុស្សារណៈ លើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាពេលឆាប់ៗខាងមុខ

https://www.dap-news.com/ By VNT108 Posted on December 11, 2019

ភ្នំពេញ៖ ព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់រួមនឹងចុះអនុស្សារណៈ នៃការយោគយល់គ្នាលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាពេលឆាប់ៗខាងមុខ ដើម្បីបង្កើន កិច្ចសហប្រតិបត្តិការលើវិស័យនេះ និងត្រៀមបញ្ជូន-ទទួលពលករកម្ពុជា ឱ្យទៅធ្វើការនៅអារ៉ាប់រួម ខណៈមានការអះអាងថា បច្ចុប្បន្នការរស់នៅ និងការប្រកបការងារក្នុងប្រទេសនេះ កំពុងមានសុខដុមនីយកម្មយ៉ាងល្អប្រសើរ។ ការអះអាងយ៉ាងដូច្នេះ ត្រូវបានលើកឡើង នៅក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាង លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយលោក Saif Abdulla Mohammed Khalfan Alshamisi ( សាអ៊ីហ្វ អាប់ឌុលឡា មហាម៉េដ ខាល់ហ្វាន អាល់ស្វាមីស៊ី ) ឯកអគ្គរដ្ឋទូតអារ៉ាប់រួម ដែលមាននិវេសនដ្ឋាន នៅទីក្រុងបាងកក នាព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ នៅទីស្តីការក្រសួង។ នៅមុនជំនួបពិភាក្សាខាងលើនេះ សេចក្តីព្រាងអនុស្សារណៈ នៃការយោគយល់គ្នា លើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមួយ ត្រូវបានបញ្ជូនពីខាងភាគីអារ៉ាប់រួម មកកាន់ភាគីកម្ពុជារួចមកហើយ ហើយបច្ចុប្បន្នក្រុមការងារជំនាញ របស់ភាគីកម្ពុជា ក៏កំពុងរួមគ្នាត្រួតពិនិត្យ យ៉ាងយកចិត្តទុកដាក់ផងដែរ។

លោក អ៊ិត សំហេង បានសម្តែងការពេញចិត្ត ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ រវាងព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់រួម ហើយក៏បានបង្ហាញការស្វាគមន៍ ចំពោះកិច្ចខិតខំប្រឹងប្រែង លើការជំរុញឱ្យមានអនុស្សរណៈ នៃការយោគយល់គ្នាថ្មីនេះ ដែលកំពុងដំណើរការយ៉ាងល្អ។ លោករដ្ឋមន្ត្រីបានបន្តថា នៅពេលអនុស្សរណៈ ត្រូវបានចុះហត្ថលេខារួចរាល់ វាជាការផ្តល់ឱកាសថ្មីបន្ថែមទៀត ដល់ប្រជាពលរដ្ឋកម្ពុជា ដែលចង់ស្វែងរកការងារ ធ្វើនៅក្រៅប្រទេស និងទទួលបានប្រាក់ចំណូលខ្ពស់។ នៅក្នុងប្រទេសកម្ពុជា ក៏សម្បូរការងារធ្វើហើយកន្លែងខ្លះ ក៏ខ្វះកម្លាំងពលកម្មទៅទៀត ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជា នៅតែផ្តល់ឱកាស និងស្វែងរកការងារនៅក្រៅប្រទេស សម្រាប់ប្រជាពលរដ្ឋបន្ថែមទៀតដែរ។ លោករដ្ឋមន្ត្រីបានបញ្ជាក់ទៀតថា តាមរយៈការចេញទៅធ្វើការក្រៅប្រទេសនេះ បានជួយអោយពលករ ទទួលបានប្រាក់ចំណូលថែម ទាំងទទួលបានបទពិសោធន៍ ជំនាញវិជ្ជាជីវៈទៀតផង។

លោកឯកអគ្គរដ្ឋទូតអារ៉ាប់រួម Abdulla Mohammed បានអះអាងថា នៅប្រទេសអារ៉ាប់រួម មានប្រជាជនរស់នៅយ៉ាងច្រើន ក្នុងនោះមានប្រមាណ ២០០សញ្ជាតិ ដែលកំពុងរស់នៅ ប្រកបការងារ អាជីវកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ក្នុងប្រទេសនេះ ប្រកបដោយសុខដុមនីយកម្ម។ មិនតែប៉ុណ្ណោះ នៅឆ្នាំ២០១៩នេះ រដ្ឋាភិបាលអារ៉ាប់រួម ក៏បានដាក់ចេញ គោលនយោបាយគាំពារសិទ្ធិ សេរីភាព និងផលប្រយោជន៍ របស់ប្រជាជនដែលរស់នៅ ប្រកបការងារ អាជីវកម្ម និងធ្វើពាណិជ្ជកម្មក្នុងប្រទេសខ្លួនផងដែរ ដើម្បីធ្វើឱ្យការរស់នៅក្នុងប្រទេសនេះ កាន់តែមានភាពសុខសាន្ត។ លោក Abdulla Mohammed បានបង្ហាញគោលបំណង ចង់ឱ្យអនុស្សរណៈនៃការយោគយល់គ្នា លើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរវាងកម្ពុជា និងអារ៉ាប់រួម ឈានទៅរកការចុះហត្ថលេខា ឱ្យបានឆាប់រហ័ស។

សូមជម្រាបថា បច្ចុប្បន្នមិនទាន់មានពលករកម្ពុជា ទៅធ្វើការនៅប្រទេសអារ៉ាប់រួម តាមរយៈក្រុម ហ៊ុនដែលទទួលសិទ្ធិ ពីរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអារ៉ាប់រួមនៅឡើយទេ ប៉ុន្តែអាចមានពលករកម្ពុជាមួយចំនួន បានទៅធ្វើការនៅទីនោះ ដោយខ្លួនឯង៕

https://www.facebook.com/CentralCambodiaOrg/ 13-12-2019

នៅថ្ងៃនេះអង្គការសង់ត្រាល់ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី (ការជ្រើសរើសពលករប្រកបដោយក្រមសីលធម៌) ដោយមានការចូលរួមពី តំណាងរដ្ឋាភិបាល ក្រសួងការងារ អង្គការសង្គមស៊ីវិលក្នុងស្រុក និងសង្គមស៊ីវិលមកពីប្រទេសថៃ ទីភ្នាក់ងារជ្រើសរើសពលករ យុវជន កម្មករ ពលករ និងអតីតពលកចំណាកស្រុក។

## ពលករខ្មែរឆ្លងដែនកាប់ឈើគ្រញូងប្រុសស្រី៣នាក់ រួចផុតទោស អាជ្ញាធរថៃយកមកប្រគល់ឲ្យកម្ពុជាវិញ

http://nokorwatnews.com/ 12-12-2019

ខេត្តឧត្តរមានជ័យ៖ ពលករខ្មែរប្រុស ស្រី ឆ្លងដែនខុសច្បាប់ ចូលកាប់ឈើគ្រញូង ចំនួន៣នាក់ក្នុងទឹកដីថៃ ត្រូវបានអាជ្ញាធរថៃចាប់យកផ្តន្ទាទោសតាមច្បាប់ប្រទេសថៃ នៅម៉ោង១៥និង២០នាទី ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ អាជ្ញាធរថៃបានបញ្ជូនមកប្រគល់ឲ្យកម្ពុជាវិញតាមច្រកទ្វាអន្តរជាតិជាំ ឃុំត្រពាំងប្រិយ៍ស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចបានឲ្យដឹងថា៖ អាជ្ញាធរថៃបាន នបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន ០៣ នាក់មាន ស្រី ០២ នាក់ ប្រុសម្នាក់ ។ ទី១៖ឈ្មោះ ប៉ាត ពិន ភេទស្រី ២៥ឆ្នាំ ទី២៖ឈ្មោះ ភូក មុំ ភេទស្រី ៣០ឆ្នាំ ទី៣៖ឈ្មោះ ពុំ គយ ភេទប្រុស ៣៩ឆ្នាំអ្នកទាំង ០៣ រស់នៅភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ ចាប់ខ្លួននៅថ្ងៃទី១៣ ខែ៥ ឆ្នាំ២០១៧ ពីបទឆ្លងដែនរកក្រញូង ចូលតាមច្រកទឹកជប់ ជាប់គុកនៅស្រុកខាន់តាឡាក់ខេត្តស៊ីសាកេត ប្រទេសថៃ ។ សមត្ថកិច្ចបានអប់រំរួចរាល់ និងឲ្យវិលត្រឡប់ទៅស្រុកកំណើតរាងៗខ្លួន ៕ ប៉ែន នួន

## កម្លាំងអាជ្ញាធរអន្តោប្រវេសន៍ ខេត្តណាខនស៊ីថាមរាជ ប្រទេសថៃ បានធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរ ចំនួន ០១នាក់

https://www.facebook.com/LabourOfficial/ 12-12-2019

ឃាត់ខ្លួនពលរដ្ឋខ្មែរ ០១នាក់ Over Stay 70ថ្ងៃ កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ កន្លងទៅកម្លាំងអាជ្ញាធរអន្តោប្រវេសន៍ ខេត្តណាខនស៊ីថាមរាជ ប្រទេសថៃ បានធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរ ចំនួន ០១នាក់ ឈ្មោះ ហាំ សារ៉ាក់ អាយុ ៣០ឆ្នាំ ពីបទស្នាក់នៅលើសទិដ្ឋាការកំណត់ ចំនួន ៧០ថ្ងៃ ។ ក្រោយពេលឃាត់ខ្លួនពលរដ្ឋខ្មែរខាងលើត្រូវបានសមត្ថកិច្ចថៃបញ្ជូនទៅអធិការដ្ឋានតម្រួតអន្តោប្រវេសន៍ ខេត្តណាខនស៊ីថាមរាជ ដើម្បីវិធានការតាមផ្លូវច្បាប់។

## ពលករខ្មែរធ្វើការសំណង់យកកូនស្រី មកអោយលេងនៅន្លែងធ្វើការ ប៉ុន្តែអកុសលកូនត្រូវរថយន្តកិនស្លាប់

https://www.facebook.com/LabourOfficial/ 12/12/19

ពលករខ្មែរធ្វើការសំណង់យកកូនស្រី មកអោយលេងនៅន្លែងធ្វើការ ប៉ុន្តែអកុសលកូនត្រូវរថយន្តកិនស្លាប់យ៉ាងអាណោចអាធ័ម ហេតុការណ៍នេះបានកើតឡើងកាលពីវេលាម៉ោង០៩ព្រឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩ ស្ថិតនៅក្នុងការដ្ឋានសំណង់មួយកន្លែងក្នុង ខេត្តសាមុតប្រាកាន ប្រទេសថៃ ។

## បុរសពលករខ្មែរធ្វើការសំណង់ ធ្លាក់ពីលើផ្ទះសំណាក់ ស្លាប់បាត់បង់ជីវិត

https://www.facebook.com/LabourOfficial/ 12/12/19

មានករណីបុរសពលករខ្មែរធ្វើការសំណង់ ធ្លាក់ពីលើផ្ទះសំណាក់ ស្លាប់បាត់បង់ជីវិតហេតុការណ៍នេះបានកើតឡើងនៅក្នុងស្រុកប្រាកសាមុតជេឌី ខេត្តសាមុតប្រាកាន ។ យោងតាមរបាយការណ៍ពីកន្លែងកើតហេតុជនរង

គ្រោះបាននាំស្រីស្នេហ៍ឡើងផ្ទះសំណាក់បន្ទាប់មកស្រវឹងធ្លាក់ពីលើផ្ទះបណ្តាលឲ្យស្លាប់បាត់បង់ជីវិត។ បច្ចុប្បន្នសាកសពជនរងគ្រោះត្រូវបានសមត្ថកិច្ចបញ្ជូនយកទៅរក្សាទុកនៅមន្ទីរពេទ្យប្រាក់សាមុតដេឌីដើម្បីធ្វើកោសល្យវិច័យ។

## ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១៩

## នាយករដ្ឋមន្ត្រីៈពិព័រណ៍ផលិតផលខ្មែរបង្កើនប្រាក់ចំណូល និងទប់ស្កាត់ការធ្វើចំណាកស្រុក

https://www.dap-news.com/ ByTR110 Posted on December 15, 2019

ភ្នំពេញៈ ក្នុងឱកាសអញ្ជើញ ជាអធិបតីភាព បើកពិព័រណ៍ផលិតផលខ្មែរ និងទំនិញនាំចេញ-នាំចូល កម្ពុជា លើកទី១៤ ឆ្នាំ២០១៩នារសៀលថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៩ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានលើកឡើងថា ព្រឹត្តិការណ៍នេះ បានជួយបង្កើនផលិតភាព បង្កើនតម្លៃបន្ថែមលើផលិតផល ពង្រឹងគុណភាពផលិតផល និងសេវា បង្កើតការងារថ្មីៗ បង្កើនប្រាក់ចំណូល ជួយទប់ស្កាត់ការធ្វើចំណាកស្រុក ។ សម្តេចតេជោបន្តថា ព្រឹត្តិការណ៍ពាណិជ្ជកម្មនេះ ក៏បានជួយ រួមចំណែកកាត់បន្ថយភាពក្រីក្រ នៅកម្ពុជាផងដែរ។ លើសពីនេះទៀត សម្តេចតេជោបានកត់សម្គាល់ឃើញថា *"តាមរយៈការរៀបចំពិព័រណ៍ក្នុងស្រុក និងការចូលរួមរបស់កម្ពុជាក្នុងពិព័រណ៍ធំៗនៅក្រៅប្រទេសដូចជា ពិព័រណ៍ពិភព លោក ពិព័រណ៍អន្តរជាតិ និងពិព័រណ៍ចិន-អាស៊ានជាដើម បានធ្វើឲ្យកម្ពុជាមានកិត្តិយស ស្មើមុខស្មើមាត់ លើឆាក អន្តរជាតិ និងជាឱកាសដ៏ល្អ សម្រាប់កម្ពុជាផ្សព្វផ្សាយ អំពីផលិតផលសក្តានុពលរបស់ខ្លួន ស្វែងរកទីផ្សារនាំចេញ ទាក់ទាញវិនិយោគិនបរទេស និងពង្រឹងកិច្ចសហប្រតិបត្តិការល្អលើគ្រប់វិស័យជាមួយបណ្តាប្រទេសជាមិត្ត ជាពិសេស បានចូលរួមចំណែកផ្សព្វផ្សាយអំពីវប្បធម៌ និងអរិយធម៌ខ្មែរ ដើម្បីទាក់ទាញភ្ញៀវទេសចរចូលមកកម្ពុជាកាន់តែច្រើនថែមទៀត"*។

សម្តេចតេជោមាន ប្រសាសន៍បន្តថា តាមរយៈគោលនយោបាយ ឈ្នះ ឈ្នះ របស់រាជរដ្ឋាភិបាលកម្ពុជា និងការរក្សាបាននូវសន្តិភាព និងសន្តិសុខ សង្គមទូទាំងប្រទេស បានធ្វើឲ្យកម្ពុជាទទួលបាននូវកាលានុវត្តភាពថ្មីពុំធ្លាប់មាន សម្រាប់ការកែទម្រង់ ទូលំទូលាយមួយ ព្រមទាំងទទួលបាននូវទំនុកចិត្តខ្ពស់ពីធុរជន និងវិនិយោគិនទាំងក្នុង និងក្រៅប្រទេស ដែលជាឱកាសធ្វើឲ្យសេដ្ឋកិច្ចកម្ពុជា រីកចម្រើនក្នុងកំណើនជាមធ្យម ៧.៧% ក្នុងមួយឆ្នាំក្នុងរយៈពេល ២០ឆ្នាំ កន្លងទៅ។ ដើម្បីជំរុញឲ្យវិស័យទាំងបួន ខាងលើកាន់តែមានការរីក ចម្រើន រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសឲ្យប្រើប្រាស់ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ សំដៅរក្សាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងដើម្បីប្រែក្លាយកម្ពុជាបច្ចុប្បន្ន ពីប្រទេសដែលមានប្រាក់ចំណូល មធ្យមកម្រិតទាប ឲ្យទៅជាប្រទេសមានប្រាក់ចំណូល មធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងសម្រេចបានគោល ដៅជាប្រទេស ដែលមានប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

នាយករដ្ឋមន្ត្រី បន្ថែមថា វិស័យពាណិជ្ជកម្មកម្ពុជាបានរួម ចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ និងជំរុញកំណើន សេដ្ឋកិច្ច។ ការនាំចេញទំនិញពីកម្ពុជា ទៅកាន់ទីផ្សារអន្តរជាតិ មានការកើនឡើងជាលំដាប់។ ឆ្លៀតក្នុងឱកាសដ៏សំខាន់នេះ នាយករដ្ឋមន្ត្រី ក៏បានលើកទឹកចិត្តពាណិជ្ជករ សហគ្រិន វិនិយោគិន ធុរជនទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងអ្នកទស្សនាពិព័រណ៍ទាំងអស់ គប្បីចូលរួមនិងប្រើប្រាស់ឲ្យអស់លទ្ធភាពនូវវេទិកានានា ក្នុងព្រឹត្តិការណ៍ពាណិជ្ជកម្មប្រចាំឆ្នាំនេះដើម្បីទទួលបានជោគជ័យថ្មីៗថែមទៀតលើកិច្ចការធុរកិច្ចនិងវិនិយោគរបស់ខ្លួន។

បើតាមរបាយការណ៍ លោកប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីពាណិជ្ជ កម្ម ពិព័រណ៍ផលិតផលខ្មែរនេះ ត្រូវបាន រៀបចំឡើងដោយមានការគាំទ្រ និងការចូលរួម យ៉ាងសកម្មពីប្រទេស ជាមិត្តក្នុងតំបន់ដូចជា ប្រទេសចិន ជប៉ុន ឥណ្ឌូនេស៊ី ថៃ ម៉ាឡេស៊ី មីយ៉ាន់ម៉ា វៀតណាម និងប្រទេសឡាវព្រមទាំងមន្ទីរពាណិជ្ជកម្មទាំង២៥ រាជធានី-ខេត្ត សភាពាណិជ្ជកម្មកម្ពុជា សហព័ន្ធស្រូវអង្ករ អង្គការ សមាគមអាជីវកម្ម ក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនបរទេសដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា។ ពិព័រណ៍នេះមានស្តង់សរុបចំនួន ៣៧២ស្តង់ ដោយមានទំនិញ និងសេវាជាច្រើនប្រភេទផងដែរ៕

## នគរបាលប៉ុស្តិ៍វត្តភ្នំ ឃាត់ខ្លួនស្រ្តីរកស៊ីផ្លូវភេទ និងអ្នកគួកជេសរុប៣នាក់

http://nokorwatnews.com/ 16-12-2019

ភ្នំពេញ៖ ស្រ្តីរកស៊ីផ្លូវភេទ និងអ្នកគួកជេសរុបចំនួន៣នាក់ ត្រូវកម្លាំងនគរបាលប៉ុស្តិ៍វត្តភ្នំ ឃាត់ខ្លួនជាបន្ទាប់បន្ត នៅជុំវិញរង្វង់មូលវត្តភ្នំ កាលពីវេលាម៉ោង២ រំលងអធ្រាត្រ ចូលថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៩ ។ មន្ត្រីនគរបាលប៉ុស្តិ៍វត្តភ្នំ បានឲ្យដឹងថា ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោក សុខ ពេញវុធ អភិបាលនៃគណៈអភិបាលខណ្ឌដូនពេញ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង១០យប់ កម្លាំងជំនាញខណ្ឌ ប៉ុស្តិ៍នគរបាលវត្តភ្នំបានចុះបង្រ្កាប ករណីស្រ្តីរកស៊ីផ្លូវភេទ និងអ្នកគួកជេ (អ្នកចាប់ម៉ូយ) ស្ថិតនៅចំណុចផ្លូវលេខ ៩២. ៩៤. ៩៦ និងជុំវិញរង្វង់មូលវត្តភ្នំ ហើយបានបញ្ចប់នៅវេលាម៉ោង២ រំលងអធ្រាត្រ ឈានចូលថ្ងៃទី១៥ ខែធ្នូ សមត្ថកិច្ចប្រមូលបានសរុបរួមចំនួន ០៣នាក់ ក្នុងនោះស្រី០២នាក់ ប្រុសភេទទី៣ម្នាក់ ។

ក្រោយឃាត់ខ្លួន កម្លាំងអធិការដ្ឋាននគរបាលខណ្ឌដូនពេញ បានបញ្ជូនស្រ្តីរកស៊ីផ្លូវភេទខាងលើ ទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ដើម្បីអប់រំបន្ត ៕ស រស្មី

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃ ចំនួនន ៤៦នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 13-12-2019

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ នាវេលាម៉ោង ០៧និង៣០នាទី ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ពីភាគីថៃ ចំនួនន ៤៦នាក់ ស្រី ១៣នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ មុននឹងអនុញ្ញាត ឲ្យវិលត្រឡប់ទៅកាន់លំនៅដ្ឋានវិញ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលរដ្ឋខ្មែរ ចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 13-12-2019

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ នារសៀលថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ បានទទួលពលរដ្ឋខ្មែរ ចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រក អានសេះ ខេត្ត ព្រះវិហារ ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានពិនិត្យឃើញមានពលករខ្មែរចំនួន ១៤នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 14-12-2019

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១២និង៥០នាទី ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៩ បានពិនិត្យឃើញមានពលករខ្មែរចំនួន ១៤នាក់ មានទីលំនៅខេត្តកោះកុង ដែលបានទៅធ្វើការនៅខេត្តច័ន្ទបូរី ប្រទេសថៃ ចំនួន ០២ខែ ពុំទទួលបានប្រាក់ខែ។ ក្រោយពីការសាកសួរ និងអប់រំណែនាំរួច កម្លាំងនគរបាលប៉ុស្តិ៍ បានប្រគល់ជូនលោក សាក់ សំណាង មន្ត្រីការិយាល័យសង្គមកិច្ចការងារ ខេត្តកោះកុង ដើម្បីអនុវត្តបន្ត ទៅតាមនីតិវិធីនៃច្បាប់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលរដ្ឋខ្មែរ ចំនួន០៣នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 14-12-2019

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ នារសៀលថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៩ បានទទួលពលរដ្ឋខ្មែរ ចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្ត ឧត្តរមានជ័យ ៕

## មានករណីពលករខ្មែរ ត្រូវខ្សែភ្លើងឆក់រងរបួសធ្ងន់

https://www.facebook.com/LabourOfficial/ ពលករ December 14 at 10:12 PM 14/12/19

ហេតុការណ៍នេះបានកើតឡើងនៅវេលាម៉ោង០២:៣០នាទីនារសៀលថ្ងៃសៅរ៍ ទី១៤ ខែធ្នូ ឆ្នាំ២០១៩នៅក្បែរផ្លូវលំមួយក្នុងតំបន់(កផៃ) ស្ថិតក្នុងក្រុងប៉ាតាយ៉ា ស្រុកបាងឡាមុង ខេត្តឈុនបុរី ប្រទេសថៃ ។ ជនរងគ្រោះមានឈ្មោះ ណុប ភេទប្រុស អាយុ ២៥ឆ្នាំ រងរបួសត្រូវចរន្តភ្លើងអគ្គិសនីឆេះដៃខាងឆ្វេងមានស្ថានភាពធ្ងន់ធ្ងរ ក្រោយពេលកើតហេតុជនរងគ្រោះត្រូវភ្នាក់ងារសង្គ្រោះបញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យបាងឡាមុង ខេត្តឈុនបុរី។ ប្រភពពីមិត្តភ័ក្តិរួមការងារជាមួយជនរងគ្រោះបានប្រាប់ឲ្យដឹងថា ថ្ងៃនេះជនរងគ្រោះមកធ្វើការរៀបចំប្រព័ន្ធខ្សែភ្លើងថ្មី ខណៈពេលកើតហេតុជនរងគ្រោះបានទៅត្រូវចំណុចខ្សែភ្លើងធំ ដែលមានកម្លាំងភ្លើងខ្លាំងបណ្តាលឲ្យត្រូវចរន្តអគ្គិសនីឆក់រងរបួសធ្ងន់។ ប្រភពពីខេត្តឈុនបុរី

## មានករណីពលករខ្មែរធ្វើការលក់បាយនៅក្នុងខេត្តឈុនបុរី បានគាំងបេះដូងស្លាប់

https://www.facebook.com/LabourOfficial/ December 14 at 7:16 AM · 14/12/19

មានករណីពលករខ្មែរធ្វើការលក់បាយនៅក្នុងខេត្តឈុនបុរី បានគាំងបេះដូងស្លាប់ កាលពីវេលាទៀបភ្លឺ ថ្ងៃសៅរ៍ ទី១៤ ខែធ្នូ ឆ្នាំ២០១៩នេះ ជនរងគ្រោះ ឈ្មោះ សៀប សិត ភេទប្រុស អាយុ ២៤ឆ្នាំ ស្រុកកំណើតរស់នៅភូមិល្វា ស្រុកក្រឡាញ់ ខេត្តសៀមរាប។ ប្រភពពីសាច់ញាតិស្លាប់បានប្រាប់ឲ្យដឹងថា ជនរងគ្រោះត្រូវបានសាច់ញាតិបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យឯកជនមួយបន្ទាប់មកជនរងគ្រោះបានស្លាប់បាត់បង់ជីវិត បន្ទាប់មកខាងមន្ទីរពេទ្យបានទាមទារប្រាក់ចំនួន ៤០.០០០បាត ពីសាច់ញាតិជនរងគ្រោះ រីឯខាងថៅកែក៏មិនទទួលខុសត្រូវដែរ ព្រមទាំងគ្មានលេខទូរស័ព្ទទំនាក់ទំនង ខណៈពេលនេះសាច់ញាតិនៅធ្វើការនៅខេត្តអយុធ្យា កំពុងធ្វើដំណើរដល់ទីក្រុងកក់ហេ ីយកំពុងធ្វើដំណើរបន្តមកខេត្តឈុនបុរី ដើម្បីជួបសព។ ប្រភពបន្ថែមពីសាច់ញាតិខណៈពេលនេះសាកសពត្រូវបញ្ជូនចេញពីមន្ទីរពេទ្យឯកជនមករក្សាទុកនៅមន្ទីរពេទ្យស្រុកបាងឡាម៉ុងវិញ។ លេខទូរស័ព្ទសាច់ញាតិសព៖ 0994984159 ,0946947643 ។

បច្ចុប្បន្នសាកសពជនរងគ្រោះត្រូវបានសាច់ញាតិបញ្ជូនយកទៅធ្វើបុណ្យតាមប្រពៃណីនៅឯស្រុកកំណើតនៅប្រទេសកម្ពុជា ករណីនេះបានការជួយអន្តរាគមន៍ពីមន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ភ្លាមៗផងដែរ។

# ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១៩

## លោក ហ៊ុន សែន ថា មន្ទីរពេទ្យព្រះកេតុមាលា មានសមត្ថភាពវះកាត់ប្ដូរក្រលៀនបាន

https://www.rfa.org/khmer/ ដោយ អាស៊ីសេរី 2019-12-16

លោក ហ៊ុន សែន ប្រមុខរដ្ឋាភិបាលក្រុងភ្នំពេញ បានអះអាងថា មន្ទីរពេទ្យព្រះកេតុមាលា ឬពេទ្យទាហានមានសមត្ថភាពវះកាត់ផ្លាស់ប្ដូរក្រលៀន សម្រាប់អ្នកខូចក្រលៀន ឬតម្រងនោម។ ថ្លែងក្នុងពិធីចែកសញ្ញាប័ត្រដល់និស្សិតសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ២.៥៨៨នាក់ នៅកោះពេជ្រ ព្រឹកថ្ងៃទី១៦ ធ្នូ លោក ហ៊ុន សែន លើកឡើងថា មន្ទីរពេទ្យព្រះកេតុមាលា មានសមត្ថភាពដោះដូរគ្រឿងក្នុង ក្រលៀន ឬសរីរាង្គមួយចំនួន ហើយគុណ

ភាពគឺដូច មន្ទីរពេទ្យនៅបរទេស។ លោក ហ៊ុន សែន លើកទឹកចិត្តឲ្យអ្នកជួបបញ្ហាក្រលៀន កុំអស់សង្ឃឹម ឲ្យតែមានបងប្អូន កូនចៅ សាច់ញាតិ ដែលមានប្រភេទក្រលៀនដូចគ្នា អាចទៅជួបពិភាក្សា ជាមួយគ្រូពេទ្យ ដើម្បីវះកាត់ដោះដូរបាន។

ជំងឺខូចក្រលៀន ឬខូចតម្រង់នោម ដែលធ្ងន់ធ្ងរ មិនអាចព្យាបាលបានទេ លុះត្រាតែមានការវះកាត់ប្តូរ ដាក់ក្រលៀនថ្មី។ នៅឆ្នាំ២០១៦ រដ្ឋសភា បានអនុម័តច្បាប់ឲ្យគ្រូពេទ្យ អាចធ្វើការវះកាត់ប្តូរក្រលៀន ឬសរីរាង្គកាយ នៅតាមមន្ទីរពេទ្យបាន តែធ្វើឡើងតាមគោលការណ៍ស្ម័គ្រចិត្តសងខាង សប្បុរសធម៌ និងមិនមានការជួញដូរ មិនមានការផ្សាយពាណិជ្ជកម្ម និងត្រូវធ្វើឡើងជាសម្ងាត់ ជាដើម។

អ្នកកើតជំងឺខូចក្រលៀន ឬតម្រង់នោម នៅកម្ពុជា ភាគច្រើន ទទួលបានត្រឹមសេវា លាងឈាម ឬការលាងជាតិពុលនៅក្នុងឈាម។ ការលាងឈាមនេះ អ្នកជំងឺត្រូវចំណាយលុយខ្ទង់ ៥០ ទៅ ៦០ដុល្លារ ក្នុងការលាងម្តងដោយមិនទាន់រាប់បញ្ចូលនឹងថ្នាំចាក់ផ្សេងៗ ហើយការលាងនេះ ត្រូវធ្វើញឹកញាប់ ឬរង្វើល ទៅតាមស្ថានភាពជំងឺ។ អ្នកខ្លះ ត្រូវលាងឈាម មួយសប្តាហ៍ម្តង ឬត្រូវលាងរាល់ថ្ងៃ ទៅតាមស្ថានភាពជំងឺជាក់ស្តែង។ មន្ទីរពេទ្យ ដែលមានសេវា និងម៉ាស៊ីនលាងឈាម គឺមន្ទីរពេទ្យព្រះកេតុមាលា ឬពេទ្យធំ មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ឬពេទ្យរុស្ស៊ី មន្ទីរពេទ្យព្រះកុសុម ឬពេទ្យលោកសង្ឃ មន្ទីរពេទ្យ កាល់ម៉ែត និងមន្ទីរពេទ្យឯកជនខ្នាតធំ មួយចំនួនទៀត៕

## នាយករដ្ឋមន្ត្រី ហ៊ុន សែន និយាយថាការវះកាត់ដូរតម្រងនោមអាចធ្វើបាននៅកម្ពុជា

https://khmer.voanews.com/ 16 ធ្នូ 2019 ខាន់ សុគុំមនោ

ភ្នំពេញ៖ នៅព្រឹកថ្ងៃចន្ទនេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្តាំប្រជាជនកម្ពុជា ដែលមានជំងឺខូចតម្រងនោមថា ពួកគេអាចស្វែងរកសេវាវះកាត់ផ្សាំកោសិកាតម្រងនោម ឬប្តូរគ្រលៀននៅក្នុងប្រទេសកម្ពុជាបាន។ កន្លងមកកម្ពុជាមិនមានសេវាកម្មផ្លាស់ប្តូរសរីរាង្គនេះទេ។ កាលពីឆ្នាំ២០១៦ រដ្ឋាភិបាលកម្ពុជាបានសម្រេចហាមឃាត់មិនឲ្យមានការទិញដូរសរីរាង្គ ដើម្បីលុបបំបាត់ការជួញដូរខុសច្បាប់។

នៅចំពោះមុខនិស្សិតពេទ្យ ដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលនៅរាជធានីភ្នំពេញ លោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានថ្លែងថា៖ «ឥឡូវខ្ញុំនេះ សូមយកឱកាសនេះ ដើម្បីចែករំលែក និងជម្រាបជូនចំពោះប្រជាពលរដ្ឋកម្ពុជារបស់យើងឲ្យបានជ្រាបថា ការដូរគ្រលៀន ឬសរីរាង្គមួយចំនួន គឺធ្វើបានក្នុងប្រទេសកម្ពុជារបស់យើងដោយសុវត្ថិភាព គឺនៅក្នុងមន្ទីរពេទ្យកងទ័ពរបស់យើងតែម្តង»។ លោក ហ៊ុន សែន បន្តថា ដំណើរការវះកាត់ផ្សាំកោសិកាតម្រងនោមនៅក្នុងស្រុកអាចធ្វើទៅបាន ប្រសិនបើក្រុមគ្រួសាររបស់អ្នកជំងឺអាចបរិច្ចាគគ្រលៀនរបស់ពួកគេដើម្បីសង្គ្រោះអ្នកជំងឺ។ លោក ហ៊ុន សែន បន្ថែមថា៖ «តម្រូវការនៃការប្តូរគ្រលៀន យើងមានតម្រូវការគ្រាន់ថាសាច់ញាតិរបស់យើងដែលមានគ្រលៀនដូចយើងមានឈាមដូចយើង គឺអាចដោះស្រាយបញ្ហាបានហើយ។ ប៉ុន្តែនិយាយយ៉ាងដូច្នេះ មិនមែនបានសេចក្តីថា ឱ្យបងប្អូនលក់គ្រលៀនទេ នាំគ្នាលក់គ្រលៀនទេ ឬក៏សរីរាង្គខ្លះ»។

កាលណាខូចតម្រងនោមទាំងសងខាង វិធីព្យាបាលមានតែមួយគត់ដែលអាចឲ្យអ្នកជំងឺជាសះស្បើយ គឺការវះកាត់ផ្លាស់ប្តូរសរីរាង្គតម្រងនោមដែលខូចចេញ និងជំនួសដោយសរីរាង្គដែលនៅល្អ អាចបំពេញមុខងាររបស់វា ក្នុងការបន្សាបជាតិពុលក្នុងឈាមបាន នេះបើយោងតាមលោកវេជ្ជបណ្ឌិត ជី ទិត ប្រធានមជ្ឈមណ្ឌលលាងឈាមនៅក្នុងមន្ទីរពេទ្យព្រះកេតុ មាលា។ លោកវេជ្ជបណ្ឌិត ជី ទិត បានប្រាប់វីអូអេថា លោកមិនបានដឹងនៅឡើយ អំពីការបង្កើតឲ្យមានសេវាវះកាត់ផ្សាំកោសិការនៅមន្ទីរពេទ្យនេះ។ តែលោកកត់សម្គាល់ថា អ្នកខូចតម្រងនោម និងមកទទួលការលាងបន្សុទ្ធឈាម មានចំនួនកើនឡើងច្រើនជាបន្តបន្ទាប់ ដែលនៅក្នុងមួយថ្ងៃអាចមានដល់ទៅ៦០នាក់ នៅក្នុងអគារលាងឈាមរបស់លោក។ លោក ជី ទិត មានប្រសាសន៍យ៉ាងដូច្នេះថា៖ «ព័ត៌មានហ្នឹង ខ្ញុំអត់ត្រូវបានជ្រួតជ្រាបទេ ចាំមើលខ្ញុំសួរព័ត៌មានខាងមន្ទីរពេទ្យសិនណា។ តែក្រែងលោប្រហែលមាន តែខ្ញុំអត់បានជ្រាបច្បាស់ទេពីបញ្ហាអស់ហ្នឹង»។

លោក ជី ទិត ដែលបម្រើការនៅផ្នែកលាងឈាមនៅមន្ទីរពេទ្យព្រះកេតុមាលា ជាង១២ឆ្នាំមកហើយនោះ បន្តទៀតថា លោកបារម្ភអំពីស្ថានភាពជំងឺតម្រងនោមដែលអ្នកជំងឺក្មេងបំផុតអាចមានអាយុជាង១០ឆ្នាំ ហើយភាគច្រើនអ្នកជំងឺតម្រងនោមដែលប្រើប្រាស់វិធីលាងឈាម ដែលជាការបន្សុទ្ធឈាមប្រោះជាតិពុលចេញតាមរយៈម៉ាស៊ីន។លោកថា ការណ៍នេះកើតឡើងដោយសារអ្នកជំងឺមិនមានលទ្ធភាពទទួលការវះកាត់ប្តូរតម្រងនោមនៅបរទេស ដែលចំណាយប្រាក់ជាច្រើនម៉ឺនដុល្លារអាមេរិក។

តាមផ្លូវច្បាប់ ការផ្តល់សរីរាង្គតម្រងនោម ត្រូវធ្វើឡើងតាមទម្រង់បរិច្ចាគពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត និងវះកាត់ដោយគ្រូពេទ្យឯកទេស និងមានកម្មវិធីតាមដានពិនិត្យ ដើម្បីផ្ទៀងផ្ទាត់រវាងអ្នកបរិច្ចាគ និងអ្នកទទួលសរីរាង្គនោះដែរ។ កាលពីប៉ុន្មានឆ្នាំកន្លងទៅ មានក្រុមគ្រូពេទ្យឃោជាមួយក្រុមដែលធ្វើការនៅមន្ទីរពេទ្យព្រះកេតុមាលា ដែលក្នុងនោះមានឧត្តមសេនីយ៍ពីររូបផង ត្រូវបានចាប់ខ្លួន ដោយសារតែបានបង់ប្រាក់ទិញតម្រងនោមពីពលរដ្ឋកម្ពុជា។ ក្រោមការណែនាំពីក្រុមគ្រូពេទ្យចិន ពួកគេបានធ្វើការវះកាត់ប្តូរតម្រងនោមឲ្យអ្នកជំងឺជនជាតិចិនមួយចំនួន។ ក្រោយពីករណីនេះត្រូវបានដឹងឮជាសាធារណៈ អាជ្ញាធរបានដកការចោទប្រកាន់ ហើយមន្ទីរពេទ្យក៏បានចេញសេចក្តីថ្លែងការណ៍មួយដោយអះអាងថា ការប្តូរសរីរាង្គនេះគឺជាផ្នែកមួយនៃកម្មវិធីរបស់ក្រុមគ្រូពេទ្យជនជាតិចិន ដែលពេលនោះពួកគេមកបណ្តុះបណ្តាលក្រុមគ្រូពេទ្យផ្នែកឯកទេសវះកាត់របស់កម្ពុជា។

អ្នកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ប្រាប់វីអូអេថា ក្នុងឆ្នាំ២០១៩នេះ កម្ពុជាមិនមានករណីជួញដូរសរីរាង្គនោះទេ។ អ្នកស្រីថា ការណ៍នេះដោយសារកម្ពុជាពុំមានការវះកាត់ប្តូរសរីរាង្គ។ អ្នកស្រីមានប្រសាសន៍ថា៖ «ឆ្នាំមុនយើងធ្វើការឃាត់ខ្លួន ខ្លះនោះ ដោយសារគាត់ត្រៀមទេ។ គាត់ត្រៀមប្តូរគេលៀនឲ្យគេនៅក្រៅប្រទេស។ នៅកម្ពុជា ដោយសារយើងដឹងថារឿងហ្នឹងវាមិនអាចធ្វើបាន អញ្ចឹងយើងក៏តាមដាន វាអត់ដែលឃើញករណីហ្នឹងនៅក្នុងស្រុកទេ»។

ច្បាប់ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស ដែលសភាបានអនុម័ត ឆ្នាំ២០១៦ បានឲ្យដឹងថា៖ «ក្រសួងសុខាភិបាល ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងផ្តល់ការអនុញ្ញាតដល់មន្ទីរពេទ្យ និងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាលក្នុងការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស»។

វីអូអេបានព្យាយាមទាក់ទងមន្ត្រីសុខាភិបាល ដើម្បីសាកសួរព័ត៌មានលម្អិតអំពីព័ត៌មានស្តីការបរិច្ចាគនេះ។ ទាំងអ្នកស្រី ឱ វណ្ណឌីន អគ្គនាយកបច្ចេកទេស និងអ្នកនាំពាក្យនៃក្រសួងសុខាភិបាល និងលោក លី សូវ៉ាន់ អ្នកនាំពាក្យនៃក្រសួងសុខាភិបាលមួយរូបទៀត មិនទទួលទូរស័ព្ទ។ ឯលោក ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានលើកទូរស័ព្ទ ហើយប្រាប់ថា លោក«ជាប់ប្រជុំ» ហើយចុចបិទទូរស័ព្ទវិញ។

លោក អំ សំអាត នាយករងទទួលបន្ទុកផ្នែកឃ្លាំមើល និងការពារសិទ្ធិមនុស្សនៃអង្គការលីកាដូ (Licadho) យល់ថា ការបង្កើតឲ្យមានសេវាវះកាត់ផ្លាស់ប្តូរតម្រងនោមជារឿងល្អ សម្រាប់វិស័យសុខាភិបាល។ ទោះបីជាយ៉ាងណាក៏ដោយ លោកថា រដ្ឋាភិបាលគួរត្រៀមបង្ការករណីជួញដូរសរីរាង្គមនុស្សដែលធ្លាប់កើតមានពីមុនមក។ លោក សំអាត បានលើកឡើងថា៖ «អាហ្នឹងជាការល្អ ក៏ប៉ុន្តែសរីរាង្គទាំងអស់ហ្នឹងត្រូវប្រាកដថាបានឡើងដោយការស្រេបច្បាប់ បានមកពីការបរិច្ចាគ និងការស្របច្បាប់ផ្សេងៗ។ កន្លែងនេះដែលយើងត្រូវពិចារណា ហើយត្រូវមានវិធានការ និងច្បាប់ណាមួយកំណត់ឲ្យបានច្បាស់លាស់ទៅលើបញ្ហាទាំងអស់។ បើមិនអញ្ចឹងទេ យើងនៅតែមានការបារម្ភលើការជួយដូរសរីរាង្គ»។

នៅកម្ពុជា អត្រាអ្នកកើតជំងឺខូចតម្រងនោម ឬខ្សោយតម្រងនោមរ៉ាំរ៉ៃ មានការកើនឡើងគួរឲ្យកត់សម្គាល់។ អ្នកស្រាវជ្រាវលើជំងឺខូចតម្រងនោម ថាជំងឺនេះគឺជា«ឃាតករស្ងប់ស្ងាត់»៕

## កម្ពុជានិងប្រទេសជាង៩០ផ្សេងទៀតសន្យារួមគ្នាទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត

http://bayontv.com.kh/ 16/12/2019

ភ្នំពេញ៖ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសចំនួន៩៣ផ្សេងទៀតរួមទាំងអង្គការសង្គម ស៊ីវិលនានានៅលើពិភពលោកបានសន្យារួមគ្នាថា នឹងខិតខំធ្វើយ៉ាងណាកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណែតខណៈបញ្ហានេះត្រូវបានពិភពលោកចាត់ទុកថា ជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតដែលទាមទារឲ្យមានការសម្របសម្រួលឆ្លើយតបជាបន្ទាន់នោះ។

ថ្លែងប្រាប់ក្រោយពីវិលត្រឡប់មកពីចូលរួមកិច្ចប្រជុំថ្នាក់កំពូល ស្តីពីពង្រាងបទបញ្ញត្តិ និងគោលនយោបាយរបស់រដ្ឋាភិបាល នៃការប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទរបស់កុមារតាមប្រព័ន្ធ អ៊ីនធឺណិត អស់រយៈពេលជាច្រើនថ្ងៃនៅទីស្នាកលការកណ្តាលសហភាពអាហ្វ្រិកនៃទីក្រុងអាឌីសអាបេបានៅប្រទេសអេត្យូពីនារសៀលថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៩ នេះនៅព្រលានយន្តហោះអន្តរជាតិលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជបានលើកឡើងថា នៅក្នុងកិច្ចប្រជុំខាងលើនេះគឺថ្នាក់ដឹក នាំនៃប្រទេសជាសមាជិក រួមទាំង អង្គការសង្គមស៊ីវិល ឧស្សាហកម្មបច្ចេកវិទ្យា ភ្នាក់ងារអនុវត្តច្បាប់ វិទ្យាស្ថានស្រាវជ្រាវ និង ដៃគូខាន់ៗជាច្រើនទៀត មកពីបណ្តាប្រទេសចំនួន៩៣ ជុំវិញពិភពលោកបានសន្យារួមគ្នាទប់ស្កាត់និងប្រឆាំងឲ្យបានចំពោះការ កេងប្រវ័ញ្ចឲ្យបានចំពោះកុមារតាមរយៈប្រព័ន្ធបច្ចេកវិទ្យាទំនើបមួយនេះ។

សូមរំលឹកថា កាលពីកិច្ចប្រជុំកំពូល (WePROTECT) ប្រារព្ធធ្វើនៅប្រទេសអារ៉ាប់រួម និងចក្រភពអង់គ្លេសពីឆ្នាំ២០១៤ និងឆ្នាំ២០១៥ ថ្នាក់ដឹកនាំនៃបណ្តាប្រទេសនានា ក្នុងនោះក៏មានប្រទេសកម្ពុជា និងអង្គការអន្តរជាតិនានាបានទទួលស្គាល់ថាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណែត គឺជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរដោយទាមទារឲ្យមានការសម្របសម្រួលឆ្លើយតបនៅកម្រិតសកលចំពោះអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិតនេះ។

យ៉ាងណាក៏ដោយលោកជំទាវជូ ប៊ុនអេង បានប្រាប់ពិភពលោកថា កម្ពុជាត្រៀមខ្លួនជា និច្ចចំពោះការសហការជាមួយប្រទេសជាសមាជិកនៅលើពិភពលោកសម្រាប់ទប់ស្កាត់ និងការពារនៅទង្វើដ៏អាក្រកមួយនេះ ខណៈកម្ពុជានាពេលបច្ចុប្បន្នបានកំពុងយកចិត្តទុកដាក់ យ៉ាងខ្លាំងដូចភ្លៀងរលឹមសម្រាប់បញ្ហាមួយនេះ៕

## កម្ពុជា-អាមេរិក ប្តេជ្ញាពង្រឹងកិច្ចសហប្រតិបត្តិការវិស័យព្រហ្មទណ្ឌ និងបទល្មើសឆ្លងដែន

http://kleykley.sabay.com.kh/ ថ្ងៃនេះ ម៉ោង 08:48

លោក អង្គ វង្ស វឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងថ្នាក់ដឹកនាំក្រសួងយុត្តិធម៌ បានទទួលជាមួយលោក W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា និង មន្ត្រីស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ដើម្បីចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ កាលពីថ្ងៃទី១៦ ខែធ្នូ នៅក្រសួងយុត្តិធម៌។ ជាលទ្ធផលនៃកិច្ចពិភាក្សា ភាគីទាំងពីរសម្តែងនូវ សេចក្តីសោមនស្សរីករាយ ចំពោះ កិច្ចសហប្រតិបត្តិការ ប្រកបដោយលទ្ធផល ជាទីមោទនៈរវាងកម្ពុជា និងសហរដ្ឋអាមេរិកកន្លងមក ជាពិសេស ពាក់ព័ន្ធនឹង ការពង្រឹងសមត្ថភាពមន្ត្រី ជំនាញការ បង្ក្រាបបទល្មើសការផ្ទេរទណ្ឌិត និងការផ្តល់ជំនួយ ទៅវិញទៅមកនៅក្នុងវិស័យព្រហ្មទណ្ឌ។

ជាចុងក្រោយភាគីទាំងពីរបានឯកភាព និងប្តេជ្ញាក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ រវាងកម្ពុជា និងសហរដ្ឋអាមេរិក តាមរយៈការបន្តការបណ្តុះបណ្តាលធនធានមនុស្ស ការផ្តល់ជំនួយទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ ការប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែននិង បទល្មើសលាងលុយ ការការពារកុមារ និង ការអនុវត្តច្បាប់៕អត្ថបទ៖ កុសល

# ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ នៅខេត្តសៀមរាបលើកទី១៣ ឆ្នាំ២០១៩

https://www.facebook.com/deputygovernoryousophear/ លេខាធិការដ្ឋាន គខបជសៀមរាប 16-12-2019

នាព្រឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១៩នេះ នៅសាលមហោស្រពស្នាមញញឹមអង្គរខេត្តសៀមរាបមានប្រារព្ធទិវាជាតិលើកទី១៣ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ក្រោមប្រធានបទ(រួមសហការគ្នា ដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស) ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និង ជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោកជំទាវ យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការ គ ខ ប ជ លោកជំទាវ ស៊ិន ណម សមាជិកក្រុមប្រឹក្សាខេត្ត និងមានការនិមន្ត អញ្ជើញចូលរួមពីព្រះមេគណខេត្ត ឯកឧត្តម លោកជំទាវ អភិបាលរងខេត្តកំពង់ធំ បាត់ដំបង សមាជិកក្រុមប្រឹក្សាខេត្ត និង អស់លោក លោកស្រីជាថ្នាក់ដឹកនាំមន្ទីរ អង្គភាព គណៈអភិបាលក្រុង ស្រុក និង បណ្ដាអង្គការសង្គមស៊ីវិល ព្រមទាំងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ លោកគ្រូ អ្នកគ្រូ និស្សិត ក្រុមយុវជនកាយរឹទ្ធកម្ពុជា និងយុវជនកាកបាទក្រហម សិស្សានុសិស្ស និង ប្រជាពលរដ្ឋ ប្រមាណជិតមួយពាន់នាក់ចូលរួម ។

លោកស្រី យូ សុភា អភិបាលរងនៃគណៈអភិបាលខេត្ត និង ជាប្រធានលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប បានបញ្ជាក់អំពីគោលបំណងនៃការប្រារព្ធទិវាជាតិនេះ គឺដើម្បីបង្ហាញពីឆន្ទៈដ៏មុះមុតរបស់រាជរដ្ឋាភិបាល និង ប្រជាពលរដ្ឋគ្រប់រូប ក្នុងការរួមសហការគ្នា ដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស ព្រមទាំងបញ្ជាក់ពីលទ្ធផលដែលអនុវត្តបានក្នុងឆ្នាំ២០១៩ យុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស ការការពារ ស្តារនីតិសម្បទា សមាហរណកម្មនិងមាតុភូមិនិវត្តន៍ ការងារកិច្ចយុត្តិធម៌ និងកិច្ចសហប្រតិបត្តិការ ព្រមទាំងការងារបណ្ដុះបណ្ដាលលើកកម្ពស់សមត្ថភាពទៀតផង ។

បន្ទាប់ពីទស្សនានូវកម្រងភាពយន្តឯកសារទាក់ទងការជួញដូរ កេងប្រវ័ញ្ច និងធ្វើអាជីវកម្មផ្លូវភេទ តាមរយៈមេខ្យល់ ក្រុមអ្នករកស៊ីរត់ពន្ធមនុស្ស ដែលបានប្រើប្រាស់គ្រប់កលល្បិចបោកប្រាស់ ទៅតាមគ្រប់រូបភាព ហើយកុមារមួយចំនួនត្រូវបានធ្លាក់ខ្លួនទៅក្នុង អំពើពេស្យាចារ ដោយរងនូវអំពើហិង្សាក្នុងគ្រួសារ ល្បែងស៊ីសង ឬឪពុកម្ដាយយកទៅលក់ ដើម្បីសងបំណុលគេ និង កុមារមួយចំនួនត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ដែលត្រូវបានគេយកទៅលក់ និង កត្តាមួយចំនួនក៏ធ្វើឲ្យស្ត្រី និង កុមារងាយរងគ្រោះ។

ក្នុងនោះលោកជំទាវ ជូ ប៊ុនអេង ក៏បានលើកឡើងថា ទិវាជាតិលើកទី១៣ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៩ ក្នុងគោលបំណង បង្ហាញអំពីឆន្ទៈមុះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា និង ប្រជាពលរដ្ឋគ្រប់រូបក្នុងការរួមគ្នា បង្ការ បង្ក្រាប ផ្ដន្ទាទោស សង្គ្រោះ និង ការពារ ដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស ។ ម៉្យាងទៀតរាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តខិតខំប្រឹងប្រែងជម្នះគ្រប់ឧបសគ្គ ការលំបាក ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ដើម្បីឲ្យប្រជាជនកម្ពុជា និង មនុស្សជាតិ ទទួលបានការគោរពសិទ្ធិសេចក្តីថ្លៃថ្នូរ ផលប្រយោជន៍ស្របច្បាប់ និង ភាពសុខដុមរមនា ។ លោកជំទាវក៏បានបញ្ជាក់ ពីការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងកិច្ចសហការជាមួយបណ្ដាដៃគូពាក់ព័ន្ធនានា និងទាមទារឲ្យមានកិច្ចសហការ កាន់តែជាក់លាក់ពីបណ្ដាប្រទេសពាក់ ព័ន្ធទាំងឡាយក្នុងតំបន់ និង លើពិភពលោក ដើម្បីរួមគ្នាបង្ក្រាបអំពើជួញដូរមនុស្សគ្រប់រូបភាព និង ផ្ដន្ទាទោសជនល្មើសឲ្យបានម៉ឺងម៉ាត់ ដើម្បីកាត់បន្ថយ លុបបំបាត់ប្រសិទ្ធភាពបទល្មើស ។

លោកជំទាវ ជូ ប៊ុនអេង ក៏បានបន្តទៀតថា កម្ពុជានឹងពង្រឹងការអនុវត្តច្បាប់ អនុសញ្ញា កតិកាសញ្ញាអន្តរជាតិ ច្បាប់ជាតិ អនុស្សរណៈកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ផែនការសកម្មភាពរួម ផែនការជាតិ ព្រមទាំងបទដ្ឋានគតិយុត្តិដែលមានស្រាប់ ឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ ព្រមទាំងការគាំទ្រ លើកកម្ពស់កិច្ចខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់លំដាប់ថ្នាក់ ឲ្យមានលទ្ធភាព សមត្ថភាព និង ធនធានគ្រប់គ្រាន់ ក្នុងការបំពេញភារកិច្ចរបស់ខ្លួនឲ្យទទួលបានលទ្ធផលល្អ ។ ខ្លឹមសារនៃទិវាជាតិលើកទី១៣ ប្រយុទ្ធប្រឆាំងអំពើជួញដូរ

មនុស្ស១២ធ្នូ ឆ្នាំ២០១៩នេះ បានផ្តោតសំខាន់ចំពោះបទល្មើស ការពរពោះជំនួស ដែលជាបទឧក្រិដ្ឋមួយ ក្នុងការជួញដូរទារក នាំចេញទៅក្រៅប្រទេស ។ ម៉្យាងទៀត រាជរដ្ឋាភិបាលកម្ពុជា បានគាំទ្រការធ្វើទេសន្តប្រវេសន៍ការងារស្របច្បាប់ សម្រាប់ជាជម្រើស ក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និង សង្គម ។

លោកជំទាវ ជូ ប៊ុនអេង ក៏មានសង្ឃឹមជឿជាក់ថា ការប្រារព្ធទិវានៅថ្ងៃនេះជាស្មារតីយល់ដឹងដ៏មានសារៈសំខាន់បំផុត ក្នុងការផ្សព្វផ្សាយជាសាធារណៈ បំផុសកិច្ចចូលរួមក្នុងការអនុវត្តច្បាប់ ស្តីអំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ព្រមទាំងសូមបងប្អូនប្រជាពលរដ្ឋទាំងអស់ ផ្តល់ការគាំទ្រ បន្តការសហការជាមួយគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប ដើម្បីអនុវត្តច្បាប់នេះ ឲ្យកាន់តែមានប្រសិទ្ធិភាព និងជោគជ័យថែមទៀត ដើម្បីប្រជាជននិងប្រទេសជាតិយើង ៕

## មន្ទីរកិច្ចការនារីខេត្តស្ទឹងត្រែង ផ្សព្វផ្សាយការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ផ្សារភ្ជាប់ និងការអប់រំ

http://www.freshnewsasia.com/ 2019-12-17

**(ស្ទឹងត្រែង)៖** មន្ទីរកិច្ចការនារីខេត្តស្ទឹងត្រែង បានរៀបចំវេទិកាផ្សព្វផ្សាយស្តីពីការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរផ្សារភ្ជាប់និងការអប់រំយុវជន ក្រោមប្រធានបទ «យុវវ័យ និងប្រព័ន្ធបច្ចេកវិទ្យាក្នុងគោលបំណងឲ្យមជ្ឈដ្ឋានទូទៅបានជ្រួតជ្រាបផងដែរ»។ វេទិការធ្វើឡើងនៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡាខេត្ត កាលពីព្រឹកថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ ក្រោមអធិបតីលោកស្រី កែវ សារឿន ប្រធានគណៈកម្មាធិកាខេត្តលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ និងជាអភិបាលរង នៃគណៈអភិបាលខេត្ត និងលោកស្រី កុត ប៊ុនមី អនុប្រធានគណៈកម្មាធិកាខេត្តលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ និងជាសមាជិកក្រុមប្រឹក្សាខេត្ត ព្រមទាំងមានការចូលរួមពីសំណាក់ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សនិងអ្នកពាក់ព័ន្ធមួយចំនួនទៀត។

លោកស្រី សន សុខា បានឲ្យដឹងថា ពាក់ព័ន្ធនិងការផ្សព្វផ្សាយសីលធម៌សង្គមកន្លងមកនេះ គណៈកម្មាធិកាខេត្តលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរបានអនុវត្តការងារយ៉ាងសកម្ម ទៅលើសកម្មភាពអប់រំផ្សព្វផ្សាយក្នុងគោលបំណងឲ្យមជ្ឈដ្ឋានទូទៅបានជ្រួតជ្រាបផងដែរ។ លោកស្រីបន្ថែមថា កន្លងមកក្រុមការងារធ្លាប់រៀបចំជាវេទិការសំណួរចម្លើយតាមបណ្តាភូមិ-ឃុំ អនុវិទ្យាល័យ និងវិទ្យាល័យពាក់ព័ន្ធនិងសីលធម៌សង្គម និងតម្លៃស្ត្រីនេះ ហើយជាលទ្ធផលបង្ហាញថា បញ្ហាប្រឈមជាច្រើននៅតែបន្តកើតមានឡើងតាមរយៈឥរិយាបទ អាកប្បកិរិយាទង្វើមិនថ្លៃថ្នូរបស់មនុស្សក្នុងសង្គម តាមរយៈការស្លៀកពាក់ខើចមុខខើចក្រោយ ប្រព័ន្ធអេឡិចត្រូនិចព័ត៌មានវិទ្យា រូបអាសភាស ជាទម្រង់នៃអំពើអសីលធម៌ ធ្វើឲ្យប៉ះពាល់លើភាពថ្លៃថ្នូរបស់ប្រពៃណីខ្មែរហើយអាចបង្ករជាអំពើហិង្សាទៅលើស្ត្រីនិងកុមារ។

លោកស្រី កែវ សារឿន បានថ្លែងផងដែរថា បញ្ហាសីលធម៌សង្គមក៏ពាក់ព័ន្ធនិងបច្ចេកវិទ្យាទំនើបផងដែរ ជាក់ស្តែងយុវវ័យភាគច្រើនបានយកមធ្យោបាយព័ត៌មានវិទ្យាជាទុនក្នុងការទំនាក់ទំនង ស្វែងរកព័ត៌មាន និងចំណេះដឹងថ្មីៗ ប៉ុន្តែប្រសិនបើពួកគេយកទៅប្រើប្រាស់ក្នុងខុសឆ្គងណាមួយដោយទុច្ចរិក បង្កឲ្យមានអសីលធម៌នៅតាមបណ្តាញសង្គម និងប្រព័ន្ធអ៊ីនធឺណែត គឺជាប្រភពមួយជំរុញឲ្យមានការចាប់រំលោភសេពសន្ថវៈ អំពើហិង្សា និងការជួញដូរមនុស្ស ឆក់ ប្លន់ជាដើម។ លោកស្រីអភិបាលរងខេត្តបន្តថា ត្រូវជំរុញឲ្យអាជ្ញាធរពាក់ព័ន្ធត្រូវខិតខំប្រឹងផ្សព្វផ្សាយ អប់រំស្តីពី ការលើកកម្ពស់សីលធម៏សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរជាបន្តទៀត ដើម្បីឲ្យសង្គមកម្ពុជាក្លាយជាសង្គមដែលមានភាពថ្លៃថ្នូ និងលុបបំបាត់បាននូវរាល់បញ្ហាអសីលធម៌ដែលអាចកើតមានឡើង។ ជាមួយគ្នានេះ លោកស្រី ក៏បានកោតសរសើចំពោះមន្ទីរកិច្ចការនារីខេត្តដែលមានកិច្ចសហការល្អជាមួយ និងស្ថាប័នពាក់ព័ន្ធ ជាពិសេសមន្ទីរអប់រំ យុវជន និងកីឡា ដែលបានជំរុញឲ្យក្មេងស្រី ទទួលបានឱកាស ក្នុងការសិក្សាខ្ពង់ខ្ពស់ដូចក្មេងប្រុស ជាពិសេសសអប់រំ

បណ្តុះនូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូ ឥរិយាបទល្អ ជំរុញឲ្យយុវវ័យស្រលាញ់ និងការពារអត្តសញ្ញាណ វប្បធម៌ជាតិ៕

## ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៩

### ពិធីអបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ នៅស្ទួនមានជ័យ

https://grandnewsasia.com/ 18-12-2019

បន្ទាយមានជ័យ៖ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានអញ្ជើញជាអធិបតីនៅក្នុងការប្រារព្ធទិវាជាតិលើកទី១៥ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានការចូលរួមពីលោក លោកស្រី ដែលជាសមាជិកក្រុមប្រឹក្សាខេត្ត និងជាអភិបាលរងខេត្ត អភិបាល អភិបាលរងក្រុង-ស្រុក មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សប្រមាណជាង១២៨០នាក់ ដែលរៀបចំឡើងនៅស្ទួនមានជ័យ ខេត្តបន្ទាយមានជ័យ៕

### មជ្ឈមណ្ឌលឥស្ស៊ូមតិសម្រាប់កុមារជួយកុមាររងគ្រោះពីការរំលោភបំពាន

https://thmeythmey.com/ 18, Dec 2019 , 7:59 am

សៀមរាប៖ មូលនិធិ អេ ២១ (A21) ដែលជាស្ថាប័នដ៏ធំធ្វើការលើការការពារកុមាររងគ្រោះពីការរំលោភបំពានផ្សេងៗ បានដាក់ដំណើរការនៃមជ្ឈមណ្ឌលឥស្ស៊ូមតិសម្រាប់កុមារ អេ ២១ ប្រចាំខេត្តសៀមរាបនៅពាក់កណ្តាលខែធ្នូ កន្លងទៅ។ មជ្ឈមណ្ឌលនេះនឹងដើរតួយ៉ាងសំខាន់សម្រាប់ការការពារកុមាររងគ្រោះពីការរំលោភបំពានផ្លូវភេទ ការរំលោភបំពានកម្លាំងពលកម្ម ជួយប្រឹក្សាយោបល់ និងជ្រោមជ្រែងឱ្យកុមារទាំងនោះមានភាពរឹងមាំ និងគេចចេញពីភាពរងគ្រោះម្តងទៀត។ ក្រុមមន្ត្រីដែលពាក់ព័ន្ធលើកិច្ចការនេះជឿជាក់ថា មជ្ឈមណ្ឌលថ្មីនេះនឹងជួយឱ្យការទប់ស្កាត់ ការបង្ក្រាបបទល្មើសការជួញដូរកុមារនៅកម្ពុជាកាន់តែមានប្រសិទ្ធភាព។

មូលនិធិ អេ ២១ បានបើកការិយាល័យរបស់ខ្លួននៅកម្ពុជាអស់រយៈពេលជាង២ឆ្នាំមកហើយ ដើម្បីជួយកុមាររងគ្រោះគ្រប់ទម្រង់ ពិសេសកុមាររងគ្រោះពីការរំលោភបំពានផ្លូវភេទ រំលោភបំពានលើកម្លាំងពលកម្ម ដែលមានស្នាក់ការប្រចាំនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ មូលនិធិនេះបានធ្វើជាមួយ អេ ២១ នៅប្រទេសថៃ ដែលរកឃើញកុមារកម្ពុជារងគ្រោះពីទីនោះបញ្ជូនមកកម្ពុជាវិញ តាមរយៈការជួយប្រឹក្សាយោបល់ ការថែទាំបន្ទាប់ ផ្តល់ការអប់រំ និងជ្រោមជ្រែងដល់គ្រួសារកុមាររងគ្រោះឱ្យមានអាជីវកម្មខ្នាតតូចជាដើម។ នៅថ្ងៃទី១១ ធ្នូ មូលនិធិនេះ បានដាក់ឱ្យដំណើរការនៃមជ្ឈមណ្ឌលឥស្ស៊ូមតិសម្រាប់កុមារ អេ ២១ប្រចាំខេត្តសៀមរាប។

លោក ប៊ុក ទ្រី ប្រធានមជ្ឈមណ្ឌលបានឱ្យដឹងថា មជ្ឈមណ្ឌលនេះនឹងក្លាយជាទីតាំងមានសុវត្ថិភាព សម្រាប់ការផ្តល់ប្រឹក្សាយោបល់ដល់កុមាររងគ្រោះ កន្លែងផ្តល់ការការពារកុមារ កន្លែងសម្ភាសធ្វើកោសល្យវិច្ច័យ និងសហការជាមួយនគរបាលប្រឆាំងការជួញដូរកុមារ ក៏ដូចជាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីកុំឱ្យកុមារទាំងនោះទទួលរងនូវការរំលោភបំពានសាជាថ្មី។

កញ្ញា គ្រីស្ទីន ស្កាហ្វ នាយិកាប្រចាំប្រទេសនៃមូលនិធិ អេ ២១ លើកឡើងថាមជ្ឈមណ្ឌលនេះនឹងដើរយ៉ាងសំខាន់ក្នុងការផ្តល់សុវត្ថិភាពសម្រាប់កុមាររងគ្រោះ ការសម្ភាស និងពិនិត្យកោសល្យវិច្ច័យពីផលប៉ះពាល់ផ្នែកផ្លូវចិត្តដល់កុមាររងគ្រោះពីការរំលោភបំពាននានា។

ស្នងការរងទទួលបន្ទុកការជួញដូរមនុស្ស នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប លោកស្រី ឌួង ថាវរី មានប្រសាសន៍ថា កន្លងមកស្ថាប័នលោកស្រីបានធ្វើការងារជាច្រើនលើការជួញដូរកុមារក្នុងខេត្តសៀមរាប និងទទួលបានលទ្ធផលល្អប្រសើរ។ ចំពោះការដាក់ដំណើរការមជ្ឈមណ្ឌលឥស្ស៊ូមតិរបស់មូលនិធិ អេ ២១នេះ វានឹងក្លាយជាដៃគូមួយបន្ថែមទៀតសម្រាប់ការប្រយុទ្ធប្រឆាំងការជួញដូរកុមារនៅខេត្តសៀមរាប។ បទល្មើសដែលការិយាល័យប្រឆាំងការ

ជួញដូរមនុស្សខេត្តសៀមរាបធ្លាប់បានបង្រ្កាបបួមមានភាគច្រើនការរំលោភបំពានផ្លូវភេទ ការជួញដូរកុមារទៅធ្វើការនៅក្រៅប្រទេស ការកេងកម្លាំងពលកម្មកុមារ ដែលមាននៅតាមកន្លែងអាជីវកម្មមួយចំនួនដូចជានៅឡដុត្ជ និងកន្លែងកម្សាន្តជាដើម។ តាមការបញ្ជាក់ពីលោកស្រី ឌួង ថាវរី ការជួញដូរកម្លាំងពលកម្មកុមារនៅខេត្តសៀមរាប ច្រើនតែនៅកន្លែងឡដុត្ជ ដ្បិតថាអាណាព្យាបាលមិនសូវយល់ពីច្បាប់ និងយល់ថាកូនៗពួកគេ គួរតែធ្វើការដើម្បីរកប្រាក់ចិញ្ចឹមគ្រួសារ។

ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ លោក ជីវ ផល្លី ក្នុងពិធីសម្ពោធមជ្ឈមណ្ឌលតស៊ូមតិកុមារនៃមូលនិធិ អេ ២១ បានប្រាប់សារព័ត៌មានថ្មីៗថាកន្លងមកស្ថាប័នរបស់លោកបានសហការជាមួយនគរបាលប្រឆាំងការជួញដូរមនុស្សរាជធានី-ខេត្ត និងអង្គការក្រៅរដ្ឋាភិបាលដែលទាក់ទងនឹងយ៉ាងសកម្ម ធ្វើការស្រាវជ្រាវតាមរយៈការផ្តល់ព័ត៌មានតាមបណ្តាញសង្គម តាមរយៈការផ្តល់ព័ត៌មានពីសាក្សី ឪពុកម្តាយ ឬអាណាព្យាបាលជនរងគ្រោះ។ល។ ក្រោយទទួលបានព័ត៌មានទាំងនោះ កម្លាំងជំនាញបានចុះបង្ក្រាបភ្លាមៗដើម្បីឆ្លើយតបបទល្មើស និងបើកការស៊ើបអង្កេត ស្វែងរកជនល្មើសមកផ្តន្ទាទោស។ បន្ទាប់ពីជួយសង្គ្រោះបានហើយ កុមាររងគ្រោះនឹងត្រូវបញ្ជូនទៅកាន់អង្គការដៃគូនានាដើម្បីទទួលបានការថែទាំ និងបង្រៀនវិជ្ជាជីវៈផ្សេងៗ។ ពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទកុមារ នៅពេលថ្មីៗនេះបានលេចចេញតាមប្រព័ន្ធអនឡាញដែលកិច្ចការនេះត្រូវបានកម្លាំងជំនាញនៃនាយកដ្ឋានការជួញដូរមនុស្ស សហការជាមួយនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ស្រាវជ្រាវចាប់ជនល្មើសជាបន្តបន្ទាប់។

ការជួញដូរនិងរំលោភបំពានកុមារមានច្រើនទម្រង់ សូមស្តាប់ការពន្យល់របស់លោក ជីវ ផល្លី ដូចតទៅ៖« ការជួញដូរកុមារមានច្រើនទម្រង់ មានន័យថាជួញដូរកុមារយកទៅបម្រើសេវាកម្មផ្លូវភេទ ឬទាញប្រយោជន៍ពីការរួមភេទរបស់កុមារ ឬយកកុមារទៅលក់ដើម្បីបម្រើសេវាផ្លូវភេទ យើងមានករណីយកកុមារទៅបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍នៅក្រៅប្រទេស ការបង្ខំឱ្យការ...ការបង្ខំពលកម្មកុមារ ទម្រង់ផលិតសម្ភារអាសអាភាសឬមួយមានការរំលោភបំពានផ្លូវភេទតាមរយៈការទាញប្រយោជន៍ទៅតាមប្រព័ន្ធអ៊ីនធឺណិត...»។ ការរំលោភបំពានកុមារ បង្កើតឱ្យមានបញ្ហាផ្លូវចិត្តដល់កុមារ ហើយវាក៏ជាបន្ទុកមួយដល់សង្គមផងដែរ។ ដើម្បីដោះស្រាយ ក៏ដូចជាជួយសម្រាលបន្ទុកកិច្ចការនេះ ក្រសួងពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន បានប្រឹងប្រែងបង្កើតមជ្ឈមណ្ឌលដើម្បីជួយកុមាររងគ្រោះទាំងនោះ។ ក្រោយជួយសង្គ្រោះ កុមារអាចរស់នៅ រៀនសូត្រ និងទទួលបានចំណេះជំនាញវិជ្ជាជីវៈ ដើម្បីកែប្រែជីវិតរបស់ពួកគេ។ កុមារខ្លះ បន្តរស់នៅនិងរៀនសូត្ររហូតដល់អាយុ១៦ឬ១៧ឆ្នាំ ហើយខ្លះត្រូវឪពុកម្តាយស្នើសុំយកទៅរស់នៅជុំគ្រួសារវិញក៏មាន តែពួកគេស្ថិតក្រោមការតាមដាន ដើម្បីកុំឱ្យមានការរងគ្រោះម្តងទៀត៕

## សមត្ថកិច្ចចាប់ខ្លួនស្ត្រីរកស៊ីផ្លូវភេទ និងអ្នកគកជេរជាច្រើននាក់នៅជុំវិញរង្វង់មូលវត្តភ្នំ

https://khmernote.com/news/ 18-12-2019

បើយោងតាមការបញ្ជាក់ពី រដ្ឋបាលខណ្ឌដូនពេញ បានឲ្យដឹងថា ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោក សុខ ពេញវុធ អភិបាលនៃគណៈអភិបាលខណ្ឌដូនពេញ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង២២ និង០០នាទី កំលាំងជំនាញខណ្ឌ ប៉ុស្តិ៍នគរបាលវត្តភ្នំបានចុះបង្ក្រាប ករណីស្ត្រីស៊ីផ្លូវភេទ និងអ្នកគកជេរ(អ្នកចាប់ម៉ូយ) ស្ថិតនៅចំណុចផ្លូវលេខ ៩២. ៩៤. ៩៦ និងជុំវិញរង្វង់មូលវត្តភ្នំ រាជធានីភ្នំពេញ។ ជាលទ្ធផលនៃកិច្ចប្រតិបត្តិការនេះ បានបញ្ចប់នៅវេលាម៉ោង ០២ និង០០នាទីរំលងអាធ្រាតចូលថ្ងៃទី១៨ កម្លាំងសមត្ថកិច្ចប្រមូលបានសរុបរួមចំនួន០៦នាក់ ស្រី០៦នាក់ ហើយអធិការដ្ឋានបានធ្វើការបញ្ជូនស្ត្រីរកស៊ីផ្លូវភេទ ខាងលើទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ៕

## នារីរងគ្រោះ ២នាក់ ដែលចាញ់បោកគេទៅស្រុកចិន ពេលនេះ ត្រលប់មកផ្ទះវិញហើយ

https://www.chnchannel.com/ On Dec 18, 2019

**ព្រះសីហនុ៖** នាវេលាម៉ោង០៧ជាង ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ បានទទួលមាតុភូមិនិវត្តន៍ស្ត្រីរងគ្រោះ ដោយអំពើជួញដូរ ចំនួន០២នាក់ មកដល់ព្រះរាជាណាចក្រកម្ពុជា តាមជើងយន្តហោះលេខ LQ809 (WUH-KOS) ពីទីក្រុង WUHEN ប្រទេសចិន មកខេត្តព្រះសីហនុ ដោយស្ថានអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុង ធុងឈីង បានរៀបចំឯកសារធ្វើដំណើរ ជូនស្ត្រីរងគ្រោះ។

សមត្ថកិច្ចបានឲ្យដឹងថា ស្ត្រីរងគ្រោះ ដោយអំពើជួញដូរទាំង ០២នាក់នេះ មានឈ្មោះ គឹម សុជា អាយុ ៣៣ ឆ្នាំ ស្រុកកំណើត នៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និងឈ្មោះ ចាប ចាន់ធី អាយុ ២៦ឆ្នាំ ស្រុកកំណើត នៅស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។ ក្រោយពីធ្វើការសាកសួររួចមក កម្លាំងនគរបាលអន្តោប្រវេសន្តប៉ុស្តិ៍ បានប្រថាប់ត្រាចូលប្រទេស លើលិខិតបើកផ្លូវជូនស្ត្រីរងគ្រោះខាងលើ បន្ទាប់មកតំណាងក្រសួង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតសម្បទា រួមទាំងកម្លាំងស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានចូលរួមទទួលស្ត្រីរងគ្រោះ ហើយបញ្ជូនទៅរាជធានីភ្នំពេញ៕ដោយ វ៉ឺន កញ្ញា

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលរដ្ឋខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial/ December 16 at 4:26 PM •

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ នារសៀលថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ បានទទួលពលរដ្ឋខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែន ទៅធ្វើការខុសច្បាប់ នៅប្រទេសថៃ ដែលចេញតាមច្រកបឹងត្រកួន ខេត្តបន្ទាយមានជ័យ៕

## អាជ្ញាធរថៃបញ្ជូនពលរដ្ឋខ្មែរម្នាក់តាមច្រកអន្តរជាតិជាំបន្ទាប់ពីដោះលែងពីពន្ធនាគារ

http://www.rasmeinews.com/ December 17, 2019, 9:38 PM

ដោយបាយ័ន/ឧត្តរមានជ័យ:អាជ្ញាធរថៃបានបញ្ជូនពលរដ្ឋខ្មែរម្នាក់តាមច្រកអន្តរជាតិជាំឱ្យត្រឡប់មកស្រុកកំណើតវិញបន្ទាប់ពីដោះលែងពីពន្ធនាគារនៅស្រុកខាន់ដាឡាក់ខេត្តស៊ីសាកេតប្រទេសថៃ ។ពីបទឆ្លងដែនខុសច្បាប់ចូលកាប់ឈើគ្រញូងក្នុងទឹកដីថៃ។ការប្រគល់និងទទួលបានធ្វើឡើងនៅច្រកអន្តរជាតិជាំស្រងាំក្នុងទឹកដីស្រុកអន្លង់វែងខេត្តឧត្តរមានជ័យនៅថ្ងៃទី១៧ខែធ្នូឆ្នាំ២០១៩។

សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំស្រងាំបាននិយាយថាពលរដ្ឋខ្មែរដែលត្រូវបានថៃបញ្ជូនមកគឺមានឈ្មោះឈឺនជាភេទប្រុសអាយុ៤៥ឆ្នាំរស់នៅភូមិបន្ទាយចាស់ឃុំព្រះប្រឡាយស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។សមត្ថកិច្ចបានបន្តថាជនឈ្មោះ ឈឺនជាត្រូវបានចាប់ខ្លួននៅថ្ងៃ១២ ខែមករា ឆ្នាំ២០១៨ កន្លងទៅពីបទឆ្លងដែនកាប់ឈើដោយចូលតាមច្រកអូរ៥០។ ត្រូវបានបញ្ជូនទៅដាក់ពន្ធនាគារនៅស្រុកខាន់ដាឡាក់ខេត្តស៊ីសាកេតប្រទេសថៃរហូតដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩នេះទើបដោះលែងរួចបញ្ជូនមកស្រុកកំណើតវិញ៕S/

## ពលករខ្មែរ ០២គ្រួសាររងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ក្នុងប្រទេសថៃអស់រយៈពេលជាង៣ឆ្នាំ

https://www.facebook.com/LabourOfficial/ ពលករ 17-12-2019

ពលករខ្មែរ ០៤នាក់ ចូលមកធ្វើការនៅក្នុងប្រទេសថៃ ដោយស្របច្បាប់ ប៉ុន្តែរងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ដោយទទួលបានប្រាក់ឈ្នួលតិចជាងប្រាក់គោលដែលច្បាប់ប្រទេសថៃកំណត់ទៅទៀត ។ ពលករខ្មែរនោះមាន ឈ្មោះ ខា សុខឃីម ភេទប្រុស ២៩ឆ្នាំ ស្រុកកកំណើតរស់នៅភូមិកំពង់ស្មោរ ឃុំទំពាំងឬស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

បានប្រាប់ឲ្យដឹងថាគាត់និងប្រពន្ធព្រមទាំងបងថ្លៃ មានគ្នា ០៤នាក់បានមកធ្វើការចញ្ចឹមមាន់នៅក្នុងកសិដ្ឋានមួយ មួយកន្លែងនៅខេត្តឈុនបុរី ប្រទេសថៃ អស់រយៈពេលជិត ៤ឆ្នាំហើយ ប៉ុន្តែប្រាក់ឈ្នួលដែលគាត់ទទួលបានក្នុង ១ខែ ត្រឹមតែ ៦០០០បាត ហើយបច្ចុប្បន្ននេះថៅកែទើបតែតម្លើងអោយបានត្រឹម៦.៥០០បាតប៉ុណ្ណោះ។ គាត់បន្តទៀតថា នៅកន្លែងធ្វើការថៅកែផ្តល់អោយជូនតែបន្ទប់ស្នាក់នៅប៉ុណ្ណោះ ចំណែកថ្លៃហូបអាហារគាត់ត្រូវចំណាយប្រាក់ទិញដោយខ្លួនឯងអស់។

ពេលវេលានិងម៉ោងធ្វើការគាត់ត្រូវក្រោកតាំងពីម៉ោង ៣ភ្លឺទៀបភ្លឺដើម្បីដាក់ចំណីអាហារអោយសត្វមាន់ រហូតដល់ម៉ោង ៣រសៀលទើបបានសម្រាក បើពេលខ្លះគេត្រូវការចាក់ថ្នាំមាន់គាត់ត្រូវធ្វើការបន្ថែមម៉ោងថែមទៀត ប៉ុន្តែប្រាក់ខែនៅដដែល។ ចំពោះរឿងទាមទារប្រាក់ដំឡើងប្រាក់ឈ្នួលវិញគាត់មិនហ៊ានទៅប្តឹងនោះទេព្រោះថៅកែ ជាមនុស្សមានឥទ្ធិពល មានខ្នងបង្អែកជាអ្នកធំច្រើននៅក្នុងខេត្តនេះ។ កន្លងមកធ្លាប់មានមិត្តភ័ក្តិណែនាំអោយគាត់ប្តូរការងារដែរប៉ុន្តែគាត់មិនហ៊ានប្តូរនោះទេព្រោះពិបាកនៅការដំណើរការរឿងឯកសារ ដូច្នេះទើបទ្រាំធ្វើការដល់បច្ចុប្បន្ននេះ ។ ហើយមូលហេតុដែលគាត់ចេញផ្តល់ព័ត៌មានលើកនេះគឺដោយសារគាត់ឃើញតារាងប្រាក់ឈ្នួលគោលដែលច្បាប់ការងារថៃកំណត់នោះគឺសម្បតែដាក់ស្តែងគាត់ធ្វើការ អស់រយៈពេលជិត ៤ឆ្នាំទទួលបានប្រាក់ឈ្នួលក្នុង ១ថ្ងៃត្រឹមតែ ២១៦បាត ប៉ុណ្ណោះ។

## ពលករខ្មែរមួយក្រុមធ្វើការនៅថៃស្វែងយល់ពីសិទ្ធិការងារ

https://www.rfa.org/khmer/ ដោយ សេក បណ្ឌិត 2019-12-15

តំណាងក្រុមពលករខ្មែរដែលធ្វើការនៅប្រទេសថៃប្រមាណ ៥០នាក់ នៅព្រឹកថ្ងៃទី១៦ ធ្នូ បានចូលរួមវគ្គអប់រំអំពីសិទ្ធិការងារនៅខេត្តជាប់ទីក្រុងបាងកក។ មន្ត្រីសង្គមស៊ីវិល លើកឡើងថាវគ្គអប់រំនេះជាប្រយោជន៍ដល់ពលករ ឱ្យបានពួកគេយល់ដឹងច្បាប់ ដើម្បីដោះស្រាយនៅពេលដែលពួកគាត់មានបញ្ហាក្នុងពេលបំពេញការងារនៅក្រៅប្រទេស។ តំណាងពលករខ្មែរធ្វើការរោងចក្រកាត់ដេរនៅខេត្តជាប់ទីក្រុងបាងកកប្រទេសថៃ លោក រិន មករា ប្រាប់អាស៊ីសេរីក្រោយពេលបញ្ចប់វគ្គអប់រំថា អ្នកចូលស្វែងយល់អំពីសិទ្ធិការងារនេះភាគច្រើនជាតំណាងពលករខ្មែរនៅខេត្តជុំវិញទីក្រុងបាងកក ដោយមានអង្គការសហភាពការងារផ្នែកសំណង់ហៅកាត់ ស៊ី អឹម អាយ ហ្វាយ (CMIY) របស់ថៃ ចុះទៅអប់រំពួកគាត់ នៅខេត្តសមុទ្រប្រាកាន (Samut Prakan)។ លោក បន្តថា ពលករបានលើកយកបញ្ហាសំខាន់មួយចំនួនដែលជួបប្រទះនៅកន្លែងធ្វើការងារដាក់ជូនដល់វាគ្មិន ដើម្បីឱ្យជួយដោះស្រាយ មានដូចជា ថៅកែមិនព្រមបើកប្រាក់ខែជូនពលករ គ្រោះថ្នាក់ផ្សេងនៅកន្លែងការងារដោយមិនមានអ្នកទទួលខុសត្រូវ និងករណីរោងចក្រខ្លះមិនព្រមចេញលិខិតបញ្ជាក់ជូនពលករ នៅពេលដែលពួកគាត់ប្តូរកន្លែងការងារជាដើម៖ «គឺគោលបំណងរបស់អង្គការគឺគាត់ចង់ឱ្យពួកខ្ញុំស្គាល់ពីសិទ្ធិរបស់ខ្លួនឯង កុំឱ្យខ្លាច ដូចជាមានការជួបគ្រោះថ្នាក់ចរាចរគេមិនបង់ប្រាក់ឱ្យ យើងអត់ហ៊ានតវ៉ាតអីអីចឹង ។អីចឹងគាត់ផ្តល់ចំណេះដឹងហ្នឹងឱ្យយើងហ៊ានប្រឈមមុខច្បាប់ ហ៊ានងើបតស៊ូនូវអ្វីដែលថៅកែរំលោភមកលើពលករហើយមិនទទួលខុសត្រូវ»។

ពលកររោងចក្រកាប់សាច់ជ្រូកនៅខេត្តជាប់ទីក្រុងបាងកក លោក ហ៊ិន រ៉ាប៊ូ ថ្លែងថា លោកមកធ្វើការនៅប្រទេសថៃប្រមាណ ៩ឆ្នាំហើយ ប៉ុន្តែនៅតែរកប្រាក់មិនបានធ្វើផ្ទះសមរម្យនៅឡើយទេ។ លោកបន្តថា នៅកន្លែងការងាររបស់លោកមានពលករខ្មែរប្រមាណ ១ពាន់នាក់កំពុងធ្វើការ ក្នុងនោះមានពលករខ្លះត្រូវបានថៅកែដកហូតលិខិតឆ្លងដែន ដោយសារមិនទាន់សងប្រាក់ដែលខ្ចីគេធ្វើលិខិតឆ្លងដែនគ្រប់នៅឡើយ។ លោកបន្ថែមថា ថៅកែថៃភាគច្រើនមិនសូវយកចិត្តទុកដាក់មកលើពលករខ្មែរដូចការជួយពលករជាតិសាសន៍ដទៃនោះទេ ហើយពួកលោកក៏ធ្លាប់ប្តឹងទៅស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកកឱ្យជួយដែរ ប៉ុន្តែមិនមានមន្ត្រីណាចុះមកជួយពួកគាត់នោះទេ ដោយលើកហេតុផលថា បុគ្គលិកតិចមិនអាចជួយបានទាន់ពេល។លោកបញ្ជាក់ថា ក្រោយពីទទួលបានការអប់រំសិទ្ធិការងារនេះរួចហើយ ធ្វើឱ្យពួកលោកមានភាពក្លាហាន ព្រោះបានយល់ដឹងពីច្បាប់ការងារ និងមានអង្គការចាំជួយប្រសិនបើ

មានពលករណាមានបញ្ហាពេលបំពេញការងារនៅថ្ងៃក្រោយ៖ «គេនិយាយអំពីបញ្ហារស់នៅក្នុងសង្គមថៃ យើងបានសិទ្ធិអីខ្លះ ព្រោះបងប្អូនខ្មែរភាគច្រើនអត់ដឹងថាការរស់នៅប្រទេសថៃមានសិទ្ធិរបៀបម៉េចទេ។នៅក្នុងនេះគាត់បាននិយាយប្រាប់ពួកខ្ញុំថា យើងមានសិទ្ធិគ្រប់យ៉ាងនូវអ្វីដែលធ្វើស្របច្បាប់ប្រទេសថៃ និយាយទៅគាត់មិនឱ្យយើងខ្លាចថៅកែ ដូចពីមុនអីខ្ញុំចេះតែខ្លាចថៅកែ ប៉ុន្តែដល់ពេលខ្ញុំបានអប់រំអីចឹងទៅខ្ញុំមានកម្លាំងចិត្តថាយើងបានអង្គការមួយមកជួយយើង ពេលមានរឿងអីយើងរកគាត់ឱ្យគាត់ជួយ ពីមុខមកពេលមានបញ្ហាអីយើងមិនទៅរកអ្នកណា»។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរទទួលបន្ទុកផ្នែកពលករប្រចាំនៅប្រទេសថៃ លោក ចិន សំណាង ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេនៅថ្ងៃទី១៦ ធ្នូ ដោយទូរស័ព្ទចូល ពុំមានអ្នកទទួល។ ទោះជាយ៉ាងណាស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ធ្លាប់អះអាងថា ស្ថានទូតតែងតែយកចិត្តទុកដាក់ជួយដល់ពលករខ្មែរ ដែលកំពុងស្នាក់នៅនិងធ្វើការក្នុងប្រទេសថៃជាប្រចាំ។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្ស អាដហុក ប្រចាំនៅខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគារ មានប្រសាសន៍ថា ពលករខ្មែរធ្វើការនៅប្រទេសថៃដែលរងគ្រោះពេញបំពេញការងារភាគច្រើន បណ្ដាលមកពីខ្វះការយកចិត្តទុកដាក់ពីអាជ្ញាធរកម្ពុជា ដែលធ្វើឱ្យថៅកែជនជាតិថៃបន្តធ្វើបាបពួកគាត់ម្ដងហើយម្ដងទៀត។លោកបន្តថា ការអប់រំនេះនឹងជួយឱ្យពលករយល់ដឹងអំពីច្បាប់ការងារ ដើម្បីប្ដឹងទៅអាជ្ញាធរថៃឱ្យជួយរកខុសត្រូវជូនពួកគាត់បាន៖ «ព្រោះកន្លងមកយើងឃើញមានខ្មែររងគ្រោះដោយសារថៃចាញ់សម្លាប់ ថៃធ្វើបាបចាប់បង្ខាំងមនុស្សឱ្យស្រាតខោអាវ វាយក្បាលធ្វើទារុណកម្មអី រហូតដល់ពេលនេះក៏នៅមិនទាន់មានយុត្តិធម៌នៅឡើយទេ។អីចឹងបើមានខាងអង្គការនៅប្រទេសថៃ ចាប់ផ្ដើមជួយពង្រីកនិងពន្យល់អំពីច្បាប់នេះ គឺស្រួលដល់ខ្មែរធ្វើការទាមទារដោយសន្តិវិធីដើម្បីឱ្យរដ្ឋាភិបាលថៃដោះស្រាយជូនពួកគាត់បាន»។

របាយការណ៍ក្រសួងការងារឱ្យដឹងថា ពលករខ្មែរធ្វើការនៅក្នុងប្រទេសថៃមានជាង១លាន ១សែននាក់ ក៏ប៉ុន្តែបើតាមការប៉ាន់ស្មានក្រៅផ្លូវការរបស់អង្គការ សង់ត្រាល់ (CENTRAL) ពលករខ្មែរនៅប្រទេសថៃអាចមានចន្លោះពី ១លាន ៨សែន ទៅ ២លាននាក់ ដោយរាប់ទាំងពលករស្របច្បាប់ និងមិនស្របច្បាប់។

ពលករដែលទទួលបានអប់រំនិយាយថាអង្គការសហភាពការងារផ្នែកសំណង់ ស៊ី អឹមអាយ ហ្វាយ (CMIY) នឹងជួយផ្នែកច្បាប់ដល់ពលករខ្មែរ ប្រសិនបើពួកគេមានការរំលោភសិទ្ធិការងារឬមានបញ្ហាផ្សេងៗ នៅពេលបំពេញការងារនៅប្រទេសថៃ គឺអាចទាក់ទងទៅកាន់បុគ្គលិករបស់អង្គការនេះតាមលេខទូរស័ព្ទ ០៨៩ ៥៣៣ ៧៩៦៣៕

## ឧត្តមនាវីឯក ទៀ សុខា ចូលរួមប្រជុំ ផ្លាស់ប្ដូរព័ត៌មាន លើផ្ទៃសមុទ្រ ជាមួយភាគីថៃ

https://www.dap-news.com/ ByPH104 Posted on December 18, 2019

ភ្នំពេញ ៖ ឧត្តមនាវីឯក ទៀ សុខា មេបញ្ជាការរងកងទ័ពជើងទឹក និងជាមេបញ្ជាការ ទីបញ្ជាការជួរមុខ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី១១ ស្ដីពី ការផ្លាស់ប្ដូរព័ត៌មានលើផ្ទៃសមុទ្រនាំទំនិញ ចេញ-ចូល ខុសច្បាប់ ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស និងការរុករក ជួយសង្គ្រោះគ្រោះមហន្តរាយ នៅបញ្ជាការដ្ឋាន យោធភូមិភាគទី១ នៃកងទ័ពជើងទឹកភូមិន្ទថៃ ខេត្តឈុនបុរី ប្រទេសថៃ។ ក្នុងកិច្ចប្រជុំមានការចូលរួម ពីទីបញ្ជាការជួរមុខអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសន្តិសុខ លម្ហសមុទ្រកម្ពុជា ជាមួយបញ្ជាការដ្ឋានយោធភូមិភាគទី១ នៃកងទ័ពជើងទឹកភូមិន្ទថៃ ៕

# ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៩

## មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ ថ្លែងជំរុញគ្រប់ភាគីពាក់ព័ន្ធរួមគ្នាបង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ និងការពារ ដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស

https://www.information.gov.kh/ ធ្នូ 18, 2019 ស វិជ័យ

AKP បន្ទាយមានជ័យ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ ៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងអំពាវនាវ ជំរុញគ្រប់ភាគីពាក់ព័ន្ធទាំងអស់បន្តរួមគ្នាបង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ និងការពារ ដើម្បីកម្ពុជាគ្មាន អំពើជួញដូរមនុស្ស។ ការថ្លែងបែបនេះរបស់លោកជំទាវ ជូ ប៊ុនអេង បានធ្វើឡើងក្នុងទិវាជាតិលើកទី១៣ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ ធ្នូ ដែលអាជ្ញាធរខេត្តបន្ទាយមានជ័យរួមជាមួយ អង្គការដៃគូបានប្រារព្ធធ្វើនៅសួនមានជ័យក្រុងសិរីសោភ័ណ កាលពីព្រឹកថ្ងៃពុធ ៧រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩នេះ ដែលមានថ្នាក់ដឹកនាំមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ប្រមាណជាង១២៨០នាក់ បានចូលរួមអបអរសាទរក្នុងទិវានោះ។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃលោកជំទាវ ជូ ប៊ុនអេង បានមានប្រសាសន៍ថា អំពើជួញដូរមនុស្សគឺជាបទល្មើសឧក្រិដ្ឋដែលមិនអាចអត់អោនឱ្យបាន ហើយក៏ជាការរំលោភទៅលើសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរផងដែរ ដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ។ លោកជំទាវ ជូ ប៊ុនអេង បានបញ្ជាក់ទៀតថា កត្តាដែលជំរុញឱ្យមានការជួញដូរមនុស្ស គឺបណ្តាលមកពីភាពក្រីក្រកង្វះខាតផ្នែកសិក្សាអប់រំ ភាពអត់ការងារធ្វើ ការអើសអើងផ្នែកភេទ អំពើហិង្សា និងការរំលោភបំពាននៅក្នុងសង្គមគ្រួសារ ស្ថានភាពជម្លោះក្នុងគ្រួសារ កង្វះខាតនូវការជ្រើសរើស និងស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់ជាដើម។ ជាមួយនោះលោកជំទាវក៏បានធ្វើការអំពាវនាវដល់អាជ្ញាធរដែនដីកម្លាំងសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងអង្គការដៃគូពាក់ព័ន្ធ ត្រូវរួមគ្នាបន្តសកម្មភាពទប់ស្កាត់ និងបង្ក្រាបរាល់ទម្រង់ នៃការជួញដូរមនុស្សនៅកម្ពុជា ពិសេសនៅតាមតំបន់ជាប់ព្រំដែនដែលតែតែងកើតមាន ការជួញដូរមនុស្សនេះច្រើនជាងគេនោះគឺការជួញដូរកម្លាំងពលកម្ម និងការជួញដូរផ្លូវភេទ ជាពិសេសលើស្ត្រីនិងកុមារ។

អភិបាលរងខេត្តបន្ទាយមានជ័យលោកស្រីប៊ុកណាឌី បានឱ្យដឹងថា យោងតាមរបាយការណ៍បានបង្ហាញឱ្យឃើញថាបញ្ហាជួញដូរមនុស្សត្រូវបានរកឃើញស្ថិតនៅក្រោមរូបភាពទេសន្តប្រវេសន៍ការងារ ដូចជាកន្លែងកម្សាន្តសប្បាយ អាពាហ៍ពិពាហ៍អន្តរជាតិ ទេសចរណ៍ការងារ និងការស្វែងរកគូស្រករនៅក្រៅប្រទេសជាដើមក្នុងនោះ អំពើជួញដូរមនុស្សមានពីរប្រភេទដែលត្រូវបានជួបប្រទះជាញឹកញាប់ជាងគេនោះគឺការជួញដូរកម្លាំងពលកម្ម និងការជួញដូរផ្លូវភេទ។ លោកស្រីប៊ុកណាឌីឱ្យដឹងទៀតថា ការជួញដូរមនុស្ស ឆ្លងកាត់ព្រំដែនទៅក្រៅប្រទេស គឺជាគោលដៅចម្បងដែលប្រជាជនកម្ពុជាត្រូវបានគេជួញដូរឱ្យទៅសុំទានធ្វើការងារក្នុងរោងចក្រកសិដ្ឋានចម្ការការងារផ្ទះនេសាទសមុទ្រ និងអាជីវកម្មផ្លូវភេទជាដើម៕ ដោយឈុនសារ៉ាត

## ថៃចាប់បញ្ជូនពលករខ្មែរតាមច្រកប៉ោយប៉ែត10ខែ ចំនួន 11.118 នាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៩ ម៉ោង ១៤:៥៦ ណុប រក្សា

ខេត្តបន្ទាយមានជ័យ ៖ គណៈកម្មាធិការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សថ្នាក់ខេត្ត(គ.ខ.ប.ជ) កាលពីថ្ងៃទី១៦ ខែធ្នូ កន្លងទៅនៅសាលាខេត្ត បានប្រជុំបូកសរុបលទ្ធផលការងារក្នុងរយៈពេល១០ខែ ដើមឆ្នាំ២០១៩ ក្រោមអធិបតីភាពលោកស្រី ប៉ុក ណាឌី អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ខេត្ត ដោយមានការរួមចូលពីសំណាក់អ្នកពាក់ព័ន្ធ និងអង្គការដៃគូ ។ តាមរបាយការណ៍ឱ្យដឹងថា ក្នុងរយៈពេល១០ខែដើមឆ្នាំ២០១៩នេះ ពលករទេសន្តប្រវេសន៍(ពលករខ្មែរ) ដែលអាជ្ញាធរថៃបញ្ជូនមកវិញ

មានចំនួនសរុប១១.១៩៨នាក់(ស្រី ៣.៤៨៥នាក់)ក្នុងនោះកុមារចំនួន១.៤៥៧នាក់(កុមារី៥៩៣នាក់)។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ ដែលមានចំនួន២៦.៩៨១នាក់ ឃើញថាមានការថយចុះចំនួន១៥.៨៦៣នាក់ ។ ឯសពពលករខ្មែរដែលអាជ្ញាធរថៃបញ្ជូនមកតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត តាមតួលេខរបស់ការិយាល័យអន្តោប្រវេសន៍មានចំនួន៥នាក់(ស្រីម្នាក់)។

លោកស្រី ប៉ុក ណាឌី បានមានប្រសាសន៍ ជំរុញដល់អ្នកពាក់ព័ន្ធត្រូវ៖

-បន្តអប់រំ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យបានយល់ដឹងពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។

-បន្តសហការជាមួយមន្ទីរទេសចរណ៍ខេត្ត ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ហាងខារ៉ាអូខេ កន្លែងកម្សាន្ត កន្លែងម៉ាស្សា ទប់ស្កាត់សកម្មភាពជួញដូរស្ត្រី និងកុមារ។

-បន្តលើកកម្ពស់បញ្ហាសុខុមាលភាពកុមារនៅក្នុងមណ្ឌល និងក្រៅមណ្ឌល។

-បន្តកិច្ចសហការជាមួយអង្គការដៃគូ ដើម្បីផ្តល់សេវាដល់ជនរងគ្រោះដែលមានបញ្ហាពាក់ព័ន្ធ។

-សហការជាមួយនឹងអាជ្ញាធរក្រុង-ស្រុក អង្គភាពពាក់ព័ន្ធ និងអង្គការ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលរកឃើញ។

-ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រឆ្នាំ២០១៤-២០១៨ ស្តីពីផែនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

-បន្តជំរុញការក្តាប់ទិន្នន័យចំណាកស្រុក និងបង្ក្រាបជនដែលលួចចេញ-ចូលទៅប្រទេសថៃ តាមច្រករបៀងគ្មានច្បាប់អនុញ្ញាត។

-បន្តសហការជាមួយអង្គការដៃគូនានា ដើម្បីផ្តល់សេវាដល់ជនរងគ្រោះដែលមានបញ្ហា ឲ្យបានទាន់ពេលវេលា និង-ត្រូវបន្តចុះអធិការកិច្ចការងារតាមសហគ្រាសគ្រឹះស្ថានឯកជន និងសេវាកម្សាន្តនានា ។

## ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០១៩

## កម្ពុជា-សហភាពអឺរ៉ុប ប្តេជ្ញារួមគ្នាប្រយុទ្ធប្រឆាំងលើ បញ្ហាជួញដូរមនុស្ស និងបញ្ហាជនទេសន្តរប្រវេសន៍

https://www.information.gov.kh/ ធ្នូ 20, 2019 ចែម ហួត

វិទ្យុជាតិកម្ពុជា៖ MC៖ កម្ពុជា-សហភាពអឺរ៉ុប ប្តេជ្ញារួមប្រយុទ្ធប្រឆាំងលើ បញ្ហាការជួញដូរមនុស្ស និងបញ្ហាជនទេសន្តប្រវេសន៍ ដើម្បីបង្កាការពារ និងលើកកម្ពស់សុខមាលភាពរបស់កម្មករចំណាកស្រុក ខណៈដែលកម្មករចំណាកស្រុក ជាផ្នែកមួយដែលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។

ថ្លែងប្រាប់ក្រុមអ្នកសារព័ត៌មាន ក្រោយជំនួបសម្តែងការគួរសម និងពិភាក្សាការងារ រវាងសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាមួយលោកជំទាវ Carmen Moreno ឯកអគ្គរដ្ឋទូតថ្មីនៃសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកឧត្តម ផាត សុផានិត អ្នកនាំពាក្យរងក្រសួងមហាផ្ទៃ បានឲ្យដឹងថា លោកជំទាវឯកអគ្គរដ្ឋទូតថ្មី លើកឡើងថា កន្លងមកក្រសួងមហាផ្ទៃបានផ្តល់នូវកិច្ចសហការដ៏ល្អ ជាពិសេសសម្តេចក្រឡាហោមផ្ទាល់ ជាមួយនឹងសហភាពអឺរ៉ុប ។ លោកជំទាវ សង្ឃឹមថា វត្តមានរបស់លោកជំទាវនៅកម្ពុជានាពេលនេះ នឹងបន្តនូវអ្វីដែលជាទំនាក់ទំនងកិច្ចសហប្រតិបត្តិការដ៏ល្អ ដែលមានកន្លងមកនេះរវាងភាគីទាំងពីរ។ លោកជំទាវ បន្ថែមថា កន្លងមកប្រជាជនកម្ពុជា ធ្វើចំណាកស្រុកច្រើន ទៅកាន់ប្រទេសថៃ ជាពិសេស លើវិស័យនេសាទ ហើយពួកគាត់មួយចំនួនក៏ប្រឈមទៅនឹងការជួញដូរមនុស្ស ប្រសិនបើគាត់ពុំមានឯកសារគ្រប់គ្រាន់ឬក៏មិនមានការជួយជ្រោមជ្រែងសមស្របណាមួយ។ លោក

ជំទាវ បញ្ជាក់ថា នេះជាផ្នែកមួយដែលសហភាពអឺរ៉ុប កំពុងយកចិត្តទុកដាក់ លើការងារលើកកម្ពស់សុខមាលភាពរបស់កម្មករចំណាកស្រុក។

ជាកិច្ចឆ្លើយតប សម្តេចក្រឡាហោម ស ខេង បានថ្លែងអំណរគុណចំពោះសហភាពអឺរ៉ុប ដែលតែងតែខិតខំប្រឹងប្រែង ក្នុងការបន្តលើកកម្ពស់ទំនាក់ទំនងរវាងភាគីទាំងពី។ សម្តេច សង្ឃឹមថា វត្តមានរបស់លោកជំទាវក្នុងអណត្តិថ្មីនេះនឹងបន្តលើកកម្ពស់ទំនាក់ទំនងរវាងភាគីទាំងពីរឲ្យកាន់តែប្រសើរឡើងថែមទៀត។ ចំពោះបញ្ហាទេសន្តប្រវេសន៍ និងការជួញដូរមនុស្សនេះដែរ សម្តេចក្រឡាហោម បានឲ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជា ពិតជាយកចិត្តទុកដាក់ខ្ពស់ណាស់ចំពោះបញ្ហានេះ ហើយកន្លងមក កម្ពុជាបានបង្កើតជាយន្តការអន្តរក្រសួង ក្នុងការចុះទៅស្រង់នូវស្ថិតិដូចជា ធ្វើប័ណ្ណឯកសារផ្លូវការជូនទៅពលករ ឬក៏ប្រជាពលរដ្ឋចំណាកស្រុក ជាពិសេសអ្នកដែលទៅធ្វើការជាអ្នកនេសាទនៅប្រទេសថៃ។ មួយវិញទៀត រាជរដ្ឋាភិបាលកម្ពុជា ក៏បានយកចិត្តទុកដាក់លើការងារពាក់ព័ន្ធទៅនឹងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនេះ ដោយបង្កើតគណៈកម្មការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដែលសម្តេចផ្ទាល់គឺជាប្រធាននៃគណៈកម្មការនេះ។

សម្តេចបានបន្តថា កន្លងមកគឺបានធ្វើការងារច្រើនជាមួយនឹងបណ្តាប្រទេសជិតខាង ដូចជាការងារផ្សព្វផ្សាយអប់រំ ដើម្បីធ្វើយ៉ាងណាទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការងារជួញដូរមនុស្សនេះ។ ហើយសម្តេចពិតជារីករាយនិងទទួលបានការជួយគាំទ្រទៅលើផ្នែកពាក់ព័ន្ធលើកិច្ចការងារគាំទ្រដល់ជនចំណាកស្រុក ហើយនឹងការងារប្រឆាំងការជួញដូរមនុស្សនេះ។

លោកជំទាវ Carmen Moreno ឯកអគ្គរដ្ឋទូតថ្មី នៃសហភាពអ៊ឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា ក៏បានថ្លែងអំណរគុណ និងកោតសរសើរចំពោះវឌ្ឍនភាពនៃការរីកចម្រើនរបស់កម្ពុជា ទាំងលើវិស័យសេដ្ឋកិច្ច និងសង្គម ។លោកជំទាវ ក៏សង្ឃឹមជឿជាក់ថា លោកជំទាវនឹងអាចចូលរួមចំណែកក្នុងការធ្វើយ៉ាងណាជួយបន្តនូវអ្វីដែលជាវឌ្ឍនភាពរបស់កម្ពុជានេះឲ្យបានកាន់តែរីកចម្រើនលូតលាស់ទៅមុខទៀត៕

## សម្តេចក្រឡាហោម ស ខេង ទទួលជួបពិភាក្សាការងារជាមួយ ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា

http://cambodiapolice.com/policekh/ 6:46 pm 19 ធ្នូ 2019 101

**ភ្នំពេញ៖** នៅរសៀលថ្ងៃព្រហស្បតិ៍ ៨រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានទទួលជួបពិភាក្សាការងារជាមួយលោកជំទាវ ខាម៉ិន ម៉ូរ៉េណូ ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ។

ជាកិច្ចចាប់ផ្តើម សម្តេចក្រឡាហោម ស ខេង បានសម្តែងការស្វាគមន៍ និងថ្លែងអំណរគុណចំពោះលោកជំទាវឯកអគ្គរដ្ឋទូត និងសហភាពអឺរ៉ុប ដែលកន្លងមក តែងតែខិតខំប្រឹងប្រែងក្នុងការបន្តលើកកម្ពស់ទំនាក់ទំនងរវាងកម្ពុជា និងសហភាពអឺរ៉ុប និងបានសម្តែងក្តីសង្ឃឹមថាវត្តមានលោកជំទាវក្នុងអាណត្តិការងារនេះ នឹងបន្តលើកកម្ពស់ទំនាក់ទំនងនេះឲ្យកាន់តែប្រសើរឡើងថែមទៀត។

ជាការឆ្លើយតបលោកជំទាវ ខាម៉ិន ម៉ូរ៉េណូ ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប បានជំរាបជូនសម្តេចក្រឡាហោម ថាតាមរយៈឯកឧត្តមឯកអគ្គរដ្ឋទូតចាស់ លោកជំទាវបានដឹងថាកន្លងមកក្រសួងមហាផ្ទៃបានផ្តល់នូវកិច្ចសហការដ៏ល្អជាមួយសហភាពអឺរ៉ុប ពិសេសសម្តេចក្រឡាហោមផ្ទាល់ និងបានសម្តែងសង្ឃឹមដែរថាតាមរយៈអាណត្តិការងារនេះ លោកជំទាវនឹងបានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អជានេះទៀត។ លោកជំទាវឯកអគ្គរដ្ឋទូត ក៏បានជំរាបជូសម្តេចដែរថាសហភាពអឺរ៉ុប មានកម្មវិធីអភិវឌ្ឍន៍មួយចំនួនដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ

កម្ពុជា ក្នុងនោះក៏មានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ហើយថាលោកជំទាវពិតរីករាយចំពោះការមើលឃើញកិច្ចខិតខំប្រឹងប្រែងរបស់សម្តេចក្រឡាហោម និងសូមអរបអរសាទរចំពោះការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការឈានឆ្ពោះទៅមុខក្នុងការសម្រេចបានជោគជ័យលើការងារកំណែទម្រង់នេះ។ លោកជំទាវក៏បានបន្តមានប្រសាសន៍ដែរថា កាលពីប៉ុន្មានខែមុននេះ សម្តេចបានដឹកនាំគណៈប្រតិភូអន្តរក្រសួងទៅកាន់ប្រទេសអាល្លឺម៉ង់ដើម្បីស្វែងយល់បន្ថែមអំពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនេះ ហើយលោកជំទាវយល់ឃើញថាកំណែទម្រង់នេះ ពិតជាមានសារៈសំខាន់ណាស់ក្នុងការធ្វើឲ្យសង្គមមានគណនេយ្យភាព ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការចូលរួមរបស់ពលរដ្ឋក្នុងការសម្រេចចិត្តផ្សេងនៅមូលដ្ឋានរបស់ខ្លួន។

សម្តេចក្រឡាហោម ស ខេង ក៏បានមានប្រសាសន៍បញ្ជាក់ជូនអំពីសវតាខ្លះៗនៃដំណើរការកំណែទម្រង់រដ្ឋបាលរបស់ប្រទេសកម្ពុជា ដែលកន្លងមកកម្ពុជាបានដឹកនាំប្រទេសតាមបែបថ្នាក់កណ្តាល គឺអំណាចនៅថ្នាក់ជាតិ ប៉ុន្តែតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កម្ពុជាបានផ្ទេរអំណាចទៅថ្នាក់ក្រោមដើម្បីសម្រេចចិត្តលើវិស័យមួយចំនួនដែលបំរើសេចក្តីត្រូវការជាក់ស្តែងក្នុងមូលដ្ឋាន។ សម្តេចបានបន្តមានប្រសាស៍ថាការចាប់ផ្តើមកំណែទម្រង់នេះមិនមែនជាការងាយស្រួលនោះទេ គឺបានជួបការលំបាកជាច្រើនដែរ ប៉ុន្តែយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តក្នុងការបន្តឲ្យមានវឌ្ឍនភាពទៅមុខជាលំដាប់។ សម្តេចបានគូសបញ្ជាក់ថានៅឆ្នាំ ២០២០ខាងមុខនេះ កម្ពុជានឹងបញ្ចប់ផែនការជាតិ១០ឆ្នាំក្នុងការងារកំណែទម្រង់នេះជំហ៊ានទី១ និងបានបង្ហាញភាពរីករាយប្រសិនបើសហភាពអឺរ៉ុបចូលរួមចំណែកក្នុងការងាររៀបចំផែនការសម្រាប់អនុវត្តជំហ៊ានទី២បន្តទៀត។

ឆ្លើយតបជូនសម្តេច លោកជំទាវឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបបានមានប្រសាសន៍ថា សហភាពអឺរ៉ុបពិតជាយល់ឃើញចំពោះសារៈសំខាន់នៃការងារកំណែទម្រង់នេះ និងបានសន្យាខិតខំរិះរកមធ្យោបាយបន្តជួយគាំទ្រដល់ការងារនេះ មុននឹងបន្តជំរាបជូនសម្តេចអំពីកិច្ចសហប្រតិបត្តិការក្នុងការងារជនទេសន្តប្រវេសន៍។ លោកជំទាវបានលើកឡើងថា កម្ពុជាក៏មានអ្នកធ្វើចំណាកស្រុកច្រើនទៅកាន់ប្រទេសថៃ ពិសេសក្នុងវិស័យនេសាទ ដែលមួយចំនួនប្រឈមការជួញដូរមនុស្ស ប្រសិនបើគ្មានឯកសារគ្រប់គ្រាន់ និងការជួយជ្រោមជ្រែងសមស្របណាមួយ ដោយបានបន្តថាសហភាពអឺរ៉ុប ក៏យកចិត្តទុកដាក់ក្នុងការងារលើកកម្ពស់សុខមាលភពរបស់កម្មករចំណាកស្រុកនេះ ដោយសារកម្មករនេះក៏ជាផ្នែកមួយនៃការជួយអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។ លោកជំទាវបានបន្តថា នៅសហភាពអឺរ៉ុបមានគោលនយោបាយអនុញ្ញាតឲ្យប្រជាពលរដ្ឋអាចផ្លាស់ទីទៅធ្វើការដោយសេរីនៅក្នុងសហគមអឺរ៉ុប ប៉ុន្តែថា នៅក្នុងតំបន់អាស៊ាន មិនទាន់មានយន្តការនេះទេ ដូច្នេះនឹងអាចធ្វើឲ្យប្រជាពលរដ្ឋមួយចំនួនក្លាយជាអ្នកចំណាកស្រុកខុសច្បាប់ និងក្លាយជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស។

ជុំវិញប្រធានបទនេះ សម្តេចក្រឡាហោម ស ខេង បានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជា ពិតជាយកចិត្តទុកដាក់ខ្ពស់ណាស់ចំពោះបញ្ហានេះ ដោយបានបង្កើតឲ្យមានជាយន្តការអន្តរក្រសួងក្នុងការចុះទៅស្រង់ស្ថិតិ និងធ្វើបណ្ណឯកសារស្របច្បាប់ជូនពលករ ឬជនចំណាកស្រុកនៅប្រទេសថៃ និងបានយកចិត្តទុកដាក់ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ដោយកិច្ចនេះក៏មានយន្តការគណៈកម្មាធិការជាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលសម្តេចផ្ទាល់គឺជាប្រធាន និងបានធ្វើការងារយ៉ាងច្រើនជាមួយប្រទេសជិតខាង និងការងារផ្សព្វផ្សាយអប់រំ។

លោកជំទាវ ខាម៉ិន ម៉ូរ៉េណូ ក៏បានបន្តមានប្រសាសន៍អំពីការងារសង្គមស៊ីវិលនៅកម្ពុជា ដោយបានជំរាបសម្តេចក្រឡាហោមថាលោកជំទាវបានតាមដានការជួបជជែកគ្នារវាងក្រសួងមហាផ្ទៃ និងតំណាងអង្គការសង្គមស៊ីវិល ដើម្បីបង្កើនភាពជាដៃគូរវាងភាគីទាំងពីរ។ លោកជំទាវបានសម្តែងការអបអរសាទរចំពោះការជួបពិភាក្សាគ្នានេះ នឹងបង្ហាញភាពរីករាយថាប្រសិនបើមានអ្វីដែលសហភាពអឺរ៉ុបចូលរួមចំណែកបានក្នុងការធ្វើឲ្យមានភាពជាដៃគូល្អរវាងសង្គមស៊ីវិល និងរាជរដ្ឋាភិបាលនោះ គឺលោកជំទាវត្រៀមខ្លួនជានិច្ច។

ជាការឆ្លើយតប សម្ដេចក្រឡាហោម ស ខេង បានមានប្រសាសន៍ថាសម្ដេចនៅតែបន្តមានការលើកទឹកចិត្តឲ្យមានការប្រស្រ័យទាក់ទងគ្នាល្អរវាងភាគីសង្គមស៊ីវិល និងក្រសួងមហាផ្ទៃ ព្រមទាំងរាជរដ្ឋាភិបាល និងបានគូសបញ្ជាក់ថារាជរដ្ឋាភិបាល មានការយល់ឃើញដូចគ្នាដែរថាសង្គមស៊ីវិល គឺជាដៃគូមួយដ៏សំខាន់ ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សង្គមជាតិ។

មុននឹងបញ្ចប់លោកជំទាវ ខាម៉ិន ម៉ូរ៉េណូ ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប បានសម្ដែងការអបអរសាទរចំពោះវឌ្ឍន៍ភាពទាំងវិស័យសង្គម សេដ្ឋកិច្ច របស់កម្ពុជា និងបានបង្ហាញក្ដីសង្ឃឹមជឿជាក់ថា លោកជំទាវនឹងអាចរួមចំណែកធ្វើយ៉ាងណាជួយបន្តនូវអ្វីដែលជាវឌ្ឍនភាពរបស់កម្ពុជាឲ្យបានកាន់តែរកចំរើនតទៅមុខទៀត។

ហើយសម្ដេចក្រឡាហោម ស ខេង ក៏បានបង្ហាញក្ដីសង្ឃឹមជឿជាក់ដែរថាសហភាពអឺរ៉ុប នឹងបន្តជួយកម្ពុជាក្នុងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ៕

## EU៖ ពលរដ្ឋខ្មែរ ចំណាកស្រុកទៅថៃ ប្រឈមការជួញ ដូរមនុស្សបើគ្មាន ឯកសារគ្រប់គ្រាន់

https://www.dap-news.com/national/ ByPH104 Posted on December 20, 2019

ភ្នំពេញ ៖ លោកស្រី ខាម៉ិន ម៉ូរ៉េណូ ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប (EU) ប្រចាំកម្ពុជា បានថ្លែងថា ពលរដ្ឋខ្មែរធ្វើចំណាកស្រុក ទៅកាន់ប្រទេសថៃ ក្នុងវិស័យនេសាទ មួយចំនួនប្រឈមការជួញដូរមនុស្ស ប្រសិនបើពួកគេ គ្មានឯកសារគ្រប់គ្រាន់ ។

ក្នុងជំនួបពិភាក្សាការងារ ជាមួយសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ លោកស្រី ខាម៉ិន ម៉ូរ៉េណូ បានឲ្យដឹងថា EU យកចិត្តទុកដាក់ក្នុងការលើកកម្ពស់សុខមាលភាព របស់កម្មករចំណាកស្រុកដោយសារកម្មករនេះក៏ជាផ្នែកមួយក្នុងការជួយអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម។

លោកស្រីមានប្រសាសន៍ថា "កម្ពុជាក៏មានអ្នកធ្វើចំណាកស្រុកច្រើន ទៅកាន់ប្រទេសថៃ ពិសេសក្នុងវិស័យនេសាទ ដែលមួយចំនួនប្រឈម ការជួញដូរមនុស្ស ប្រសិនបើគ្មានឯកសារគ្រប់គ្រាន់ និងការជួយជ្រោមជ្រែង សមស្របណាមួយ" ។ លោកស្រីបន្តថា EU មានគោលនយោបាយអនុញ្ញាត ឲ្យប្រជាពលរដ្ឋអាចផ្លាស់ទីតាំងទៅធ្វើការដោយសេរីនៅ EU ។ លោកស្រីថា ប៉ុន្តែក្នុងតំបន់អាស៊ានមិនទាន់មានយន្តការនេះទេ ដូច្នេះនឹងអាចធ្វើឲ្យប្រជាពលរដ្ឋមួយចំនួនក្លាយ ជាអ្នកចំណាកស្រុកខុសច្បាប់ និងក្លាយជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស ។

ជាការឆ្លើយតប សម្ដេចក្រឡាហោម ស ខេង លើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា ពិតជាយកចិត្តទុកដាក់ខ្ពស់ចំពោះបញ្ហានេះ ដោយបានបង្កើត ឲ្យមានជាយន្តការអន្តរ ក្រសួងចុះទៅស្រង់ស្ថិតិ និងធ្វើប័ណ្ណឯកសារស្របច្បាប់ជូនពលករ ឬជនចំណាកស្រុកនៅថៃ និងបានយកចិត្តទុកដាក់ប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ដោយកិច្ចនេះ ក៏មានយន្តការគណៈកម្មាធិការជាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលសម្ដេចផ្ទាល់គឺ ជាប្រធានដោយបានធ្វើការងារយ៉ាងច្រើន ជាមួយប្រទេសជិតខាង និងការងារផ្សព្វផ្សាយអប់រំជាដើម ៕ ដោយ ៖ អេង ប៊ូឆេង

## ក្រុមប្រឹក្សាជាតិដើម្បីកុមារ បើកវគ្គបណ្ដុះបណ្ដាលស្ដីពី កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ

http://www.freshnewsasia.com/ 2019-12-19

**(កែប)៖** អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិដើម្បីកុមារ (ក.ជ.ក) បានរៀបចំវគ្គបណ្ដុះបណ្ដាល ស្ដីពីកិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ នៅសណ្ឋាគាររ៉ុករ៉ូយ៉ាល់ ខេត្តកែប ចាប់ពីថ្ងៃទី១៨ ដល់

ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ក្រោមអធិបតីភាព លោកស្រី ខៀវ បូរី រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

វគ្គបណ្តុះបណ្តាលនេះធ្វើឡើងក្នុងគោលបំណង ទី១៖ ដើម្បីលើកកម្ពស់ការយល់ដឹងដល់មន្ត្រី នៃអគ្គលេខាធិការដ្ឋាន ក.ជ.ក អំពីការទប់ស្កាត់ និងការពារកុមារពីការ កេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ, ទី២៖ ដើម្បីបង្កើនកិច្ចសហការ ជាមួយមន្ត្រីអ្នកអនុវត្តច្បាប់ និងគោលនយោបាយសំខាន់ៗ ពាក់ព័ន្ធកិច្ចការពារកុមារ។ វគ្គបណ្តុះបណ្តាលនេះ ក៏មានការចូលរួមពី លោក លោកស្រី ដែលអញ្ជើញមកក្រសួងមហាផ្ទៃ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងអង្គការដៃគូពាក់ព័ន្ធ ដែលឧបត្ថម្ភគាំទ្រពីអង្គការ Terre des hommes ( TDH )៕

## ប្រធានបេសសកម្ម IOM សន្យាបន្តកិច្ចសហការពេញទំហឹង លើការងារជួយជនចំណាកស្រុក ដោយប្រថុយប្រថាន និង ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នៅកម្ពុជា

http://freshnewsasia.com/ 2019-12-19

**(ភ្នំពេញ)៖** លោកស្រី គ្រីស្ទីន ប៉ាកូ ប្រធានបេសកកម្មអង្គការ ប្រធានបេសសកម្ម IOM សន្យាបន្តកិច្ចសហការពេញទំហឹង លើការងារជួយជនចំណាកស្រុកដោយប្រថុយប្រថាន និង ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នៅកម្ពុជា ទាំងផ្នែកស្មារតី, បច្ចេកទេស និងហរិញ្ញវត្ថុ និងធនធានមនុស្ស ដើម្បីពង្រឹងការងារជួយទៅដល់ជនចំណាកស្រុក និងការជួញដូរមនុស្សនៅកម្ពុជា។ ការប្រកាសជួយពីអង្គការ IOM បានធ្វើឡើងខណៈកម្ពុជា កំពុងតែសាងសង់មជ្ឈមណ្ឌលសំចត សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត ក្រោមការឧបត្ថម្ភពីប្រទេសថៃ។

ការលើកឡើងរបស់ថ្នាក់ដឹកនាំអង្គការ IOM នាពេលនេះ បានធ្វើឡើងនៅក្នុងជំនួបរវាង លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និងជាតំណាងលោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយលោកស្រី គ្រីស្ទីន ប៉ាកូ ប្រធានបេសកកម្ម អង្គការ IOM នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩នេះ នាទីស្តីការក្រសួងសង្គមកិច្ច។

**បន្ថែមពីលើនេះ ភាគីទាំងពីរ ក៏បានពិភាក្សាគ្នាទៅលើបញ្ហាមួយចំនួនទៀតរួមមាន៖**

*១៖ អង្គការ IOM មានគំរោងបណ្តុះបណ្តាលផ្នែកសង្គ្រោះបឋមតាមប្រព័ន្ធអនឡាញ ទៅដល់មន្ត្រីនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

*២៖ អង្គការ IOM នឹងផ្តល់កិច្ចគាំទ្រគំរោងសិក្ខាសាលាដល់មន្ត្រីថ្នាក់ ភូមិ ឃុំ អំពីការចំណាកស្រុកដោយភាពប្រថុយប្រថាន។

*៣៖ អង្គការ IOM នឹងផ្តល់កិច្ចគាំទ្រផ្នែកស្មារតី បច្ចេកទេស និង ហរិញ្ញវត្ថុ ទៅលើសិក្ខាសាលានៃការផ្សព្វផ្សាយ SOP រវាងប្រទេស កម្ពុជា-ថៃ អំពីការបញ្ជូននិងមាតុភូមិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលនឹងប្រព្រឹត្តទៅនាចុងខែមករា ឆ្នាំ២០២០ ខាងមុខនេះ។

*៤៖ អង្គការ IOM នឹងបន្តពង្រឹងកិច្ចសហប្រតិបត្តការ ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

គួរបញ្ជាក់ថា ប្រទេសថៃបានសម្រេចកសាងមជ្ឈមណ្ឌលសំចត សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត ជូនដល់ប្រទេសកម្ពុជាសម្រាប់ការប្រារព្ធពិធីគំរប់ខួប៧០ឆ្នាំ នៃសម្ព័ន្ធភាពថៃ-កម្ពុជា។ ការកសាងជូនប្រទេសកម្ពុជា នាពេលនេះ ក៏បង្ហាញពីចំណុចចាប់ផ្តើមជាវិជ្ជមានរបស់កម្ពុជា-ថៃ លើការពង្រឹង និង

គ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និង សមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស (SOP) នៅក្នុងប្រទេសថៃ ដែលកម្ពុជា និងថៃបានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩កន្លងមកផងដែរ។

កាលពីពេលថ្មីៗនេះ ភាគីកម្ពុជា និងភាគីថៃ បានចុះហត្ថលេខា (SOP) ដើម្បីបង្កើតគោលការណ៍ណែនាំរួមស្តីពី ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណងពង្រឹងបទដ្ឋានប្រតិបត្តិអនុលោម ទៅតាមការអនុវត្តជាលក្ខណៈអន្តរជាតិ, កំណត់តួនាទី និងការទទួលខុសត្រូវ នៃអាជ្ញាធរពាក់ព័ន្ធនៃរដ្ឋភាគីទាំង២ នៅក្នុងដំណើរការមាតុភូមិនិវត្តន៍ និងសមាហរណកម្ម, ប្រើប្រាស់ជាឯកសារយោងពាក់ព័ន្ធ និងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម និងជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស៕

## ពលរដ្ឋនាំគ្រួសារចេញទៅរកការងារក្នុងដីថៃ ខណៈធ្វើស្រែមិនសូវបានផល

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩ ម៉ោង ១៦:២៥ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ប្រជាពលរដ្ឋទាំងគ្រួសារបាននាំគ្នាចេញពីកម្ពុជាតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតទៅទឹកដីថៃដើម្បីរកការងារធ្វើរកប្រាក់ចំណូលបន្ថែម ខណៈឆ្នាំនេះទឹកតិចធ្វើស្រែមិនសូវបានផល ។ គេសង្កេតឃើញគ្រួសារខ្លះមានកូនតូច ខ្លះក៏មានកូនធំ ហើយសម្ភារៈនាំទៅជាមួយមានស្ទើរគ្រប់បែបយ៉ាងដូចជាកន្ទេល មុងភួយ ចានឆ្នាំង សម្លៀកបំពាក់ និងអង្ករ។ ពលករទាំងនេះអះអាងថា ពួកគាត់ទៅស៊ីឈ្នួលកាប់អំពៅ និងដកដំឡូងឲ្យថៃតាមខេត្តជាប់ៗព្រំដែនលុះជិតដល់ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិទើបត្រឡប់មកភូមិកំណើតវិញ ។ ពលករទាំងនេះមួយចំនួនមកពីខេត្តបន្ទាយមានជ័យ, ខេត្តកំពង់ធំ និងភាគច្រើនមកពីខេត្តសៀមរាប ហើយភាគច្រើនប្រើប្រាស់លិខិតឆ្លងដែនការងារ (Pass Port) និងមួយចំនួនតូចប្រើប្រាស់ប័ណ្ណឆ្លងព្រំដែន(Border Pass) ។ ពួកគាត់លើកឡើងខុសគ្នាៗខ្លះថា ដោយសារឆ្នាំនេះភ្លៀងធ្លាក់តិចធ្វើស្រែមិនសូវកើតខ្លះថានៅស្រុកគ្មានការងារធ្វើ ឯអ្នកមួយចំនួនទៀតថា រដូវនេះធ្លាប់ឆ្លងដែនទៅមកធ្វើការឲ្យជនជាតិថៃ។

ជុំវិញករណីនេះ លោកវរសេនីយ៍ត្រីសេម មករា ប្រធានសេនាធិការនគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតប្រាប់តាមទូរស័ព្ទថា ចំនួនពលករឆ្លងដែនទៅដីថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតដើម្បីរកការងារធ្វើតាមខេត្តជាប់ព្រំដែនឆ្នាំនេះមានចំនួនតិចជាងឆ្នាំមុនៗ ហើយលោកថាពលករទាំងនេះបច្ចុប្បន្នងាកទៅប្រើប្រាស់លិខិតឆ្លងដែនការងារជំនួសប័ណ្ណឆ្លងព្រំដែន (Border Pass) វិញ៕ (កែសម្រួលដោយ ៖ ធីតា)

## រដ្ឋបាលខេត្តព្រះសីហនុ ប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៩

https://www.information.gov.kh/ ធ្នូ 19, 2019 ស វិជ័យ

AKP ព្រះសីហនុ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩៖ នៅព្រឹកថ្ងៃព្រហស្បតិ៍ ៨រោច ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ រដ្ឋបាលខេត្តព្រះសីហនុ ប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ នៅសាលាខេត្តព្រះសីហនុ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម ជាម ហ៊ីម ប្រធាន ក្រុមប្រឹក្សាខេត្តព្រះសីហនុ លោកស្រី ហៀក ហ៊ីមុល្លី អភិបាលរងខេត្តព្រះសីហនុ និងមន្ត្រីមន្ទីរ អង្គភាព កងកម្លាំងប្រដាប់អាវុធជុំវិញខេត្ត។

ឯកឧត្តម ជាម ហ៊ីម ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុបានមានប្រសាសន៍ថា ទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ លើកទី១៣ ជាទិវាមួយក្នុងចំណោមអាទិភាពជា ច្រើនសម្រាប់ការលើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសង្គម ក៏ដូចជាការលើកកម្ពស់ការ គោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូរមនុស្ស ព្រោះថា អំពើជួញដូរមនុស្ស ជាបទឧក្រិដ្ឋដែលជន ល្មើសជួញដូរមនុស្ស បានប្រើប្រាស់គ្រប់កលល្បិច ដើម្បីកេងប្រវ័ញ្ចរំលោភបំពានលើមនុស្ស ដោយមិនខ្វាយខ្វល់ពីទុក្ខវេទនា និងអាយុជីវិតរបស់មនុស្សដែលចង់រស់រៀនជួបជុំគ្រួសារ និងសេចក្តីសុខ។ រដ្ឋបាលខេត្តនឹងបន្តការប្តេជ្ញាចិត្តខ្ពស់ រិះរកគ្រប់វិធានការ និងពង្រឹងការ អនុវត្តច្បាប់ពាក់ព័ន្ធនានា ដើម្បីការពារប្រជា

ពលរដ្ឋ ពីបទល្មើសដ៏ស្មុគស្មាញនេះ។ ជំរុញអនុវត្តន៍យុទ្ធសាស្ត្រទាំង៤ របស់ផែនការជាតិមានជាអាទិ៍ ការងារបង្ការទប់ស្កាត់, កិច្ចការពារជនរងគ្រោះ, ការពង្រឹងការអនុវត្តច្បាប់ និងការពង្រឹងកិច្ចសហការជាមួយ គ្រប់ភាគីពាក់ព័ន្ធឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ឯកឧត្តម ប្រធានក្រុមប្រឹក្សាខេត្តបន្តថា រដ្ឋបាលខេត្ត និងខិតខំប្រឹងប្រែងយក ចិត្តទុកដាក់ ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម និងលើកកម្ពស់កំណើនសេដ្ឋ កិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិឱ្យមានស្ថិរភាព ព្រមទាំងប្តេជ្ញាចិត្តរក្សាសន្តិសុខ សុវត្ថិភាព សម្រាប់ភ្ញៀវបរទេសទាំងឡាយ ដែលស្នាក់នៅក្នុងខេត្តព្រះសីហនុ ប្រកបដោយភាពកក់ក្តៅ ទន្ទឹមនេះរដ្ឋបាលខេត្តបង្កើតក្រុមការងារក្រុង ស្រុក លើកកម្ពស់កម្រិតជីវភាពរបស់ ប្រជាពលរដ្ឋលើគ្រប់វិស័យ តាមរយៈការលើកកម្ពស់វិស័យទេសចរណ៍ កសិកម្ម សំណង់ ហេដ្ឋារចនាសម្ព័ន្ធ ពាណិជ្ជកម្មជាដើម ដែលអាចបង្កើនការងារ និងមុខរបរជូនប្រជាពលរដ្ឋ ក្នុងខេត្តធ្វើឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញ ដូរមនុស្ស គឺជាយុទ្ធនាការ ដ៏ទូលំទូលាយសម្រាប់ការផ្សព្វ ផ្សាយការយល់ដឹង អំពើជួញដូរមនុស្ស ផលប៉ះពាល់ និងអំពីកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ប្រចាំឆ្នាំ ក៏ដូចជាវេទិកាអំពាវនាវដល់ជនរួមជាតិ និងសហគមន៍អន្តរជាតិចូលរួមសហការ ដើម្បីការពារសន្តិសុខ និងសុវត្ថិភាពមនុស្សជាតិពីអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពានគ្រប់រូបភាពទៅលើមនុស្ស។ ដូច្នេះថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ស្ថាប័ន អយ្យការតុលាការ កងកម្លាំងគ្រប់ប្រភេទ ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងវិស័យឯកជន តែងតែរួមគ្នាជម្នះដោះស្រាយបញ្ហាចំពោះមុខដោយមិនខ្លាចនឿយហត់ ពុះពារប្រឆាំងដាច់ខាតទៅនឹងសកម្មភាពរបស់ឧក្រិដ្ឋជនស្របតាមទិសដៅ នៃគោល នយោបាយជាតិ និងការបេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល។

ឯកឧត្តម ជាម ហ៊ីម បន្តថា ក្នុងនាមរដ្ឋបាលខេត្ត សូមអំពាវនាវ សូមប្រកាស ជាឱឡារិកក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ បន្តយុទ្ធនាការប្រឆាំង អំពើជួញដូរមនុស្ស ដើម្បីឱ្យប្រជាជនកម្ពុជា និងមនុស្សជាតិ ទទួលបានការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ ផលប្រយោជន៍ស្របច្បាប់ និងភាពសុខដុមរមនា ដោយរួមសហការជាមួយដៃគូ ពាក់ព័ន្ធនានា ដើម្បីរួមគ្នាបង្ក្រាបអំពើជួញដូរមនុស្សគ្រប់រូបភាព និងផ្តន្ទាទោសជនល្មើស ម៉ឺងម៉ាត់ ដើម្បីកាត់បន្ថយឈានទៅលុបបំបាត់បទល្មើសទាំងឡាយ នៅកម្ពុជាទទួលបាន ភាពសុខសាន្តគ្មានអំពើរំលោភបំពាន និងអំពើជួញដូរមនុស្ស៕ ដោយ ង៉ូ សុមុនី

## រដ្ឋាភិបាលជប៉ុន សម្រេចបង្កើតប្រព័ន្ធថ្មីទទួលពលករខ្មែរទៅធ្វើការងារនៅប្រទេសជប៉ុន

http://bayontv.com.kh/ 19/12/2019

ភ្នំពេញ៖ តំណាងរដ្ឋាភិបាលជប៉ុនប្រចាំនៅកម្ពុជា បានអោយដឹងថា នៅពេលនេះ រដ្ឋាភិបាលជប៉ុនបានសម្រេចបង្កើតប្រព័ន្ធថ្មីមួយ ពោល គឺប្រព័ន្ធជ្រើសរើសពលករមានជំនាញស្រាប់ទៅធ្វើការងារនៅប្រទេសជប៉ុន ខណៈប្រព័ន្ធជ្រើសរើសពលករបែបកម្មសិក្សាការនីកន្លងមក គឺមានពលករខ្មែរប្រមាណពី ៨០០០ ទៅ៩០០០នាក់ បាននឹងកំពុងធ្វើការងារនៅប្រទេសជប៉ុន។ នៅក្នុងពិធីប្រគល់លិខិតកោតសរសើរពីរដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន ជូនអតីតនិស្សិតកម្ពុជាមានស្នាដៃឆ្នើមចំនួន ២រូប នៅស្ថានទូតជប៉ុន ល្ងាចថ្ងៃទី១៨ ខែធ្នូនេះ ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា បានថ្លែងថា នៅក្នុងប្រព័ន្ធថ្មីនៃការជ្រើសរើសពលករជំនាញបរទេសទៅបំរើការងារនៅប្រទេសជប៉ុននេះ សម្រាប់ពលករពីប្រទេសកម្ពុជា អាចនឹងមិនមានការកើនឡើងនោះទេ ប៉ុន្តែទោះយ៉ាងណា ឯកឧត្តម នឹងខិតខំជួយសម្របសំរួលជួយបណ្តុះបណ្តាលជំនាញជូនប្រជាពលរដ្ឋកម្ពុជាអោយមានជំនាញ និងភាសាជប៉ុន ដើម្បីអោយគេទទួលបានឱកាសប្រលងជាប់ទៅធ្វើការងារនៅប្រទេសជប៉ុនផង និងរៀនសូត្រពីរបៀបធ្វើការងារនៅប្រទេសជប៉ុនបន្ថែមផងដែរ។

ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ បានថ្លែងថា សម្រាប់ប្រព័ន្ធការនៃជ្រើសរើសពលករបរទេសកន្លងមក គឺភាគី ជប៉ុនផ្តល់ឱកាសពលករទាំងនោះធ្វើការងារបណ្តើរ និងរៀនសូត្រជំនាញបណ្តើរ ហើយនៅពេលដល់បច្ចុប្បន្ននេះ ពលករខ្មែរដែលគេហៅថា ជាកម្មសិក្សាការនីផងដែរនោះ គឺបានក្លាយពលករមានជំនាញច្បាស់លាស់ មាន ប្រមាណពី៨០០០ទៅ៩០០០នាក់ ហើយអ្នកទាំងនោះ នឹងក្លាយជាអ្នកមានធនធានបន្តអាចធ្វើការងារនៅប្រទេស បន្តទៀតបានជាពិសេសបំរើការងារនៅក្នុងវិស័យកសិកម្ម។ ឯកឧត្តម អគ្គរាជទូតជប៉ុន ក៏បានបញ្ជាក់ថា នៅក្នុង ប្រព័ន្ធជ្រើសរើសពលករមានជំនាញស្រាប់នេះ បច្ចុប្បន្ន ជប៉ុនបាននិងកំពុងរៀបចំផ្ទះស្នាក់ល្អជាច្រើន ដើម្បីអោយ ពលករទាំងនោះទៅធ្វើការងា និងរស់នៅក្នុងប្រទេសជប៉ុនមានសុខដុមរមនា និងទទួលបាននូវការបណ្តុះបណ្តាល ជំនាញបន្ថែមទៀត ដើម្បីអោយពលករនៅពេលចប់អាណត្តិធ្វើការងាររបស់គេ ត្រលប់មកមាតុប្រទេសវិញ គឺគេ មានចំណេះមានជំនាញ អាចការបង្កើតមុខរបរ និងធ្វើការងារនានាដើម្បីអភិវឌ្ឍន៍ប្រទេសគេវិញ៕

## សារព័ត៌មានវៀតណាមថា កម្ពុជាគឺជាគោលដៅធំបំផុតសម្រាប់ស្ត្រីវៀតណាមមកពពោះជំនួស

https://khmernote.com/news/ December 20, 2019

យោងតាមរបាយការណ៍របស់រដ្ឋាភិបាលរបស់ប្រទេសទាំងពីរបានឱ្យដឹងថា ចាប់តាំងពីឆ្នាំ២០១៧ ស្ត្រីវៀត ណាមចំនួន ១,៦០០នាក់ ត្រូវបានគេជួញដូរមកកម្ពុជាដើម្បីពពោះជំនួស ឬពេស្យាចារ។ ក្នុងរបាយការណ៍ចេញ ផ្សាយនៅក្នុងសន្និសីទកាលពីថ្ងៃអង្គារ ក្រសួងសន្តិសុខសាធារណៈវៀតណាម និងក្រសួងកិច្ចការនារីកម្ពុជាបាន និយាយថា ចំពោះករណីដែលស្ត្រីវៀតណាមត្រូវបានគេជួញដូរមកធ្វើជាអ្នកពពោះជំនួស ពួកគេត្រូវបានជ្រើសរើស និងបញ្ជូនមកដោយពួកអ្នកលេង។ បន្ទាប់មកនៅពេលដែលពួកគេមានផ្ទៃពោះហើយនោះ ពួកគេនឹងត្រូវបញ្ជូនទៅ កាន់ប្រទេសវៀតណាមវិញ ឬទៅកាន់ប្រទេសចិនបន្តដើម្បីសម្រាល។ ចំណែកឯជនជាតិវៀតណាមមួយចំនួនក៏ត្រូវ បានគេជួញដូរធ្វើជាស្រីពេស្យាចារ។ ការរត់ពន្ធស្ត្រីមានច្រើនបំផុតគឺនៅច្រកព្រំដែនម៉ុកបៃ ខេត្តតាយនីញ ភាគខាង ត្បូងប្រទេសវៀតណាម។ ក្នុងនោះផងដែររដ្ឋាភិបាលទាំងពីរបានសន្យាថា នឹងប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅ តាមតំបន់ព្រំដែន។

ចំណែកក្រុមមន្ត្រីក៏បាននិយាយថា ពួកគេនឹងមានកិច្ចសហប្រតិបត្តិការត្រីភាគីជាមួយប្រទេសចិន ដើម្បី ពង្រឹងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនេះ។ ក្នុងចំណោមជនវៀតណាមដែលត្រូវបានគេជួញដូរចំនួន ៣,៤០០នាក់ ចាប់តាំងពីឆ្នាំ២០១៣ មានជាង ៩០% ជាស្ត្រី កុមារ ឬជនជាតិភាគតិច។ ជម្រាបដែរថា ការពពោះ ជំនួសនេះ គឺជារឿងខុសច្បាប់នៅក្នុងប្រទេសចិន ហើយប្រទេសវៀតណាមអនុញ្ញាតឱ្យធ្វើវាដោយឥតគិតថ្លៃ សម្រាប់តែគោលបំណងមនុស្សធម៌ និងរវាងសមាជិកគ្រួសារប៉ុណ្ណោះ។ ចំណែកកម្ពុជាយើងបានហាមឃាត់ការព ពោះជំនួសនៅឆ្នាំ២០១៦ និងបានកាត់ទោសការពពោះជំនួសរាប់សិបដង ហើយពួកគេទាំងនោះប្រឈមនឹងការ ជាប់ពន្ធនាគាររហូតដល់ ២០ឆ្នាំ៕

# ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០១៩

## សម្តេច ស ខេង អំពាវនាវឲ្យ ពលរដ្ឋ-សមត្ថកិច្ច ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈ ស្វែងរកការងារ នៅក្រៅប្រទេស

https://www.dap-news.com/ ByVNT108 Posted on December 21, 2019

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអំពាវនាវឲ្យ ប្រជា ពលរដ្ឋ សហការគ្នាជាមួយ សមត្ថកិច្ច ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអំពើជួញដូរមនុស្ស ដែលកើតឡើង តាមរយៈ ចេញទៅស្វែងរកការងារ ដោយខុសច្បាប់នៅក្រៅប្រទេស។ ក្នុងពិធីសម្ពោធឆ្លងសមិទ្ធផលនានា នៅវត្ត ពោធិសត្ថារាម ហៅវត្តអណ្តូងសាលា ស្រុកកញ្ជ្រៀច នាថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១៩ សម្តេច ស ខេង បានថ្លែងថា

ពលរដ្ឋកម្ពុជាសម័យបច្ចុប្បន្ន មានមធ្យោបាយជាច្រើន ក្នុងការតស៊ូមតិ ដើម្បីស្វែងរកដំណោះស្រាយ បញ្ហាប្រឈមក្នុងជីវភាពប្រចាំថ្ងៃរួមមាន ៖ ការផ្តល់ព័ត៌មានជូនអាជ្ញាធរ និងមន្ត្រីពាក់ព័ន្ធ ជូនប្រព័ន្ធផ្សព្វផ្សាយ តាមរយៈការបង្ហោះលើបណ្តាញសង្គម និងទំនាក់ទំនងជាមួយ អង្គការក្រៅរដ្ឋបាលជាដើម។ សម្តេចមានប្រសាសន៍ថា "អំពាវនាវប្រជាពលរដ្ឋ រួមសហការគ្នា ជាមួយអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ច នៅក្នុងការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀនខុសច្បាប់ អំពើជួញដូរមនុស្សដែលកើតឡើង តាមរយៈការចេញ ទៅស្វែងរកការងារ ដោយខុសច្បាប់នៅក្រៅប្រទេស "។

ជាងនេះទៅទៀត សម្តេច ស ខេង បានពន្យល់ថា នៅតាមភូមិ-ឃុំ របស់ពលរដ្ឋ មានក្រុមប្រឹក្សាឃុំ មន្ត្រីនគរបាល មេភូមិ គ្រូបង្រៀន និងគ្រូពេទ្យជាដើម ជាអ្នកបំពេញតួនាទី ផ្តល់សេវាសេវាដោយផ្ទាល់ ជូនពលរដ្ឋ។ សម្តេច ឧទាហរណ៍ ថា ការផ្តល់សេវាឯកសាររដ្ឋបាលនានា ការផ្តល់សេវាសន្តិសុខសង្គម ដូចជាទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា នៅក្នុងមូលដ្ឋាន។ ឆ្លៀតឱកាសនោះដែរ សម្តេច ក្រឡា ហោម ស ខេង បាន រំលឹកថា កម្ពុជាដើរផុតពីដំណាក់កាល ស្តារប្រទេសឡើងវិញហើយ គឺកំពុងស្ថិតក្នុងដំណាក់កាល ឈរជាប្រទេសកំពុងអភិវឌ្ឍន៍ និងក៏ដើម្បីឈានទៅប្រទេស មានការអភិវឌ្ឍ ដូចបណ្តាប្រទេសជឿនលឿនផ្សេងទៀត។ សម្តេចក៏បានបញ្ជាក់ដែរថា ពេលនេះកម្ពុជា ត្រូវបន្តថែរក្សាសុខសន្តិភាព និងស្ថេរភាពជាតិ ដើម្បីផ្តល់ឱកាស ដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ធ្វើឲ្យជីវភាពរស់នៅ របស់ពលរដ្ឋកាន់តែប្រសើរ៕ ដោយ៖ អេង ប៊ូធេង

## លោក ស ខេង ប្រាប់ពលរដ្ឋកុំឲ្យចាញ់បោកមេខ្យល់អូសទាញទៅធ្វើការក្រៅប្រទេស

https://vayofm.com/ 21-12-2019

លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអំពាវនាវដល់ប្រជាពលរដ្ឋឈប់ចាញ់បោកមេខ្យល់ ដែលអូសទាញទៅក្រៅប្រទេសដោយមិនស្របច្បាប់តាមបណ្តាញផ្សេងៗ។ លោកបានបញ្ជាក់ថា ប្រសិនបើមានអ្នកណាម្នាក់ដើរឃោសនាអូសទាញបងប្អូនចំណាកស្រុក ទៅធ្វើការនៅក្រៅប្រទេស សូមរាយការណ៍ទៅសមត្ថកិច្ចបន្ទាន់ ឬសួរនាំឲ្យបានច្បាស់ថា តើមេខ្យល់មកពីប្រភពណា? ឈ្មោះអ្វី? មានឯកសារស្របច្បាប់ឬមិនមាន ក្នុងន័យដើម្បីកុំឲ្យប្រជាពលរដ្ឋចាញ់បោកមេខ្យល់ ចាញ់បោកការអូសទាញពីជនខិលខូចទាំងនោះ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃរូបនេះបានអះអាងថា នាពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបានបើឱកាសគ្រប់បែបយ៉ាង មិនថាបងប្អូនចង់ធ្វើការក្នុងស្រុក ឬទៅក្រៅប្រទេសនោះទេ គឺមានសិទ្ធសេរីភាពគ្រប់គ្រាន់ក្នុងការចេញទៅ ប៉ុន្តែត្រូវស្របច្បាប់របស់ប្រទេស ដែលអាចការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋបាន ហើយទទួលបានឱកាស និងប្រាក់ខែត្រឹមត្រូវតាមបទដ្ឋានការងាររបស់ប្រទេសនីមួយៗ។

សូមបញ្ជាក់ថា ការអំពាវនាវខាងលើនេះធ្វើឡើងនៅក្នុងឱកាសដែលលោក ស ខេង បានអញ្ជើញចូលរួមក្នុងពិធីបុណ្យសម្ពោធឆ្លងសមិទ្ធិផលនានា នៅវត្តពោធិសត្តារាម ហៅវត្តអណ្តូងសាលា ស្ថិតក្នុងភូមិអណ្តូងសាលា ឃុំព្រាល ស្រុកកញ្ជៀច ខេត្តព្រៃវែង នៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៩។

យ៉ាងណាក៏ដោយការលើកឡើងរបស់លោក ស ខេង នេះដែរស្របពេលដែលឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជាក្នុងជំនួបជាមួយលោកកាលពីថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០១៩ បានលើកឡើងថា កម្ពុជាមានអ្នកធ្វើចំណាកស្រុកច្រើនទៅកាន់ប្រទេសថៃ ពិសេសក្នុងវិស័យនេសាទ ដែលមួយចំនួនប្រឈមការជួញដូរមនុស្ស ប្រសិនបើគ្មានឯកសារគ្រប់គ្រាន់ និងការជួយជ្រោមជ្រែងសមស្របណាមួយនោះ។

## ដំណឹងល្អ! ខេត្តឧត្តរមានជ័យ ពង្រីកទីតាំងធ្វើប័ណ្ណព្រំដែនកម្ពុជា-ថៃ មួយកន្លែងទៀត ដើម្បីបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋ

http://kampucheathmey.com/ 23/12/2019 8:32 Am

ខេត្តឧត្តរមានជ័យ៖ រដ្ឋបាលខេត្តឧត្តរមានជ័យ នឹងពង្រីកទីតាំងស្នើសុំប័ណ្ណព្រំដែន កម្ពុជា-ថៃ មួយទីតាំងបន្ថែមទៀត នៅស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិអូរស្មាច់ ស្ថិតក្នុងសង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ នេះបើតាមសេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្តឧត្តរមានជ័យ ដែលបានឲ្យកម្ពុជាថ្មីដឹងនៅរសៀលថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩។ រដ្ឋបាលខេត្តឧត្តរមានជ័យ បានឲ្យដឹងថា ប្រជាពលរដ្ឋទាំង២ភេទ ដែលមានទីលំនៅអចិន្ត្រៃយ៍ នៅក្នុងខេត្តឧត្តរមានជ័យអាចដាក់ពាក្យស្នើសុំធ្វើបណ្ណ័ព្រំដែន កម្ពុជា-ថៃ នៅអង្គភាពច្រកចេញចូលតែមួយ សាលាខេត្តឧត្តរមានជ័យដដែល ឬនៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ដោយភ្ជាប់មកជាមួយ៖

ទី១ ៖ ពាក្យស្នើសុំធ្វើប័ណ្ណព្រំដែន ចំនួន១ច្បាប់ ដោយមានបិទរូបថត ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃស្តាំរបស់សាមីខ្លួន នៅលើពាក្យស្នើសុំ (ពាក្យស្នើសុំមានផ្តល់ជូននៅទីតាំងស្នើសុំផ្ទាល់)។

ទី២ ៖ រូបថតសាមីខ្លួន បច្ចុប្បន្នទំហំ៤ គុណ៦ ថតចំពីមុខគ្មានពាក់មួក និងពាក់វ៉ែនតា ចំនួន២សន្លឹក។

ទី៣ ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើត ដែលជាច្បាប់ដើម ឬច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ទី៤ ៖ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ។

រដ្ឋបាលខេត្តឧត្តរមានជ័យ បានបញ្ជាក់ថា ចំពោះកុមារដែលមានអាយុក្រោម១៥ឆ្នាំ ត្រូវមានសំណើសុំ ឬការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ពីឪពុកម្តាយឬអាណាព្យាបាល។ ដោយឡែកចំពោះកុមារ ក្រោមអាយុ១២ឆ្នាំ អាចដាក់បញ្ចូលជាមួយប័ណ្ណព្រំដែនឪពុកម្តាយ ឬអាណាព្យាបាល ដោយភ្ជាប់មកជាមួយ នូវឯកសារពាក់ព័ន្ធផ្សេងៗផងដែរ៕

## អភិបាលខេត្តកំពង់ចាម អំពាវនាវដល់គ្រប់ស្ថាប័ន និងវិស័យឯកជន សហការគ្នាការពារ ដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស

http://www.freshnewsasia.com/ 2019-12-23

**(កំពង់ចាម)៖** អភិបាលខេត្តកំពង់ចាម លោក អ៊ុន ចាន់ដា បានអំពាវនាវ និងជំរុញឱ្យគ្រប់ស្ថាប័នមានសមត្ថកិច្ច និងវិស័យឯកជនទាំងអស់ រួមសហការគ្នា បង្ការ បង្ក្រាប ផ្ទន្ទាទោស សង្គ្រោះ ការពារ ដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស។ ការអំពាវនាវបែបនេះ របស់លោក អ៊ុន ចាន់ដា បានធ្វើឡើងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩នេះ ក្នុងឱកាសដែលលោកបានអញ្ជើញ ក្នុងពីពិធីប្រារព្ធទិវា ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ លើកទី១៣ នៅសាលាស្រុកចំការលើ ខេត្តកំពង់ចាម។ លោកអភិបាលខេត្ត បានថ្លែងថា សមត្ថកិច្ចជំនាញត្រូវ ផ្តល់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយពាក់ព័ន្ធអំពើជួញដូរមនុស្សដល់ប្រជាពលរដ្ឋ គ្រប់ស្រ ទាប់តាមមុខសញ្ញារបស់ស្ថាប័នរៀងៗខ្លួន។ បង្កើតសម្ភារអប់រំផ្សព្វផ្សាយ រៀបចំយុទ្ធនាការតាមគ្រប់រូបភាពក្នុងកម្មវិធីសិក្សា វេទិកាសាធារណៈ តាមសហគមន៍ និងតាមបណ្តាញផ្សព្វផ្សាយនានា។ ត្រូវសហការជាមួយវិស័យឯកជន និងទីភ្នាក់ងារជ្រើសរើសពលករ ជំរុញយកចិត្តទុកដាក់ អំពីកម្រិតវប្បធម៌ និងបង្ករលក្ខណៈជំរុញបុគ្គលិកកម្មកររោងចក្រ សហគ្រាស និងពលករទេសន្តប្រវេសន៍ មានឱកាសអភិវឌ្ឍន៍ ចំណេះដឹង សមត្ថភាពជំនាញ និងសហការជាមួយក្រសួងយុត្តិធម៌ ដើម្បីសិក្សាអំពីនីតិវិធី នៃការផ្តល់នីតិសម្បទា ដល់មណ្ឌលថែទាំជនរងគ្រោះ និងបង្កើតជាមណ្ឌលគំរូដែលមានលក្ខណៈងាយស្រួល និងផ្តល់សេវាជាកញ្ចប់។

ជាមួយនេះដែរ លោក អ៊ុន ចាន់ដា ក៏បានបន្ថែមទៀថា ត្រូវមានការ សហការជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធ ផ្នែកឯកជន អង្គការដៃគូ និងសមត្ថកិច្ចក្នុងខេត្ត ដើម្បីប្រមូលព័ត៌មានដែលអាចធានាដល់វិធានការបង្ក្រាបបទល្មើស ចាប់ជនល្មើស និងជួយជនរងគ្រោះក្នុងករណីឆ្លងដែនទាន់ ពេលវេលា។ លោកអភិបាលខេត្តបន្តថា គណៈកម្មា ធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺត្រូវតែបន្តធ្វើជំរុញកាន់តែសកម្ម អនុវត្តនូវវិធានការច្បាប់ ជំរុញកាន់តែម៉ឹងម៉ាត់ និងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់ឆ្នាំ២០១៩-២០២៣ ជំរុញបានសម្រេច តាមគោលដៅគ្រោងទុក ហើយយើងត្រូវការ ការចូលរួមពីមន្ទីរ អង្គភាព ជាសមាជិក ក៏ដូចជាដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន នូវទូទាំងខេត្ត ព្រមទាំងកិច្ចសហការល្អជាមួយខេត្តពាក់ព័ន្ធ រួមសហការគ្នា បង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ ការពារ ដើម្បីកម្ពុជា គ្មានអំពើជួញដូរមនុស្ស៕

## ស្នងការនគរបាលខេត្ត និងសហការី ចូលរួមក្នុងកម្មវិធីទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៩ លើកទី១៣

http://cambodiapolice.com/policekh/ 12:00 pm   23 ធ្នូ 2019

ខេត្តកំពង់ចាម៖ ព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ លោកឧត្តមសេនីយ៍ទោ ឯម កុសល ស្នងការនគរបាលខេត្ត និងសហការី បានអមដំណើរ ឯកឧត្តម អ៊ុន ចាន់ដា អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្សខេត្តកំពង់ចាម ចូលរួមក្នុងកម្មវិធីទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៩ លើកទី១៣ នៅបរិវេណ វិទ្យាល័យ ហ៊ុន សែន ចំការលើ ភូមិថ្នល់បែកកើត ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ។ ដោយមានការចូលរួមពី អាជ្ញាធរគ្រប់ជាន់ថ្នាក់ កងកម្លាំងប្រដាប់អាវុធទាំង៣ប្រភេទ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស បងប្អូនប្រជាពលរដ្ឋ និងមន្ត្រីពាក់ពន្ធ័មួយចំនួនទៀត ៕ សម្រួលដោយ៖ អនុ.ទោ.រឿង សុវណ្ណដែត

## ពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ចំនួន០៣នាក់ ត្រូវកម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ ខេត្តភេតបុរី ប្រទេសថៃ ធ្វើការឃាត់ខ្លួន

https://www.facebook.com/LabourOfficial/  ពលករ 21/12/19

ពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ចំនួន០៣នាក់ ត្រូវកម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ ខេត្តភេតបុរី ប្រទេសថៃធ្វើការឃាត់ខ្លួនកាលពីម្សិលមិញ ក្នុងនោះដែរសមត្ថកិច្ចថៃបានធ្វើការចោទប្រកាន់ជនជាតិថៃម្នាក់ ដែលជាអ្នកផ្តល់កន្លែងស្នាក់នៅដល់ជនអន្តោប្រវេសន៍ខុសច្បាប់ផងដែរ។

## ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៩
## ទិវាជាតិលើកទី១៣ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ
## នៅវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ចន្ទ្រា

https://www.khi-newsdaily.com/  ចេញផ្សាយ ថ្ងៃទី25 ខែDecember ឆ្នាំ2019

(ខេត្តស្វាយរៀង): នៅព្រឹកថ្ងៃ ទី២៥ ខែធ្នូ ឆ្នាំ២០១៩ រដ្ឋបាលខេត្តស្វាយរៀង ប្រារព្ធទិវាជាតិលើកទី១៣ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ នៅវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនចន្ទ្រា ស្រុកចន្ទ្រា ខេត្តស្វាយរៀង ដោយមានការចូលរួមជាអធិបតីពីលោកជំទាវ ឯក សុវណ្ណភារៈ អភិបាលរងខេត្តស្វាយរៀង និងលោកស្រីអភិបាលរងក្រុង-ស្រុក ប្រធាន-អនុប្រធានមន្ទីរ អង្គភាព កងកម្លាំងប្រដាប់អាវុធ លោក លោកស្រី តំណាងអង្គការ ឆាលហ្វាន់ និងលោកនាយក លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស យ៉ាងច្រើនកុះករផងដែរ ។ លោកជំទាវ ឯក សុវណ្ណភារៈ អភិបាលរងខេត្តស្វាយរៀងបានមានប្រសាសន៍ថា: ទិវាជាតិ ១២ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី១៣

ជាទិវាមួយ ក្នុងចំណោមអាទិភាពជាច្រើនសម្រាប់ការលើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសង្គម ក៏ដូចជាការលើកកម្ពស់ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូរមនុស្ស ព្រោះថាអំពើជួញដូរមនុស្ស ជាបទឧក្រិដ្ឋដែលជនល្មើសជួញដូរមនុស្ស បានប្រើប្រាស់គ្រប់កលល្បិច ដើម្បីកេងប្រវ័ញ្ចរំលោភបំពានលើមនុស្ស ដោយមិនខ្វាយខ្វល់ពីទុក្ខវេទនា និងអាយុជីវិតរបស់មនុស្សដែលចង់រស់រៀនជួបជុំគ្រួសារ និងសេចក្តីសុខ ដោយរដ្ឋបាលខេត្តនឹងបន្តការប្តេជ្ញាចិត្តខ្ពស់ រិះរកគ្រប់វិធានការ និងពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនានា ដើម្បីការពារប្រជាពលរដ្ឋ ពីបទល្មើសដ៏ស្មុគស្មាញនេះ។

ជំរុញអនុវត្តយុទ្ធសាស្ត្រទាំង៤ របស់ផែនការជាតិមានជាអាទិ៍ ការងារបង្ការទប់ស្កាត់ កិច្ចការពារជនរងគ្រោះ ការពង្រឹងការអនុវត្តច្បាប់ និងការពង្រឹងកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ លោកជំទាវបន្ថែមថាទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺជាយុទ្ធនាការ ដ៏ទូលំទូលាយសម្រាប់ការផ្សព្វផ្សាយការយល់ដឹង អំពើជួញដូរមនុស្ស ផលប៉ះពាល់ និងអំពីកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សប្រចាំឆ្នាំ ក៏ដូចជាវេទិកាអំពាវនាវដល់ជនរួមជាតិ និងសហគមន៍អន្តរជាតិចូលរួមសហការ ដើម្បីការពារសន្តិសុខ និងសុវត្ថិភាពមនុស្សជាតិ ពីអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពានគ្រប់រូបភាពទៅលើមនុស្ស ។ ដូច្នេះថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ស្ថាប័ន អយ្យការ តុលាការ កងកម្លាំងគ្រប់ប្រភេទ ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងវិស័យឯកជន តែងតែរួមគ្នាជម្នះដោះស្រាយបញ្ហាចំពោះមុខដោយមិនខ្លាចនឿយហត់ ពុះពារប្រឆាំងដាច់ខាត ទៅនឹងសកម្មភាពរបស់ឧក្រិដ្ឋជនស្របតាមទិសដៅ នៃគោលនយោបាយជាតិ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល។

លោកជំទាវក៏ សូមអំពាវនាវ និងប្រកាសជាឱឡារិកក្នុងទិវាជាតិលើកទី១៣ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ បន្តយុទ្ធនាការប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឱ្យប្រជាជនកម្ពុជា និងមនុស្សជាតិ ទទួលបានការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ ផលប្រយោជន៍ស្របច្បាប់ និងភាពសុខដុម រមនា ដោយរួមសហការជាមួយដៃគូពាក់ព័ន្ធនានា ដើម្បីរួមគ្នាបង្ក្រាបអំពើជួញដូរមនុស្សគ្រប់រូបភាព និងផ្តន្ទាទោសជនល្មើសម៉ឺងម៉ាត់ ដើម្បីកាត់បន្ថយឈានទៅលប់បំបាត់បទល្មើសទាំងឡាយនៅកម្ពុជា ទទួលបានភាពសុខសាន្តគ្មានអំពើរំលោភបំពាន និងអំពើជួញដូរមនុស្ស ។ លោកជំទាវមានសង្ឃឹមជឿជាក់ថា ការប្រារព្ធទិវានៅថ្ងៃនេះជាស្មារតីយល់ដឹងដ៏មានសារៈសំខាន់បំផុតក្នុងការផ្សព្វផ្សាយជាសាធារណៈ បំផុសកិច្ចចូលរួមក្នុងការអនុវត្តច្បាប់ ស្តីអំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ព្រមទាំងសូមបងប្អូនប្រជាពលរដ្ឋទាំងអស់ ផ្តល់ការគាំទ្រ បន្តការសហការជាមួយគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តស្វាយរៀង ដើម្បីអនុវត្តច្បាប់នេះ ឲ្យកាន់តែមានប្រសិទ្ធិភាព និងជោគជ័យថែមទៀត ដើម្បីប្រជាជននិងប្រទេសជាតិយើងផងដែរ ៕ ដោយ:Win

## ចាប់ខ្លួនប្រធានក្រុមហ៊ុន ដែលនាំពលករទៅធ្វើការនៅប្រទេសកូរ៉េ

---

http://kampucheathmey.com/ 25/12/2019 5:18 Pm

ភ្នំពេញ ៖ នៅព្រឹកថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩ សមត្ថកិច្ចនាយកដ្ឋាននគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនក្រសួងមហាផ្ទៃ បានបញ្ជូនប្រធានក្រុមហ៊ុន ដែលថានាំពលករទៅធ្វើការនៅប្រទេសកូរ៉េ មកសាលាដំបូងរាជធានីភ្នំពេញ ពាក់ព័ន្ធអំពើឆបោក។ ជនសង្ស័យឈ្មោះ ប៉ែន សុខ ភេទប្រុស អាយុ៤២ឆ្នាំ មុខរបរជាគ្រូបង្រៀនផង និងជាប្រធានក្រុមហ៊ុនផង មានអាសយដ្ឋាននៅភូមិព្រៃទា សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ តាមមន្ត្រីសមត្ថកិច្ចបានបង្ហើបឲ្យដឹងថា ជនសង្ស័យរងនូវពាក្យបណ្តឹងរបស់ជនរងគ្រោះជាង៨០នាក់លើទំហំទឹកប្រាក់ប្រមាណ១៦ម៉ឺនដុល្លារអាមេរិកក្នុងរូបភាពអូសទាញជនរងគ្រោះនាំទៅធ្វើការនៅប្រទេសកូរ៉េ។

សមត្ថកិច្ចបានឲ្យដឹងទៀតថា រយៈពេលកន្លងមកនេះ ជនសង្ស័យបានបើកក្រុមហ៊ុនមួយ ហើយមានបើកសាលាបង្រៀនជាភាសាកូរ៉េ ដើម្បីនាំពលករទៅធ្វើការនៅទីនោះ ដោយក្រុមហ៊ុនបានតម្រូវឲ្យពលករបង់ប្រាក់មុនដូចជា ថ្លៃការស្នាក់នៅ ថ្លៃបង្រៀនភាសាកូរ៉េ ថ្លៃសំបុត្រយន្តហោះ និងឯកសារពាក់ព័ន្ធមួយចំនួនទៀត។ ក្រុមហ៊ុនបានកំណត់ថ្ងៃខែ និងពេលវេលា ដើម្បីនាំពលករចេញដំណើរទៅធ្វើការនៅប្រទេសកូរ៉េ ក៏ប៉ុន្តែនៅពេលដល់ថ្ងៃកំណត់ ស្រាប់តែក្រុមហ៊ុនមិនបាននាំពលករចេញទេនឹង ចេះតែពន្យារពេលរហូត លុះពេលពលករស្រាវជ្រាវទៅទើបដឹងថា ក្រុមហ៊ុននេះអត់មានច្បាប់អនុញ្ញាតពីរដ្ឋាភិបាល ដើម្បីនាំពលករចេញទៅធ្វើការនៅប្រទេសកូរ៉េនោះឡើយ ដូច្នេះហើយបានជាដើមបណ្ដឹងប្ដឹងសមត្ថកិច្ចឲ្យចាប់ខ្លួន ដើម្បីចាត់ការតាមផ្លូវច្បាប់តែម្ដង។ រហូតមកដល់ថ្ងៃដដែលនេះ តុលាការ នៅមិនទាន់បានសាកសួរជនសង្ស័យនៅឡើយទេ៕ អត្ថបទ ៖ មករា

## លោក អំ សំអាត៖ ការជួញដូរមនុស្សមានលក្ខណៈជាប្រព័ន្ធ ទើបសមត្ថកិច្ចពិបាកបង្ក្រាប

https://vayofm.com/news/ 25-12-2019

លោក អំ សំអាត នាយករងទទួលបន្ទុកផ្នែកឃ្លាំមើលសិទ្ធិមនុស្ស នៃអង្គការលីកាដូ (LICADHO) បានលើកឡើងថា ការជួញដូរមនុស្សនៅក្នុងពិភពលោកមានលក្ខណៈជាប្រព័ន្ធ ទើបធ្វើឲ្យសមត្ថកិច្ចពិបាកក្នុងការបង្ក្រាបដោយក្នុងនោះមានទាំងសមត្ថកិច្ចកម្ពុជាផងដែរ។

ថ្មីៗនេះលោកស្រី ខាម៉ិន ម៉ូរ៉េណូ ឯកអគ្គរដ្ឋទូតសហភាព អឺរ៉ុបប្រចាំកម្ពុជា បានលើកឡើងថា កម្ពុជាមានអ្នកធ្វើចំណាកស្រុកច្រើនទៅកាន់ប្រទេសថៃ ពិសេសក្នុងវិស័យ នេសាទ ដែលមួយចំនួនប្រឈមការជួញដូរមនុស្ស ប្រសិនបើគ្មានឯកសារគ្រប់គ្រាន់ និងការជួយជ្រមជ្រែងសមស្របណាមួយនោះ។ លោកស្រីបានអះអាងថា នៅសហភាពអឺរ៉ុបមានគោលនយោបាយអនុញ្ញាតឲ្យប្រជាពលរដ្ឋ អាចផ្លាស់ទីទៅធ្វើការដោយសេរីនៅក្នុងសហភាពអឺរ៉ុប ប៉ុន្តែថានៅក្នុងតំបន់អាស៊ាន មិនទាន់មានយន្តការនេះទេ ដូច្នេះនឹងអាចធ្វើឲ្យប្រជាពលរដ្ឋមួយចំនួនក្លាយជាអ្នកចំណាកស្រុកខុសច្បាប់ និងក្លាយជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស។

លោក អំ សំអាត នាយករងទទួលបន្ទុកផ្នែកឃ្លាំមើលសិទ្ធិមនុស្ស នៃអង្គការលីកាដូ (LICADHO) បានលើកឡើងថា រដ្ឋាភិបាលខិតខំបង្ក្រាបយ៉ាងណាក៏ដោយ ក៏ការជួញដូរមនុស្សនេះនៅតែបន្តកើតមានដដែល ដោយលោកស្នើឲ្យរដ្ឋាភិបាលខិតខំបន្ថែមទៀតក្នុងការបង្ក្រាប ក៏ដូចជាទប់ស្កាត់អំពើជួញដូរមនុស្សនេះ។ លោកបានអះអាងថា ការជួញដូរមនុស្សនៅក្នុងពិភពលោកមានលក្ខណៈជាប្រព័ន្ធ ទើបធ្វើឲ្យសមត្ថកិច្ចពិបាកក្នុងការបង្ក្រាបក្នុងនោះមានទាំងប្រទេសកម្ពុជាផង។ លោក អំ សំអាត បានគូសបញ្ជាក់ថា អំពើជួញដូរមនុស្សកើតមានដោយសារកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត ការធ្វើចំណាកស្រុកដោយពុំបានទទួលបានព័ត៌មានគ្រប់គ្រាន់ ដោយសារកត្តាជីវភាពជាដើម ដែលជាហេតុងាយរងគ្រោះក្នុងអំពើជួញដូរមនុស្សណាស់។ លោកក៏បានគូសបញ្ជាក់ទៀតថា សម្រាប់អង្គការលីកាដូ ក្នុងឆ្នាំ២០១៩នេះ បានទទួលការពឹងពាក់ឲ្យជួយប្រមាណជា ៣០ទៅ ៤០ករណី ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនេះ។

គួរបញ្ជាក់ថា ថ្មីៗនេះលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអំពាវនាវដល់ប្រជាពលរដ្ឋឈប់ចាញ់បោកមេខ្យល់ដែលអូសទាញទៅធ្វើការក្រៅប្រទេសដោយមិនស្របច្បាប់តាមបណ្ដាញផ្សេងៗ។ លោកបានបញ្ជាក់ថាប្រសិនបើមានអ្នកណាម្នាក់ ដើរឃោសនាអូសទាញបងប្អូនចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស សូមរាយការទៅសមត្ថកិច្ចបន្ទាន់ ឬសួរនាំឲ្យបានច្បាស់ថា តើមេខ្យល់នេះមកពីប្រភពណា? ឈ្មោះអ្វី? មានឯកសារស្របច្បាប់ឬមិនមាន? ក្នុងន័យដើម្បីកុំឲ្យប្រជាពលរដ្ឋចាញ់បោកមេខ្យល់ ចាញ់បោកការអូសទាញពីជនខិលខូចទាំងនោះ។

# មន្ត្រីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ទទួលបានការបណ្តុះបណ្តាលស្តីពី យេនឌ័រ

http://cambodiapolice.com/policekh/ 11:06 am   26 ធ្នូ 2019

**ភ្នំពេញ ៖** ដោយមានការចង្អុលបង្ហាញពីថ្នាក់ដឹកនាំ និងទទួលបានការអនុញ្ញាតពី ឯកឧត្តមប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៅព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩នេះ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានរៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពី យេន ឌ័រ ដល់មន្ត្រីនគរបាលចំណុះឲ្យនាយកដ្ឋានចំនួន ២៨នាក់ (ស្រី ៨នាក់) ក្រោមវត្តមាន លោកឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការអនីតិជន តំណាង ឯកឧត្តមប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ ពិធីនេះ ក៏មានការចូលរួមពីលោក លោកស្រីអនុប្រធាននាយកដ្ឋាន នាយ នាយរងការិយល័យ និងមន្ត្រីពាក់ព័ន្ធជាច្រើនរូបទៀតផងដែរ។

លោកស្រីឧត្តមសេនីយ៍ទោ ណា នាង អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងជាប្រធានក្រុមការងារយេនឌ័រ បានឲ្យដឹងថា នៅថ្ងៃនេះលោក លោកស្រីបាននឹងកំពុងបង្ហាញឲ្យឃើញពីការរួមគ្នាក្នុងការយកចិត្តទុកដាក់លើកកម្ពស់ ឋានៈ តួនាទី ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចដល់ស្ត្រីកម្ពុជាឲ្យកាន់តែប្រសើរថែមទៀត។ ជាក់ស្តែងឆ្លងតាមការខិតខំប្រឹងប្រែងរបស់ក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ រហូតមកដល់ពេលនេះយើងសង្កេតឃើញថាតួនាទី ឋានៈ ការយល់ដឹងរបស់ស្ត្រីកំពុងត្រូវបានលើកកម្ពស់យ៉ាងល្អប្រសើរ នេះជាឱកាសបើកលទ្ធភាពកាន់តែច្រើនដល់ការចូលរួម អនុវត្ត តួនាតី ភារកិច្ច សាមគ្គីភាព ការសម្រេចចិត្តរបស់ស្ត្រីគ្រប់លំដាប់ថ្នាក់ ទាំងការងារក្នុងអង្គភាព ការងារសង្គម ក៏ដូចជាការងារនៅក្នុងគ្រួសារផងដែរ។ លោកស្រីបន្ថែមទៀតថា ឆ្លងតាមការបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងយល់ដឹងពីច្បាប់ជាតិ អន្តរជាតិនានា ដែលពាក់ព័ន្ធ និងការលើកកម្ពស់សមភាពយេនឌ័រក្នុងស្ថាប័ននគរបាលជាតិ ពិសេសកាត់បន្ថយគម្លាតយេនឌ័រ បង្កើត និងពង្រីកភាពអង់អាចក្នុងការបំពេញតួនាទីរបស់នគរបាលជាស្ត្រី នៅក្នុងអង្គភាព។

មានប្រសាសន៍បើកវគ្គបណ្តុះបណ្តាល លោកឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការអនីតិជន បានបញ្ជាក់ថា គោលនយោបាយរបស់រាជរដ្ឋាភិបាលបានគាំទ្រ និងលើកកម្ពស់ដល់តម្លៃស្ត្រី នៅក្នុងជួរស្ថាប័នគ្រប់លំដាប់ថ្នាក់ ជាពិសេសនៅក្នុងអគ្គស្នងការដ្ឋាននគរបាលជាតិ ជាក់ស្តែងនៅក្នុងនាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន បានរៀបចំតួនាទី ភារកិច្ច ចាប់ពីថ្នាក់ក្រោមរហូតដល់ថ្នាក់នាយកដ្ឋាន ទាំងនេះស្តែងចេញឲ្យឃើញពីការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ក្នុងការលើកកម្ពស់ស្ត្រីឲ្យចូលរួមចំណែកក្នុងការដឹកនាំការងារជំនាញ និងការងារផ្សេងទៀត។ ស្ត្រីមិនត្រឹមតែជាមេផ្ទះនោះទេ ស្ត្រីក៏មានសមត្ថភាព ជំនាញវិជ្ជាជីវៈអាចធ្វើការងារដូចបុរសផងដែរ។ លោកឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង បញ្ជាក់ទៀតថា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការអនីតិជន ចាំបាច់ណាស់ត្រូវតែមាននគរបាលជាស្ត្រី ព្រោះបទល្មើសជាច្រើនត្រូវមាននគរបាលជាស្ត្រី ដើម្បីធ្វើការសួរចម្លើយពាក់ព័ន្ធនឹងបទល្មើសមួយចំនួន ដូចជាបទល្មើសរំលោភសេពសន្ថវៈជាដើម ដែលនគរបាលជាបុរសពិបាកក្នុងការសួរយកចម្លើយ។

ក្នុងឱកាសនោះ លោកឧត្តមសេនីយ៍ទោអនុប្រធាននាយកដ្ឋាន បានថ្លែងអំណរគុណដល់ លោកជំទាវនាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ និងជាប្រធានក្រុមការងារយេនឌ័រ និងថ្លែងកោតសរសើរដល់ក្រុមការងារយេនឌ័រនាយកដ្ឋាន ដែលបានរៀបចំឲ្យមានវគ្គបណ្តុះបណ្តាលនេះឡើង ដើម្បីឲ្យមន្ត្រីនគរបាលក្នុងនាយកដ្ឋានបានយល់ដឹងពីសមភាពយេនឌ័រ ក៏ដូចជាការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍន៍សង្គមជាតិ៕

## ឯកឧត្តមឯកអគ្គរាជទូត ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួបសំណេះសំណាល ជាមួយបងប្អូនពលករ

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩

នាថ្ងៃពុធ ១៤រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩ ឯកឧត្តម ឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួបសំណេះសំណាល និងផ្តាំផ្ញើរការសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹករាជរដ្ឋាភិបាល ដល់បងប្អូនពលករទាំងអស់ ក៏ដូចជាការណែនាំអំពីសេវានៅស្ថានទូត ច្បាប់ការងារ សិទ្ធិនិងអត្ថប្រយោជន៍ បម្រាម ទោសបញ្ញត្តិ និងការស្នើសុំជំនួយក្នុងករណីបងប្អូនពលករជួបប្រទះបញ្ហាផ្សេងៗក្នុងការស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ។

ឆ្លៀតឱកាសនេះផងដែរ ឯកឧត្តមទូត ក៏បានធ្វើការចែកនំ និងទឹកបរិសុទ្ធ ដល់បងប្អូនពលករ និងកូនៗរបស់ពួកគាត់ ដើម្បីពិសារ ក្នុងកំឡុងពេលរងចាំទទួលឯកសារពីស្ថានទូត។ បងប្អូនពលករខ្មែរទាំងអស់ ពិតជាមានការសប្បាយរីករាយ និងកក់ក្តៅយ៉ាងខ្លាំង ដែលស្ថានទូតក៏ដូចជារាជរដ្ឋាភិបាលដែលតែងតែយកចិត្តទុកដាក់អំពីសុខទុក្ខរបស់ពួកគាត់។

## អាជ្ញាធរខេត្តចាន់បុរី ប្រទេសថៃ ឃាត់ខ្លួនបានពលករខ្មែរលួចធ្វើការខុសច្បាប់០៦នាក់ពលករ

https://www.facebook.com/LabourOfficial/ 26-12-2019

អាជ្ញាធរខេត្តចាន់បុរី ប្រទេសថៃ រឹតបន្តឹងច្បាប់អាជីពហាមឃាត់មិនអនុញ្ញាតឲ្យពលករបទេសធ្វើ ចុះឃាត់ខ្លួនបានពលករខ្មែរលួចធ្វើការខុសច្បាប់០៦នាក់ ។

## អាជ្ញាធរថៃឃាត់ខ្លួនពលរដ្ឋខ្មែរម្នាក់ជិះម៉ូតូកង់បីលក់បន្លែ ដែលជាអាជីពហាមឃាត់មិនអនុញ្ញាតឲ្យពលករបទេសធ្វើ

https://www.facebook.com/LabourOfficial/ 25/12/19

អាជ្ញាធរថៃឃាត់ខ្លួនពលរដ្ឋខ្មែរម្នាក់ជិះម៉ូតូកង់បីលក់បន្លែ ដែលជាអាជីពហាមឃាត់មិនអនុញ្ញាតឲ្យពលករបទេសធ្វើ។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីវេលាម៉ោង០៨ព្រឹក ថ្ងៃអង្គារ ទី២៤ ខែធ្នូ ឆ្នាំ២០១៩ ស្ថិតនៅក្នុងស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ។ ពលរដ្ឋខ្មែរដែលត្រូវកម្លាំងសមត្ថកិច្ចថៃចាប់ខ្លួននោះមានឈ្មោះ ចេន រ៉េន ភេទប្រុស អាយុ ៣៦ឆ្នាំ ។

## កម្លាំងអាជ្ញាធរអន្តោប្រវេសន៍ខេត្តចាន់បុរី ប្រទេសថៃ ឃាត់ខ្លួននារីពលករខ្មែរ ០១នាក់

https://www.facebook.com/LabourOfficial/ 24/12/19

កម្លាំងអាជ្ញាធរអន្តោប្រវេសន៍ខេត្តចាន់បុរី ប្រទេសថៃ ឃាត់ខ្លួននារីពលករខ្មែរ ០១នាក់ ឈ្មោះ (MRs. REASMEY THY) ភេទស្រី អាយុ៣៣ឆ្នាំ សញ្ជាតិខ្មែរ កាន់លិខិតឆ្លងដែនលេខ T0522952 ប្រើប្រាស់វីសាប្រភេទ NON-LA ត្រូវបានសមត្ថកិច្ចអន្តោប្រវេសន៍ខេត្តចាន់បុរី ឃាត់ខ្លួននៅល្ងាចថ្ងៃច័ន្ទ ទី២៣ ខែធ្នូ ឆ្នាំ២០១៩ នៅក្នុងផ្សារចាន់បុរី បន្ទាប់ពីនារីពលករខ្មែរខាងលើ ធ្វើការលក់បន្លែនៅក្នុងផ្សារដែលជាអាជីពហាមឃាត់មិនអនុញ្ញាតិឲ្យពលករបទេសធ្វើ។

# ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៩

## ខេត្តបាត់ដំបងប្រារព្ធទិវាប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស១២ធ្នូនៅសាលមហោស្រព ស្ទឹងសង្កែ

http://www.rasmeinews.com/ December 27, 2019, 2:20 PM

*ដោយៈគ្រញូង/បាត់ដំបង* ៖ នាព្រឹកថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ នៅសាលមហោស្រពស្ទឹងសង្កែមានរៀបចំប្រារព្ធទិវាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូក្រោមប្រធានបទ "រួមគ្នា សហការគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស" ក្រោមអធិបតីភាពលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោក អ៊ុយ រី ប្រធានក្រុមប្រឹក្សាខេត្តនិងលោកស្រី សុំ ចិន្តា អភិបាលរងខេត្ត។

បន្ទាប់ពីលោកស្រី សុំ ចិន្តា អភិបាលរងខេត្តបានឡើងអានរបាយការណ៍ស្តីពីសកម្មភាពនៃអំពើប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងខេត្តបាត់ដំបងរយៈពេល១០ខែ ឆ្នាំ២០១៩រួចមក មានការឡើងចាប់អារម្មណ៍របស់តំណាងអង្គការម៉ារីតាសភីស បទពិសោធន៍ប្អូនម្នាក់ចំណាកស្រុកទៅធ្វើការនៅប្រទេសសុម៉ាលី១ឆ្នាំ និងប្រទេសម៉ាឡេស៊ី៤ឆ្នាំ និងការសម្តែងរឿងខ្លីពីបងប្អូនមួយចំនួនដែលចាញ់បោកមេខ្យល់នាំទៅធ្វើការនៅប្រទេសជិតខាងពិសេសប្រទេថៃដោយខុសច្បាប់ជាដើម។

បន្តមកលោកស្រីរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបញ្ជាក់ប្រាប់ប្អូនៗសិស្ស និស្សិតនិងអ្នកចូលរួមថា ប្រទេសសុម៉ាលីជាប្រទេសមួយនៅអាហ្វ្រិកកណ្តាល ហើយជាប្រទេសក្រីក្រជាងប្រទេសកម្ពុជាឆ្ងាយណាស់ប្រៀបដូចជាក្នុងរបបប្រល័យពូជសាសន៍។ ប្រទេសនេះជួបប្រទះគ្រោះរាំងស្ងួតខ្លាំងណាស់ ធ្វើឱ្យដើមឈើមនុស្ស សត្វមានសភាពស្គាំងស្គមសល់តែក្បាលត្រឹមេងតែមិនហ៊ានសម្លាប់សត្វហូបដោយសុខចិត្តយកឡាមមកឆូតលើខ្លួនសត្វឱ្យចេញឈាមហើយនាំគ្នាអង្គុយបឺតឈាមរហូតដល់សត្វនោះងាប់ទើបសម្លាប់ធ្វើម្ហូបចែកគ្នា។ ប្រទេសសុម៉ាលីនេះសម្បូរចោរសមុទ្រតែងតែប្លន់កប៉ាល់ដឹកទំនិញ ដឹកប្រេងដើម្បីចែកគ្នារស់។

ហេតុអ្វីបានជាមានពលករខ្មែរយើងបានទៅដល់ប្រទេសនេះ ដោយសារតែចាញ់បោកមេខ្យល់នាំយកទៅលក់ឱ្យធ្វើជាអ្នកនេសាទសមុទ្រ។ ចំពោះអ្នកធ្វើការនេសាទសមុទ្រមិនងាយបានឡើងគោកទេរាប់សិបឆ្នាំទើបឡើងម្តង។ ដោយសារតែអង្គការដៃគូបានទៅឃើញពីការជួញដូរមនុស្សហើយបានជួយសង្គ្រោះឱ្យត្រឡប់មកមាតុភូមិវិញហើយ ក៏ត្រូវគេបាញ់ស្លាប់ម្នាក់ដែលពីមុនមានតែ១៨នាក់ ហើយក្រោយមកមានរហូតដល់៣០នាក់។ លោកស្រីរដ្ឋលេខាធិការបានបន្តថា "ការធ្វើចំណាកស្រុករបស់ពលករខ្មែរទៅធ្វើការនៅប្រទេសជិតខាងមិនមែនសុទ្ធតែមានសំណាងដូចគ្នាទេ"។ ពលករខ្មែរភាគច្រើនដែលគ្មានការយល់ដឹងពីច្បាប់ខ្វះថវិកាទៀត បានចាញ់បោកមេខ្យល់នាំយកទៅលក់ឲ្យថៅកែថៃឬក៏នាំទៅទម្លាក់ចោលនៅក្នុងព្រៃក្នុងទឹកដីថៃ ហើយរត់គេចខ្លួនបាត់។អ្នកដែលទៅធ្វើការនៅប្រទេសគេៗមិនគិតពីសញ្ញាបត្រ ដែលយើងមានទេគឺចាត់ទុកយើងជាកម្មករទាំងអស់។ចុងក្រោយពេលត្រឡប់មកស្រុកកំណើតវិញ មានតែដៃទទេហើយខ្លះទៀតថែមទាំងនាំយកជំងឺអេដស៍ ញៀនថ្នាំញៀនភ្លេចប្រពន្ធកូន ភ្លេចក្រុមគ្រួសារមកបំផ្លាញក្រុមគ្រួសារអស់។ អ្នកខ្លះត្រូវគេចាប់ដាក់គុកដោយគេចោទថាចូលប្រទេសគេគ្មានច្បាប់ត្រឹមត្រូវ ហើយក៏មានអ្នកខ្លះស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍និងគ្រោះថ្នាក់ពេលបំពេញការងារជាកម្មករសំណង់ត្រូវដឹកយកមកស្រុកកំណើតវិញ។

លោកស្រី ជូ ប៊ុនអេង បានបញ្ជាក់ថា សព្វថ្ងៃប្រទេសយើងមានការអភិវឌ្ឍខាងអចលនវត្ថុខ្វះកម្លាំងពលកម្មរាប់ម៉ឺននាក់ ដោយសារតែពលរដ្ឋយើងភាគច្រើននាំគ្នាចំណាកស្រុកទៅធ្វើពលកម្មឱ្យគេ ដោយនៅតាមភូមិ ឃុំនីមួយៗនៅសល់តែមនុស្សចាស់ៗមើលចៅដោយគេគិតថា ធ្វើការនៅប្រទេសគេទទួលបានកម្រៃខ្ពស់។ ប៉ុន្តែបើ

ប្រៀបទៅកម្រៃពលកម្មនៅស្រុកយើង និងនៅស្រុកគេមិនខុសត្រូវគ្នាប៉ុន្មានទេ ហើយបាននៅជិតក្រុមគ្រួសារ និងមិនត្រូវគេមើលងាយមើលថោកទៀតផង។ ក្នុងទិវានេះដែរមានចែកប័ណ្ណថ្លែងអំណរគុណដល់អង្គការដៃគូមួយចំនួន ថតរូបអនុស្សាវរីយ៍ និងបង្ហោះប៉េងប៉ោងជានិមិត្ត ដើម្បីបញ្ចប់កម្មវិធី៕B/

## អភិបាលខេត្តត្បូងឃ្មុំ អំពាវនាវដល់អ្នកពាក់ព័ន្ធទាំងអស់ ត្រូវរួមសហការគ្នាទប់ស្កាត់ឲ្យបានដាច់ខាត រាល់អំពើជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ

http://www.freshnewsasia.com/ 2019-12-27

**(ត្បូងឃ្មុំ)៖** គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តត្បូងឃ្មុំ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ បានរៀបចំ ប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ២០១៩ ខួបលើកទី១៣ ក្រោមប្រធានបទ « រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស»។ ពិធីនេះធ្វើឡើងក្រោមអធិបតីភាពលោក ជាម ច័ន្ទសោភ័ណ អភិបាលខេត្តត្បូងឃ្មុំ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត និងលោកស្រី។

ក្នុងសារបស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលអានដោយលោក ជាម ច័ន្ទសោភ័ណ បង្ហាញទៅកាន់អ្នកចូលរួមទាំងអស់ មានខ្លឹមសារពោពេញដោយអត្ថន័យ ជុំវិញការទប់ស្កាត់ការជួញដូរ មនុស្ស។

ឆ្លៀតក្នុងឱកាសនោះ លោកអភិបាលខេត្ត បានធ្វើការអំពាវនាវដល់ អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ត្រូវរួមសហការគ្នាទប់ស្កាត់ឲ្យបានដាច់ខាតនៅគ្រប់រូបភាព ឆបោកដែលឈានដល់ ការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ ។ លោក ជាម ច័ន្ទសោភ័ណ ក៏បានអំពាវនាវដល់ប្រជាពលរដ្ឋក្នុងខេត្តត្បូងឃ្មុំទាំងមូល និងខេត្តផ្សេងៗទៀតមកចូលរួមពិធីបុណ្យឆ្លងឆ្នាំសកល២០២០ខាងមុខនេះ នៅក្នុងបរិវេនរដ្ឋបាលខេត្ត ដែលនឹងមានការប្រគុំតន្ត្រី រាំលេងសប្បាយជុំគ្នា និងទស្សនាការបាញ់កាំជ្រួចអបអរបុណ្យឆ្លងឆ្នាំផងដែរ។

បើតាមលោកស្រី នី ចាន់ធីតា អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឲ្យដឹងថា អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺជាបរិបទសាកលដែលនៅតែបន្តកើតមាន អាស្រ័យដោយកត្តាសំខាន់៣ គឺការអប់រំសង្គម ការអនុវត្តច្បាប់ នឹងការធក់ឱកាសពីជនល្មើស។ រូបភាពអំពើជួញដូរ មនុស្សមិនត្រឹមតែជាការជួញដូរ ឬកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទប៉ុណ្ណោះទេ តែក្នុងឆ្នាំកន្លងទៅក៏មានលេចចេញបាតុភាពមួយចំនួនដែលទំនោរទៅរកអំពើជួញដូរសេរីរាង្គ និងបទល្មើសរត់ពន្ធ ឬជួញដូរទារកឆ្លងដែន ក្រោមរូបភាពដែលហៅថា អំពើជួលពរពោះជំនួស ទៀតផង។ ដែលនេះជាកង្វល់ថ្មីមួយទៀតដែលចាំបាច់ត្រូវ មានវិធានការស៊ើបអង្កេតស្រាវជ្រាវ និងបង្ក្រាបឲ្យបានទាន់ពេលវេលា៕

## ១ឆ្នាំ កងរាជអាវុធហត្ថ បង្ក្រាបបទល្មើស ជាង២ពាន់ករណី

https://www.dap-news.com/national/ ByPH104 Posted on December 26, 2019

ភ្នំពេញ ៖ ក្នុងរយៈពេលពេញមួយ ឆ្នាំ២០១៩នេះ កម្លាំងកងរាជអាវុធហត្ថ បានធ្វើការបង្ក្រាបបទល្មើសចំនួន ២,៣៩៨ករណី ក្នុងប្រតិបត្តិការ ២,៥៥០លើក ។ នេះបើយោងតាមរបាយការណ៍ បូកសរុបលទ្ធការងារ កងរាជអាវុធហត្ថ ឆ្នាំ២០១៩ និងលើកទិសដៅការងារបន្ត ឆ្នាំ២០២០ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ។ របាយការណ៍បានឲ្យដឹងទៀតថា បង្ក្រាបបទល្មើសជាក់ស្តែងបានចំនួន ២,១៣៥ ក្នុងប្រតិបត្តិការ២,២២២លើក ។ ក្នុងនោះរួមមាន ៖ ឃាតកម្ម១៤លើក , បង្ខាំងមនុស្ស និងជំរិតទារប្រាក់១៣លើក , រំលោភសេពសន្ថវៈ៣៥លើក , លួចមានស្ថានទម្ងន់ទោស២៨លើក , ហិង្សាមានស្ថានទម្ងន់ទោស៦៧លើក , ជួញដូរមនុស្ស៨លើក , ជួញដូរចែកចាយគ្រឿងញៀន៩៦៣លើក , លួច១៤២លើក , ឆក់៣៣លើក , ហិង្សាដោយចេតនា២៧លើក , ប្រើប្រាស់និងរក្សា

អាវុធខុសច្បាប់២១លើក , ការប្រើប្រាស់គ្រឿងញៀន១៨៨លើក , ដំណាំកញ្ឆា៤លើក , ធ្វើខូចខាតដោយចេតនា ១៦លើក , រំលោភលើទំនុកចិត្ត៣០លើក និងល្បែងស៊ីសង់ចំនួន៤៨លើក ។

របាយការណ៍បន្តថា ចំពោះការស្រាវជ្រាវបង្ក្រាបបានចំនួន២៦៣ ក្នុងប្រតិបត្តិការ៣២៨លើក រួមមាន៖ ឃាតកម្ម៩លើក , បង្ខាំងមនុស្សខុសច្បាប់១លើក , រំលោភសេពសន្ថវៈ២លើក , លួចមានស្ថានទម្ងន់ ទោស១៤ លើក , ហិង្សាមានស្ថានទម្ងន់ទោស៣៧លើក , លួច៧១លើក , ឆក់៧លើក , ឆបោក៣៧លើក , ហិង្សាដោយចេតនា២៣លើក , រំលោភលើទំនុកចិត្ត៣០លើក , ធ្វើឲ្យខូចខាតដោយចេតនា៤លើក , ទទួលផលចោរកម្ម៣ លើក និងក្មេងទំនើង១លើក៕ ដោយ៖ធី លីថូ

## អ.ស.ប លើកកម្ពស់សិទ្ធិរបស់ពលករនៅទិវាចំណាកស្រុកពិភពលោក

https://khmer.voanews.com/ 26 ធ្នូ 2019 ម៉ែន គឹមសេង

អង្គការសហប្រជាជាតិ បានផ្តោតសំខាន់នៅទិវាចំណាកស្រុកពិភពលោក លើសិទ្ធិពលករចំណាកស្រុកទាំងអស់ឲ្យទទួលបានការការពារសិទ្ធិមនុស្សគ្រប់បែបយ៉ាងដូចពលរដ្ឋនានាដែរ ដោយសារនៅពេលនេះ មានពលរដ្ឋចំនួន២៧២លាននាក់នៅលើពិភពលោកបានចាកចេញពីលំនៅដ្ឋានទៅធ្វើការនៅក្រៅប្រទេស។ អ្នកស្រី មូរ សុខហួរអនុប្រធានគណបក្សសង្គ្រោះជាតិ បានបញ្ជាក់ក្នុងកម្មវិធីហេឡូវីអូអេប្រចាំខែថា គណបក្សរបស់អ្នកស្រីកំពុងរៀបចំបណ្តាញ ដើម្បីការពារផលប្រយោជន៍ពលករចំណាកស្រុកនៅប្រទេសថៃ ដើម្បីជួយពួកគេឱ្យមានសំឡេងឡើងនិងស្តារកិត្តិយសរបស់ពួកគេ ក្នុងពេលធ្វើការនៅទីនោះដោយមិនទុកចោលពួកគេទេ។ មានពលរដ្ឋកម្ពុជាជាង២លាននាក់បានចាកចេញពីស្រុកទៅធ្វើការនៅក្រៅប្រទេស ជាពិសេសគឺប្រទេសថៃ កូរ៉េខាងត្បូង និងម៉ាឡេស៊ីជាដើម។

## វៀតណាម មានការងារក្នុងស្រុកជាង ១,៥លានកន្លែង ខណៈប្រជាជន ១៤៧.០០០នាក់ នៅធ្វើការនៅក្រៅប្រទេស

https://www.dap-news.com/national/ ByYVC111 Posted on December 26, 2019

ហាណូយ៖ ក្រសួងការងារវៀតណាម បានរាយការណ៍កាលពីថ្ងៃពុធថា ការងារក្នុងស្រុកជាង ១,៥ លានត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៩ ខណៈដែលមនុស្ស ១៤៧.០០០ នាក់ត្រូវបានបញ្ជូនទៅធ្វើការនៅក្រៅប្រទេស។ នេះបើយោងតាមការចេញផ្សាយរបស់សារព័ត៌មាន Vietnam News ចេញផ្សាយនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០១៩នេះ។ នៅក្នុងសន្និសីទបូកសរុបការងារមួយឆ្នាំដោយក្រសួងការងារ យុទ្ធជនពិការ និងសង្គមកិច្ច លោកអនុរដ្ឋមន្ត្រី ឡេ តាន់ដុងបាននិយាយថា ជនជាតិវៀតណាមសរុបជាង ១,៦៥ លាននាក់ត្រូវបានជួលឱ្យធ្វើការនៅឆ្នាំនេះ ដែលលើសពីគោលដៅដំបូង ៣,៥ ភាគរយ។

លោក ដុង បាននិយាយថា សមិទ្ធិផលទាំងនេះបានកើតឡើងបន្ទាប់ពីមានសកម្មភាពនិងផែនការជាបន្តបន្ទាប់ដែលបានអនុវត្តដោយក្រសួង ដើម្បីអភិវឌ្ឍទីផ្សារការងារ ការព្យាករណ៍ តម្រូវការ និងដើរតួជាអន្តរការី ដើម្បីភ្ជាប់ការផ្គត់ផ្គង់និងតម្រូវការនៅក្នុងទីផ្សារ។ អនុរដ្ឋមន្ត្រីក្រសួងការងារវៀតណាមរូបនេះ បន្ថែមថា “ ក្រសួងបានអនុវត្តកម្មវិធីគម្រោងនិងគោលនយោបាយជាច្រើនស្តីពីជំនួយការងារសម្រាប់កម្មករជាពិសេសយុវជនពេញវ័យ ជនពិការ កម្មករចំណាកស្រុក និងជនបទ ស្ត្រីនិងជនភាគតិច៕

## អ្នកសារព័ត៌មានទូរទស្សន៍ថៃម្នាក់ត្រូវជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ ដោយសារនិយាយរឿងស្ថានភាពការងារពលករចំណាកស្រុក

https://khmernote.com/news/ December 27, 2019 lyda

អ្នកសារព័ត៌មានទូរទស្សន៍ថៃម្នាក់ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ កាលពីថ្ងៃអង្គារ ពីបទនិយាយបង្ខូចកេរ្តិ៍ឈ្មោះកសិដ្ឋានចិញ្ចឹមមាន់មួយកន្លែង នៅលើបណ្តាញសង្គម Twitter ។ អ្នកសារព័ត៌មាននោះមានឈ្មោះថា Suchanee Cloitre អាយុ ៣០ឆ្នាំ បម្រើការឱ្យទូរទស្សន៍ Voice TV នៅពេលដែលនាងបាននិយាយពីបញ្ហាស្ថានភាពការងារនៅឯកសិដ្ឋាន Thammakaset ។ ប៉ុន្តែយ៉ាងណាក៏ដោយនាងមិនដែលគិតថា ទោសរបស់នាងគឺធ្ងន់ធ្ងរឈានដល់ការជាប់ពន្ធនាគារនោះទេ ហើយនាងក៏កំពុងបារម្ភថាតើកូនរបស់នាងនឹងទៅជាយ៉ាងណាបើគ្មាននាងមើលថែ។

វាមិនច្បាស់ទេថា នាងបាននិយាយប៉ះពាល់អ្វីខ្លះ ប៉ុន្តែប្រភពនិយាយថាការសរសេរលើបណ្តាញសង្គម Twitter របស់នាង ផ្តោតលើពាក្យបណ្តឹងរបស់ក្រុមពលករចំណាកស្រុកមួយក្រុមមកពីប្រទេសមីយ៉ាន់ម៉ា ដែលពួកគេបានប្តឹងទៅគណៈកម្មាធិការសិទ្ធិមនុស្សរបស់ប្រទេសថៃអំពីស្ថានភាពការងារនៅកសិដ្ឋាន Thammakaset ក្នុងឆ្នាំ២០១៦។ ប៉ុន្តែយ៉ាងណាតុលាការថៃបានបញ្ជាឱ្យកម្មករគួរតែទទួលបានសំណង បន្ទាប់ពីច្រានចោលបណ្តឹងបរិហារកេរ្តិ៍ដែលថា កសិដ្ឋាននេះបានចាប់ផ្តើមបំពានសិទ្ធិកម្មករ។ ចំណែកកសិដ្ឋាន Thammakaset ដែលបានបដិសេធការចោទប្រកាន់តាំងពីដំបូងមក ក៏បានដាក់ពាក្យប្តឹងអ្នកកាសែត និងសកម្មជនចំនួន ២០នាក់ ជុំវិញករណីនេះដែរ៕

# ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៩

## អាជ្ញាធរស្រុកមណ្ឌលសីមាបានរៀបចំប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៩ នៅឃុំប៉ាក់ខ្លង

https://www.facebook.com/ សារព័ត៌មាននាគមាស **ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៩ ដោយ ជីវ័ន្ត**

(ខេត្តកោះកុង)÷ នៅព្រឹកថ្ងៃសុក្រ ០២ កើត ខែបុស្ស ឆ្នាំកុរ ឯក ស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១៩ លោក ប្រាក់ វិចិត្រ អភិបាលស្រុកមណ្ឌលសី មា ដំណាងលោកជំទាវ មិថុនា ភូថង អភិបាល នៃគណៈអភិបាល ខេត្តកោះកុង អញ្ជើញជាអធិបតី ក្នុងពិធីអបអរសាទរទិវាជាតិលើកទី១៣ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២ ០១៩ ដោយមាន ការចូលរួមពីលោក ស្រីប្រធានមន្ទីរកិច្ច ការនារីខេត្ត សមាជិ កក្រុមប្រឹក្សាស្រុក ក្រុម ប្រឹក្សាឃុំ កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទ លោកគ្រូ អ្នកគ្រូ ប្រជាការពារភូមិ យុវជនកក្កាបាទក្រហមកម្ពុជាខេត្ត យុវជន ស.ស.យ.ក ស្រុក សិស្សកាយ រិទ្ធ និងប្រជាពលរដ្ឋក្នុងឃុំប៉ាក់ខ្លងយ៉ាងច្រើនកុះករ នៅបរិវេណសាលាឃុំប៉ាក់ខ្លង ស្រុកមណ្ឌល សីមា ខេត្តកោះកុង ។

ថ្លែងក្នុងពិធីទិវាជាតិប្រយុទ្ធប្រឆាំ ងអំពើជួញដូរមនុស្ស ២ធ្នូ ២០១ ៩ លោកប្រាក់ វិចិត្រ អភិបាលស្រុ កមណ្ឌលសីមា បានអាននៅស ន្ទរកថារបស់លោកជំទាវ មិថុនា ភូថង អភិបាលនៃគណៈខេត្តទាំងស្រុង ដើម្បីឲ្យបងប្អូនប្រជា ពលរដ្ឋយើងបានយល់ដឹងអំពើការជួញដូរមនុស្ស ។ ឆ្លៀតក្នុងឱកាសនោះដែរ លោកប្រាក់ វិចិត្រ អភិបាលស្រុកមណ្ឌ លសីមា ថ្លែងថា រឿងជួញដូរមនុ ស្សជារឿងសំខាន់មួយ ដែលរាជ រដ្ឋាភិបាលនៃកម្ពុជាបានយកចិត្ត ទុកដាក់ ហើយបង្កើតសច្ចាអនុ ក្រឹត្យ ការផ្សព្វផ្សាយទូលំទូលា យដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ តាំងពីថ្នាក់រាជរដ្ឋាភិបាលរហូត ដល់ថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ លោកថ្លែងបន្តថា ប្រទេសជាច្រើ នដែលស្ត្រីខ្មែរត្រូវរងគ្រោះ ក្នុងការជួញដូរ តាមរយៈរៀបការ ជាមួយជនជាតិចិន ជនជាតិម៉ាឡេស៊ី ការរួចយកទៅប្រទេសគេធ្វើជាប្រពន្ធនៅពេលគេអស់ចិត្ត ពួកគេនឹងលក់ទៅបន្តឲ្យបនបម្រើផ្លូវភេទ ព្រោះថាជនបរទេស គេពុំមានមនោសញ្ចេតនាដូចជនជាតិយើងនោះទេ ទាំងនេះហើយដែលស្ត្រីយើងទាំងអស់គ្នាត្រូវប្រុងប្រយ័ត្ន? ស្ត្រីជាមាតាដៃមួយរយ ហើយស្ត្រីជាមាតាពិតភព លោកផងដែរ ដើម្បីអនុវត្តទៅតាមអនុសាសន៍របស់ប្រមុខដឹកនាំរបស់យើង អាជ្ញាធរគ្រប់លំដាប់ថ្នាក់

ពិសេសកងកម្លាំងប្រដាប់អាវុធ ត្រូវតាម ដានការសំណាក់ស្រុករបស់ប្រ ជាពលរដ្ឋយើង និងតាមដាននូវរាល់ការរៀបអាពាហ៍ពិពាហ៍ជា មួយជនបរទេស បន្ទាប់មកពិធីនេះបានរៀបចំកាន់បដាដង្ហែជុំវិញឃុំប៉ាក់ខ្លងដើម្បី ឲ្យពលរដ្ឋយល់ដឹង និងចេះប្រុង ប្រយ័ត្នខ្ពស់នូវរាល់បញ្ហាអំពើការជួញដូរមនុស្ស ៕ ដោយ គន្ធី ភ្នាក់ងារ

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលរដ្ឋខ្មែរចំនួន០៨នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 27-12-2019

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ នាព្រឹកថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ បានទទួលពលរដ្ឋខ្មែរ ចំនួន ០៨នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែន ដោយខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកចាក់ប្រែង ខេត្តព្រះវិហារ ៕

## ប៉ូលិសថៃចាប់ខ្លួនម្ដាយម្នាក់ពីបទយកកូនស្រីសតិមិនគ្រប់អាយុ១៩ឆ្នាំឱ្យទៅដេកជាមួយបុរស៧នាក់ រួចគំរាមទារលុយរាប់ម៉ឺនដុល្លារ

http://khmeread.com/ December 29, 2019 10:54PM

ប៉ូលិសថៃបានចាប់ខ្លួនម្ដាយម្នាក់ បន្ទាប់ពីគាត់បានយកកូនស្រីសតិមិនគ្រប់ឱ្យទៅដេកជាមួយបុរស៧នាក់ រួចគំរាមទាលុយរាប់ម៉ឺនដុល្លារ។ នេះយោងតាមកាសែត Daily Mail សរសេរកាលពីថ្ងៃទី ២៩ធ្នូ។ ស្ត្រីអាយុ ៣៩ ឆ្នាំនេះត្រូវបានចាប់ខ្លួននៅផ្ទះ Apartment របស់គាត់នៅក្រុងបាងកកនៅថ្ងៃបុណ្យណូអែល បន្ទាប់ពីដីកាចាប់ខ្លួនត្រូវបានចេញដោយតុលាការខេត្តអ៊ូប៊ុនកាលពីថ្ងៃទី ២៩ វិច្ឆិកា។ បុរសទាំងនោះបានប្ដឹងស្ត្រីនេះទៅប៉ូលិស ក្រោយពីស្ត្រីជាម្ដាយគំរាមទារលុយពីពួកគេដោយចោទពីបទរួមភេទជាមួយកូនស្រីអាយុ ១៩ ឆ្នាំរបស់គាត់។

កាសែត Bangkok Post បានសរសេរថា បុរសម្នាក់ជាអាជីវករអាយុ២៤ឆ្នាំនិយាយថា គាត់បានជួបកូនស្រីនេះនៅលើកម្មវិធីណាត់ជួបគ្នាឈ្មោះថា Badoo ដោយបានដោះដូរលេខទូរស័ព្ទគ្នា រួចណាត់ជួបនៅមន្ទីរពេទ្យ Hong Han នៅថ្ងៃទី ៣ មិថុនា។ គាត់បានប្រាប់ប៉ូលិសថា នៅពេលគាត់ជួបក្មេងជំទង់អាយុ ១៩ ឆ្នាំរូបនេះ គាត់យល់ថានាងស្អាតគួរឱ្យទាក់ទាញ ប៉ុន្តែស្ងាត់ស្ងៀម ហើយពួកគេបានរួមដំណេកជាមួយគ្នាមួយយប់នៅរមណីយដ្ឋានមួយ។ ក្រោយមកមួយថ្ងៃឪពុករបស់នាងបានប្រាប់អាជីវករម្នាក់នោះថា មានស្ត្រី២នាក់ស្លៀកពាក់ឯកសណ្ឋានរដ្ឋាភិបាលបានទៅផ្ទះគាត់ ហើយនិយាយថាអាជីវកររូបនេះបាន "លួងយកកូនស្រីអាយុ១៩ឆ្នាំទៅរួមភេទ"។ ស្ត្រីពីនាក់នោះ រួមមានទាំងម្ដាយអាយុ ៣៩ ឆ្នាំផង បានគំរាមចាប់ខ្លួនបុរសអាយុ១៩ឆ្នាំរូបនេះ និងទាមទារគាត់ ២៥០.០០០ បាត។ គាត់បានបង់៥០.០០០បាតសិន ហើយសុំសងលុយសេសសល់នៅសប្ដាហ៍ក្រោយ មុនពេលគាត់ដឹងថាក្មេងស្រីនោះមានបញ្ហាសតិមិនគ្រប់ទឹក និងត្រូវបានម្ដាយយកមកលក់ដើម្បីគំរាមទារប្រាក់ពីពួកគេ។

ប៉ូលិសបានកោះហៅមិត្តរបស់ម្ដាយនោះដើម្បីសាកសួរ ដោយនាងជាមិត្តនោះសារភាពថា ម្ដាយអាយុ៣៩ឆ្នាំនេះបានស្គាប់កូនស្រីគាត់លើកម្មវិធី Badoo បើទោះបីជាកូនស្រីមិនចេះអានឬសរសេរក៏ដោយ។ ម្ដាយនេះបានយកកូនស្រីទៅបោកបុរស៦នាក់ផ្សេងទៀតនៅខេត្តអ៊ូប៊ុន ខេត្តខនខែន ខេត្តសាខននគរ និង ខេត្តណងប៊ូឡាំភូ។ ក្រោយការស៊ើបអង្កេតល្អិតល្អន់ ប៉ូលិសបានសុំដីកាចាប់ខ្លួនម្ដាយនេះដល់ផ្ទះ ដោយឆែកឆេរឃើញនិងរឹបអូសបានឯកសណ្ឋានរដ្ឋាភិបាលនៅថ្ងៃទី២៥ធ្នូ។ កូនស្រីគាត់ក៏នៅផ្ទះជាមួយម្ដាយដែរ ហើយម្ដាយនេះត្រូវបាននាំខ្លួនសាកសួរនៅប៉ុស្តិ៍ប៉ូលិស។ ត្បិតម្ដាយនេះបដិសេធការចោទប្រកាន់ពីបទជំរិតទារប្រាក់ ម្ដាយនេះបានសារភាពថាបានស្លៀកពាក់ឯកសណ្ឋានរដ្ឋាភិបាលមែន និងត្រូវប៉ូលិសចោទពីបទជំរិតទារប្រាក់ចំនួន១០ករណី៕

# ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៩

## ពលរដ្ឋខ្មែរជិត៤0ម៉ឺននាក់ ចេញពីផ្ទះ ទៅក្រៅប្រទេស ដើម្បីស្វែងរកការងារធ្វើ ក្នុងមួយខែៗ

http://bayontv.com.kh/ 31/12/2019

ភ្នំពេញ ៖ យោងតាមរបាយការណ៍ឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បាន ឲ្យដឹងថា ប្រជាពលរដ្ឋខ្មែរជាមធ្យមចំនួន៣៦០.០០០នាក់ បានចាកចេញពីផ្ទះសម្បែងរបស់ពួកគេទៅ កាន់ប្រទេសដទៃ ដើម្បីស្វែងរកការងារក្នុងមួយខែៗ ដោយក្នុងនោះស្ត្រីជាង៤៥ភាគរយ និងកុមារជាង២ ភាគរយ។ របាយការណ៍ដែលទូរទស្សន៍បាយ័នទទួលបានកាលពីល្ងាចថ្ងៃទី៣០ ខែធ្នូ ម្សិលមិញខណៈមន្ត្រី អន្តរក្រសួងដឹកនាំដោយលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សបើកកិច្ចប្រជុំ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅឆ្នាំ២០២០ ។ ក្រសួងមហាផ្ទៃ បានបញ្ជាក់ឲ្យដឹងទៀតថា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃអគ្គស្នងការនគរបាលជាតិ បានធ្វើ បច្ចុប្បន្នភាពជាប្រចាំថ្ងៃលើស្ថិតិពលរដ្ឋខ្មែរ ដែលធ្វើចំណាក់ស្រុកនៅក្រៅប្រទេស ប្រចាំខែនីមួយៗ។

ដោយការធ្វើបច្ចុប្បន្នភាពនោះ បានពិនិត្យឃើញថា ការធ្វើចំណាក់ស្រុករបស់ពលរដ្ឋខ្មែរ នៅ តែបន្តមានជាប្រក្រតី ជាមធ្យមចំនួនពលរដ្ឋដែលអវត្តមានជាប្រចាំពីលំនៅឋាន មូលហេតុចាក់ចេញ ទៅស្នាក់នៅធ្វើការក្នុងប្រទេសគោលដៅ ប្រមាណ ៣៦០.០០០នាក់ ក្នុងមួយខែៗ ក្នុងនោះ មានស្ត្រី ១៦៣.០០០នាក់ ស្មើ និង៤៥.២៧ភាគរយ និងកុមារប្រមាណ៨៨០០នាក់ស្មើ និង២.៤៤ភាគរយ ក្នុងនោះអ្នកចេញទៅរកការងារនិងស្នាក់នៅប្រទេសគោលដៅដោយស្របច្បាប់ ប្រមាណ២១០.០០០ នាក់ ស្មើនិង៥៨.៣៣ភាគរយនិងប្រមាណ៤១.៦៧ ភាគរយ មិនបានចាក់ចេញដោយស្របច្បាប់នោះ ឡើយ។ របាយការណ៍ បានបញ្ជាក់ឲ្យដឹងទៀតថា ប្រជាពលរដ្ឋដែលធ្វើចំណាក់ស្រុកនោះ ទោះបីជា មានការវិលត្រឡប់មកវិញមួយចំនួនក៏នៅតែមានអ្នកបានចាកចេញទៅវិញជាមួយមនុស្សថ្មីៗទៀត។ ឯមួយចំនួនតូចបានវិលមករស់នៅក្នុងស្រុកវិញ និងមួយចំនួនកំពុងតែបាត់ដំណឹងទាក់ទងមិនបាន ដោយមូលហេតុផ្សេងៗ។ ទិន្នន័យនេះ ក៏អាចបញ្ជាក់បានដែរថា វត្តមានពលករកម្ពុជា ដែលនៅក្រៅ ប្រទេសមានស្ថេរភាពជាតួលេខ ប្រចាំខែតែមនុស្សមានការផ្លាស់ប្តូរ គឺអ្នកដែលត្រឡប់មកវិញដោយ មូលហេតុធ្វើការលែងកើត ឬចង់ត្រឡប់មករស់នៅក្នុងស្រុកវិញជួបជុំគ្រួសារ ត្រូវជំនួសដោយមនុស្សថ្មីទៀត ដើម្បីបង្គ្រប់សេចក្តីត្រូវការ ដើម្បីរក្សាតួលេខនៃពលករដែលមានក្នុងប្រទេសជាគោលដៅ។

យ៉ាងណាក៏ដោយរបាយការណ៍ មិនបានបញ្ជាក់ថា ក្នុងចំណោមពលរដ្ឋខ្មែរជិត៤០ម៉ឺននាក់ ចេញទៅក្រៅប្រទេសនោះថា ជាការជួញដូរមនុស្សនោះឡើយ ប៉ុន្តែក្រសួងការបរទេសកម្ពុជា បានសហការជាមួយប្រទេសនិងអង្គការជាដៃគូបានជួយសម្របសម្រួលបញ្ជូនជនរងគ្រោះដែលត្រូវ បានជួញដូរមកប្រទេសកម្ពុជាវិញក្នុងឆ្នាំ២០១៩ កន្លងទៅនេះ មានចំនួន៣២.២៣៥នាក់ ដោយក្នុងនោះ ស្ត្រី១១២.៧៤៧នាក់៕